**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាក្រុមហ៊ុន

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក. កែវ ចាន់ណាលីន**

**ក. វងចាំ លីស៊ាង**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **កែវ ចាន់ណាលីន** និងនាងខ្ញុំឈ្មោះ **ខេងចាំ លីស៊ាង** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកតញ្ញូតាធម៌ និងការគោរពដឹងគុណ យ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយដ៏មានគុណទាំងពីរដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា និងទំនុកបម្រុងដល់យើងខ្ញុំទាំងពីរនាក់តាំងពីចាប់កំណើត រហូតដល់ធំដឹងក្តី។ លោកអ្នកមានគុណតែងតែយកចិត្តទុកដាក់ ពុះពារគ្រប់ឧបសគ្គ ដើម្បីផ្គត់ផ្គង់ឱ្យកូនបានទទួលការអប់រំ តាំងពីថ្នាក់បឋម រហូតដល់ថ្នាក់បរិញ្ញាបត្រ។ លោកឪពុក អ្នកម្តាយ បានលះបង់កម្លាំងកាយចិត្ត ក្នុងការទូន្មាន ប្រៀនប្រដៅ និងចំណាយទ្រព្យសម្បត្តិដើម្បីឱ្យកូនៗ ទទួលបានអនាគតល្អ ដោយមិនមានការរារែក និងប្រកបដោយព្រហ្មវិហារធម៌។ បើគ្មានអ្នកមានគុណទេ យើងទាំងពីរនាក់ ក៏មិនអាចទទួលបានអ្វីៗមកដល់សព្វថ្ងៃនេះដែរ។ ព្រហ្មវិហារធម៌ និងឧបការគុណរបស់លោក ពិតជាមានតម្លៃណាស់មិនអាចកាត់ថ្លៃបានឡើយ។

ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានដេប៉ាតឺម៉ង់ អនុប្រធានដេប៉ាតឺម៉ង់ និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

លោក លោកស្រី ជាគណៈសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការបង្ហាត់បង្រៀន និងអប់រំឱ្យយើងខ្ញុំទាំងពីរនាក់ ក៏ដូចជានិស្សិតទាំងអស់ឱ្យមានចំណេះដឹង ដើម្បីចូលរួមចំណែកកសាងធនធានមនុស្ស និងកសាងប្រទេសជាតិទៅថ្ងៃមុខ។ ជាពិសេស អ្នកគ្រូសាស្ត្រាចារ្យ **ម៉ិច ធីតា** ព្រឹទ្ធបុរសរង និងជាសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀន ព្រមទាំងណែនាំក្រុមយើងខ្ញុំទាំងពីរនាក់ក្នុងការសរសេរអត្ថបទសារណាស្រាវជ្រាវនេះ ដោយបានផ្តល់នូវគំនិត និងវិធីសាស្ត្រស្រាវជ្រាវតាំងពីដើមរហូតបានសម្រេចជាលទ្ធផល។

ជាចុងក្រោយ យើងខ្ញុំ សូមធ្វើការបួងសួង សូមឱ្យអ្នកមានគុណទាំងអស់ ដែលបានរៀបរាប់ខាងលើទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាក់ខានឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរ ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានកិត្តិយសដ៏ថ្លៃថ្លានៅក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងការតាក់តែង និងស្រាវជ្រាវប្រធានបទមួយ នៃសារណាបញ្ចប់ការសិក្សាស្ដីពី "កិច្ចសន្យាក្រុមហ៊ុន" ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

ជាការពិតណាស់ កិច្ចសន្យាក្រុមហ៊ុន ជាសញ្ញាណមួយដែលបង្កើតឱ្យមានការព្រមព្រៀងរវាងបុគ្គលឯកជនក្នុងគោលបំណងមួយ សហការគ្នាដោយដាក់ទ្រព្យធនក្នុងការវិនិយោគ។ យើងខ្ញុំសង្កេតឃើញថា កិច្ចសន្យាក្រុមហ៊ុន ដែលត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ មានសារៈប្រយោជន៍ខ្លាំងណាស់នៅក្នុងជីវភាពរស់នៅ និងការសិក្សាស្រាវជ្រាវ។ កត្តានេះហើយ ដែលជំរុញទឹកចិត្តយើងខ្ញុំឱ្យមានសេចក្ដីក្លាហាន និងមោទនភាពក្នុងការលើកយកប្រធានបទនេះ មកចងក្រងឡើងជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដើម្បីទុកជាស្នាដៃសម្រាប់ខ្លួនឯង និងជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយ ធ្វើការសិក្សាស្រាវជ្រាវផងដែរ។

ក្នុងនាមជានិស្សិត បន្ទាប់ពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យដែលជាលំនៅឋានទីពីររបស់ខ្លួន យើងខ្ញុំគួរតែបន្សល់ទុកអ្វីសម្រាប់ជាស្នាដៃ ក៏ដូចជាអនុស្សាវរីយ៍សម្រាប់សាកលវិទ្យាល័យដែលបានខិតខំផ្ដល់ការអប់រំ និងផ្ដល់កន្លែងសិក្សារយៈពេលបួនឆ្នាំ សម្រាប់យើងខ្ញុំដើម្បីធ្វើជាទុនចំណេះដឹងក្នុងការប្រកបរបរចិញ្ចឹមជីវិតនាពេលអនាគត និងបង្កើនធនធានមនុស្សនៅកម្ពុជាបន្ថែម។ ដូច្នេះ អ្វីដែលសក្តិសមក្នុងការតម្កល់ទុកនោះគឺស្នាដៃសារណានេះហើយ ដែលជាចំណងដៃជូនចំពោះសាកលវិទ្យាល័យ។

យើងខ្ញុំសូមអភ័យទោសផងដែរ នូវរាល់កង្វះខាត និងកំហុសឆ្គងដែលអាចកើតមានឡើងដោយប្រការណាមួយ ហើយយើងខ្ញុំ សូមទទួលយកដោយសេចក្ដីរីករាយនូវមតិកែលម្អក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានដើម្បីបំពេញចំណុចខ្វះខាតដោយប្រការណាមួយ ដើម្បីឱ្យការស្រាវជ្រាវមួយនេះមានភាពល្អប្រសើរឡើង។

# មាតិកា

**សេចក្តីផ្តើម** ........................................................................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន

**ផ្នែកទី១ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន** .................................. ៣
**១.១. និយមន័យ** .................................................................................... ៣
**១.២. សមាជិកក្រុមហ៊ុន** ............................................................................ ៤
**១.៣. ទ្រព្យធនវិនិយោគ** ............................................................................ ៥
**ផ្នែកទី២ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាក្រុមហ៊ុន** .................................. ៦
**២.១. លក្ខខណ្ឌទម្រង់** ............................................................................. ៦
២.១.១. កិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់ ........................................................ ៦
២.១.២. កិច្ចសន្យាធ្វើឡើងជាលាយលក្ខណ៍អក្សរ ............................................... ៧
២.១.២.១. លិខិតឯកជន ............................................................................ ៧
២.១.២.២. លិខិតយថាភូត ......................................................................... ៧
**២.២. លក្ខខណ្ឌគ្រឹះ ឬលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា** .................................... ៨
២.២.១. ការព្រមព្រៀង ................................................................................ ៨
២.២.១.១. សំណើ ...................................................................................... **៩**
២.២.១.២. ស្វីការ ..................................................................................... **១០**
២.២.១.៣. វិការៈ ...................................................................................... **១១**
ក. ការលុបចោល .................................................................................... **១១**
ខ. មោឃភាព ......................................................................................... **១៣**
២.២.២. សមត្ថភាព .................................................................................... **១៤**
២.២.២.១. ជនដែលមានសមត្ថភាព ............................................................... **១៥**
២.២.២.២. ជនដែលត្រូវបានកម្រិតសមត្ថភាព ................................................... **១៦**
ក. អនីតិជន ........................................................................................... **១៦**
ខ. ជននៅក្រោមអាណាព្យាបាលទូទៅ ........................................................ **១៧**
គ. ជននៅក្រោមហិតូបត្ថម្ភ ...................................................................... **១៨**

២.២.៣. កម្មវត្ថុនៃកិច្ចសន្យាក្រុមហ៊ុន ........ ១៩
២.២.៣.១. កម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន........ ២០
២.២.៣.២. កម្មវត្ថុស្របច្បាប់........ ២០

## ជំពូកទី២

## អានុភាព និងការរំលាយនៃកិច្ចសន្យាក្រុមហ៊ុន

**ផ្នែកទី១ អានុភាពនៃកិច្ចសន្យាក្រុមហ៊ុន**........ ២១
**១.១. សិទ្ធិរបស់សមាជិកក្រុមហ៊ុន** ........ ២១
១.១.១. សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និងស្ថានភាពទ្រព្យសម្បត្តិ ........ ២១
១.១.២. សិទ្ធិទាមទារចែកចំណេញភាគនៃការបែងចែកការចំណេញខាត ........ ២៣
១.១.៣. សិទ្ធិអំណាចអនុវត្តកិច្ចការរបស់សមាជិកនៅក្នុងក្រុមហ៊ុន ........ ២៥
១.១.៤. សិទ្ធិក្នុងការជ្រើសតាំងអ្នកតំណាង ........ ២៦
**១.២. ភាតព្វកិច្ចរបស់សមាជិកក្រុមហ៊ុន**........ ២៧
**១.៣. របៀបដកខ្លួន**........ ២៨
១.៣.១. ការដកខ្លួនដោយស្ម័គ្រចិត្ត ........ ២៨
១.៣.២. ការដកខ្លួនតាមច្បាប់ ........ ៣០
**១.៤. ទ្រព្យធនរបស់ក្រុមហ៊ុន**........ ៣២
**ផ្នែកទី២ ការរំលាយកិច្ចសន្យាក្រុមហ៊ុន** ........ ៣៣
**២.១. លក្ខខណ្ឌនៃការរំលាយ** ........ ៣៤
២.១.១. ការបញ្ចប់កម្មវត្ថុរបស់ក្រុមហ៊ុន ឬអលទ្ធភាពក្នុងការបំពេញកិច្ចការ ........ ៣៤
២.១.២. ការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន ........ ៣៥
២.១.៣. សមាជិកក្រុមហ៊ុនតែម្នាក់ ........ ៣៥
២.១.៤. អំឡុងពេលអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់ក្នុងកិច្ចសន្យាក្រុមហ៊ុនត្រូវបានបញ្ចប់ ........ ៣៥
**២.២. អានុភាពនៃការរំលាយកិច្ចសន្យា**........ ៣៦
**២.៣. ការជម្រះបញ្ជី** ........ ៣៧
២.៣.១. អ្នកជម្រះបញ្ជី ........ ៣៧
២.៣.២. មុខងារ និងសិទ្ធិអំណាចអ្នកជម្រះបញ្ជី ........ ៣៧
២.៣.៣. ការលាឈប់ និងការបញ្ឈប់អ្នកជម្រះបញ្ជី........ ៣៨

**សេចក្តីសន្និដ្ឋាន** ............................................................................................... ៣៩
**អនុសាសន៍** ............................................................................................... ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ រមែងកើតមាននូវទំនាក់ទំនង និងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដែលការប្រាស្រ័យទាក់ទងទាំងនោះ មានលក្ខណៈខុសប្លែកពីគ្នាដូចជា៖ ការប្រាស្រ័យទាក់ទងធម្មតាបែបជីវភាពរស់នៅ ការដោះដូរទំនិញ និងការធ្វើអាជីវកម្មទិញលក់ជាដើម។ ក្រោមរូបភាពនៃចំណងទំនាក់ទំនងទាំងនេះ យើងសង្កេតឃើញថា គូភាគីដែលទាក់ទងបានបង្កើតនូវចំណងកិច្ចសន្យារវាងគ្នា និងគ្នាដែលជាបច្ច័យនាំទៅរកការអនុវត្ត។ យ៉ាងណាមិញ កិច្ចសន្យាក៏បានកើតមានរួចបាត់ទៅហើយតាមរយៈពាក្យសម្តី និងការសន្យាដោយផ្ទាល់មាត់របស់ពួកគេ។ ទម្រង់នៃកិច្ចសន្យាមានពីរប្រភេទគឺ កិច្ចសន្យាផ្ទាល់មាត់ និងកិច្ចសន្យាទម្រង់ជាលាយលក្ខណ៍អក្សរ។ ដោយឡែក កិច្ចសន្យាមានទម្រង់ជាលាយលក្ខណ៍អក្សរមានលក្ខណៈពិសេសមួយខុសពីកិច្ចសន្យាផ្ទាល់មាត់ត្រង់ថា វាគឺជាភស្តុតាងជាក់លាក់មួយ ក្នុងការតតាំងចំពោះមុខតុលាការនៅពេលមានវិវាទកើតឡើង។ ក្នុងនោះផងដែរ កិច្ចសន្យាបង្កើតឡើងដើម្បីធ្វើឱ្យជំនឿទុកចិត្តរបស់គូភាគីកាន់តែមានភាពរឹងមាំ។ បច្ចុប្បន្ន នៅក្នុងការប្រកបរបរចិញ្ចឹមជីវិត ដើម្បីធ្វើឱ្យសេដ្ឋកិច្ចក្នុងគ្រួសារកាន់តែមានភាពល្អប្រសើរឡើង បុគ្គលដែលជាគូភាគីបានព្រមព្រៀងគ្នាចូលរួមបង្កើតកិច្ចសន្យា ដែលបម្រើផលប្រយោជន៍ និងផ្តល់ភាពជឿជាក់រវាងគ្នា និងគ្នាដើម្បីសម្រេចគោលដៅនៃឆន្ទៈរួមមួយ។ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ មានកិច្ចសន្យាមួយក្នុងចំណោមកិច្ចសន្យាជាច្រើនដែលមានលក្ខណៈសេដ្ឋកិច្ចខ្ពស់ជាងគេ គឺកិច្ចសន្យាក្រុមហ៊ុន។ យើងសង្កេតឃើញថា កិច្ចសន្យាប្រភេទនេះ មានលក្ខណៈងាយស្រួលក្នុងការបង្កើត ហើយវាជាឧបករណ៍គតិយុត្តមួយដែលជួយការពារផលប្រយោជន៍របស់គូភាគី។ បន្ថែមពីលើនេះទៀត កិច្ចសន្យានេះក៏បានកំណត់ពីលក្ខខណ្ឌផ្សេងៗមួយចំនួន ដែលមានអានុភាពគតិយុត្ត និងបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីដើម្បីការពារផលប្រយោជន៍របស់គូភាគី ទាំងនៅក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា និងក្រោយពេលរំលាយកិច្ចសន្យា។ ស្របពេលដែលមានគុណសម្បត្តិជាច្រើនកើតឡើង ក្នុងការបង្កើតកិច្ចសន្យាវាក៏មានគុណវិបត្តិមួយចំនួនអាចនឹងត្រូវកើតឡើងផងដែរ។ ក្នុងនោះ "កិច្ចសន្យាក្រុមហ៊ុន" នេះមិនមែនជាការបែងចែកប្រភេទក្រុមហ៊ុនដូចមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មទេ ដោយសារវាគ្រាន់តែជា ដំណាក់កាលបឋមដែលនាំឱ្យមានការបង្កើតក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា ក្នុងបរិបទក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

១. តើកិច្ចសន្យាក្រុមហ៊ុន មានអត្ថន័យយ៉ាងដូចម្តេច?

២. តើការបង្កើតក្រុមហ៊ុនស្ថិតនៅក្រោមកិច្ចសន្យាក្រុមហ៊ុន ក្នុងបរិបទនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចាំបាច់ត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

៣.តើអានុភាព និងការរំលាយនៃកិច្ចសន្យាក្រុមហ៊ុន មានលក្ខណៈដូចម្ដេចខ្លះ?

គោលបំណងក្នុងការស្រាវជ្រាវនេះ គឺនឹងធ្វើការពន្យល់អំពីកិច្ចសន្យាក្រុមហ៊ុនដែលស្ថិតនៅក្នុងបរិបទក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ នៅក្នុងនោះផងដែរ ក៏មានការបកស្រាយពីកម្មវត្ថុដែលចាំបាច់សម្រាប់គូភាគី(សមាជិកក្រុមហ៊ុន) និងចំណុចមួយចំនួនដែលទាក់ទងទៅនឹងលំហូរនៃការបង្កើតរហូតដល់ការរំលាយកិច្ចសន្យាក្រុមហ៊ុន។

វិសាលភាពនៃប្រធានបទខាងលើ គឺផ្ដោតសំខាន់ទៅលើកិច្ចសន្យាក្រុមហ៊ុនដែលស្ថិតក្រោមបរិបទក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ប៉ុណ្ណោះ ទន្ទឹមនឹងនេះ បុគ្គលភាគច្រើនគិតថាការបង្កើតកិច្ចសន្យាក្រុមហ៊ុន ជាការបែងចែកប្រភេទក្រុមហ៊ុនដូចមានចែងនៅក្នុងច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។

ដើម្បីស្រាយបំភ្លឺចំណោទគតិយុត្តខាងលើ ក្នុងដំណាក់កាលនៃការបង្កើតក្រុមហ៊ុន ក្នុងបរិបទក្រមរដ្ឋប្បវេណីរួមមាន៖ (ជំពូកទី១) សញ្ញាណទូទៅនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន និង (ជំពូកទី២) អានុភាព និងការរំលាយនៃកិច្ចសន្យាក្រុមហ៊ុនដែលស្ដែងឡើងពីការបង្កើតក្រុមហ៊ុនតាមរយៈកិច្ចសន្យាក្រុមហ៊ុននេះ។

# ជំពូកទី ១
# សញ្ញាណទូទៅនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច[1]។ កិច្ចសន្យា ត្រូវបានចែកចេញជាពីរទស្សនៈ ទីមួយគឺ កិច្ចសន្យាត្រូវគ្នាទៅនឹងឆន្ទៈរបស់ភាគី ដែលចង់បង្កើតកិច្ចសន្យាដែលស្របច្បាប់ និងទីពីរ ការបង្កើតកិច្ចសន្យាជាឆន្ទៈរបស់ភាគីដែលចង់បង្កើត កែប្រែ និងរំលត់កាតព្វកិច្ចតែប៉ុណ្ណោះ។ កិច្ចសន្យាទាំងអស់ សុទ្ធសឹងតែមានលក្ខណៈដូចគ្នាទាំងអស់ មិនថាកិច្ចសន្យាណាក៏ដោយ។ ជាទូទៅ ប្រជាពលរដ្ឋមួយចំនួនតែងយល់ថាកិច្ចសន្យា គ្រាន់តែជាការព្រមព្រៀងគ្នារវាងបុគ្គល និងបុគ្គលដែលអាចបង្កើតឱ្យមាន កិច្ចសន្យាបាន។ ចំពោះមតិមួយចំនួនទៀតយល់ថា ការបង្កើតកិច្ចសន្យាដែលមានប្រសិទ្ធិភាព លុះត្រាតែកិច្ចសន្យា នោះបង្កើតឡើងជាលាយលក្ខណ៍អក្សរ និងមានសាក្សីដឹងលឺផងដែរ។ ដោយឡែក កិច្ចសន្យាក្រុមហ៊ុនដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ពុំបានចែងច្បាស់លាស់ថា កិច្ចសន្យា ត្រូវតែជាលាយលក្ខណ៍អក្សរ ឬក៏គ្រាន់តែជាការព្រមព្រៀងគ្នាដោយផ្ទាល់មាត់ឡើយ។ ជាក់ស្តែង កិច្ចសន្យាក្រុមហ៊ុន បានបែងចែកជា២ផ្នែកដែលនាំឲ្យកិច្ចសន្យាត្រូវបានបង្កើតឡើង និងមានសុពលភាព គឺ**លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន** និង**លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាក្រុមហ៊ុន**។

## ផ្នែកទី១ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន

គោលការណ៍មួយដែលកិច្ចសន្យា អាចកើតឡើងបានតាមរយៈលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាដូចគ្នាផងដែរ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន បានបកស្រាយពី (១) និយមន័យ (២)សមាជិកក្រុមហ៊ុន និង(៣) ទ្រព្យធនវិនិយោគ។

### ១.១. និយមន័យ

កិច្ចសន្យាក្រុមហ៊ុន សំដៅទៅលើកិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការដោយសហការគ្នា ដោយភាគីនីមួយៗ ធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន[2]។ បានសេចក្តីថា កិច្ចសន្យាក្រុមហ៊ុន ជាកិច្ចសន្យាបង្កើតជាក្រុមក្នុងទិសដៅណាមួយហើយចំណុចនេះ បង្ហាញថា អាចបង្កើតក្រុមហ៊ុនតាមរយៈកិច្ចសន្យាក្រុមហ៊ុន។ យ៉ាងណាមិញ កិច្ចសន្យាក្រុមហ៊ុន ចាំបាច់ត្រូវមានការវិនិយោគទ្រព្យធនរៀងៗខ្លួន និងកិច្ចព្រមព្រៀងដែលត្រូវបានធ្វើឡើង

[1] មាត្រា៣១១ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[2] មាត្រា៦៩៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ដោយសហការគ្នា ហើយលក្ខណៈពិសេសរបស់ក្រុមហ៊ុន គឺជាក្រុមដែលពុំមានលក្ខណៈជានីតិបុគ្គលឡើយ។ ដោយឡែក ក្រុមហ៊ុនដែលបង្កើតឡើងដោយកិច្ចសន្យាក្រុមហ៊ុន គឺជាក្រុមដែលបានបង្កើត ដោយការសន្យា ដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា[3]។ ក្នុងន័យនេះ ក្រុមហ៊ុនជាការកកើតឡើងចេញពី ការបង្កើតកិច្ចសន្យាក្រុមហ៊ុន និងមានការព្រមព្រៀងគ្នាក្នុងការវិនិយោគទ្រព្យធនដោយភាគីនៃកិច្ចសន្យា។

ជាទម្លាប់ពីមុនមក ដោយយោងតាមមាត្រា១២៨៧ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០ (ក្រមរដ្ឋប្បវេណីកម្ពុជាចាស់) បានបញ្ញត្តិថា កិច្ចសន្យាក្រុមហ៊ុន គឺជាកិច្ចសន្យាទាំងឡាយព្រមព្រៀងគ្នាយកធនធានរបស់ខ្លួនទៅដាក់រួមគ្នាក្នុងគោលបំណងណាមួយដើម្បីនឹងចែកចំណេញ ឬខាតគ្នាដែលអាចកើតចេញពីការបង្កើតនេះ។ មានន័យថា កិច្ចសន្យាក្រុមហ៊ុនដែលមានចែងក្នុងក្រមរដ្ឋប្បវេណីចាស់នេះ ក៏ជាការបង្កើតក្រុមហ៊ុនទៅតាមចំណែកទ្រព្យធនរបស់ភាគី ដែលព្រមព្រៀងបង្កើតកិច្ចសន្យា ក្នុងគោលបំណងណាមួយដើម្បីផលប្រយោជន៍រួម ប្រហាក់ប្រហែលទៅនឹងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ (ក្រមរដ្ឋប្បវេណីថ្មី) ដែរ។ តាមការលើកឡើងខាងលើ គ្រាន់តែជាការលើកឡើងពីកិច្ចសន្យាក្រុមហ៊ុននៅអតីតកាល បើក្រឡេកមើលនៅពេលបច្ចុប្បន្នវិញកិច្ចសន្យាក្រុមហ៊ុនដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ច្បាស់លាស់ថាក្រុមហ៊ុននេះមិនមែនជានីតិបុគ្គលទេ។

លើសពីនេះទៅទៀត នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានបញ្ជាក់ឱ្យបានច្បាស់លាស់នូវមូលដ្ឋានគ្រឹះក្នុងការបង្កើតក្រុមហ៊ុនឡើយ។ ជាពិសេសការបង្កើតក្រុមហ៊ុនមិនតម្រូវឱ្យមានការចុះបញ្ជីនោះទេ ដោយហេតុថាក្រុមហ៊ុនពុំមានលក្ខណៈជា នីតិបុគ្គលដែលច្បាប់តម្រូវឱ្យមានការចុះបញ្ជីនោះទេ។

ឧទាហរណ៍៖ ភារិទ្ធ និងចំរុង បានចូលទុនគ្នាបើកហាងកាត់សក់មួយកន្លែង។ ដូច្នេះកិច្ចសន្យារវាងភារិទ្ធនិងចំរុងដែលព្រមព្រៀងគ្នាដើម្បីបើកហាងកាត់សក់នោះ គឺជាកិច្ចសន្យាក្រុមហ៊ុន។

### ១.២. សមាជិកក្រុមហ៊ុន

ក្រុមហ៊ុន គឺជាក្រុមដែលបង្កើតដោយការសន្យា ដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា[4]។ មានន័យថា កិច្ចសន្យាក្រុមហ៊ុន អាចបង្កើតឡើងបានលុះត្រាតែមានការព្រមព្រៀងពីភាគីនៃកិច្ចសន្យា ទើបអាចបង្កើតជាកិច្ចសន្យាក្រុមហ៊ុនបាន។ ក្នុង

[3] កថាខណ្ឌទី១ មាត្រា៧០០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[4] កថាខណ្ឌទី១ មាត្រា៧០០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ចំណុចនេះ ភាគីសំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាសមាជិកក្រុមហ៊ុននៅក្នុងក្រុមហ៊ុន ដែលបានបង្កើតឡើងតាមរយៈកិច្ចសន្យាក្រុមហ៊ុន។ ជាក់ស្តែង ការបង្កើតកិច្ចសន្យាក្រុមហ៊ុនត្រូវមានភាគីចាប់ពី២រូបឡើងទៅ ទើបអាចធ្វើការបង្កើតកិច្ចសន្យាបាន។

សមាជិកក្រុមហ៊ុន គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានព្រមព្រៀងគ្នាដាក់ទ្រព្យធន សិទ្ធិលើទ្រព្យសម្បត្តិ និងពលកម្មដើម្បីវិនិយោគ ក្នុងទិសដៅស្វែងរកចំណេញ ជាមួយភាគីម្ខាងទៀត ក្នុងការបង្កើតក្រុមហ៊ុន ដែលអាចនិយាយបានថាសមាជិកក្រុមហ៊ុន ជាភាគីនៃកិច្ចសន្យាក្រុមហ៊ុន។

### ១.៣. ទ្រព្យធនវិនិយោគ

គោលការណ៍ទូទៅ ក្នុងការបង្កើតកិច្ចសន្យាក្រុមហ៊ុនចាំបាច់ត្រូវមានទ្រព្យធន។ ទ្រព្យធនដែលភាគីនីមួយៗត្រូវវិនិយោគ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ក្រៅពីសិទ្ធិលើទ្រព្យសម្បត្តិអាចយកពលកម្មមកធ្វើជាកម្មវត្ថុបាន[5]។ ទ្រព្យធនវិនិយោគក្នុងកិច្ចសន្យាក្រុមហ៊ុនមិនបានកំណត់តែទៅលើទ្រព្យសម្បត្តិរបស់ភាគីនោះទេ តែពលកម្ម ក៏អាចក្លាយទៅជាកម្មវត្ថុនៃការវិនិយោគទ្រព្យធនដែរ។ លើសពីនេះ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានផ្តោតសំខាន់តែទៅលើទំនុកចិត្ត និងការវិនិយោគទ្រព្យធនរបស់ខ្លួនតែប៉ុណ្ណោះ ដូច្នេះហើយទ្រព្យធនវិនិយោគ គឺអាស្រ័យលើការព្រមព្រៀងរបស់គូភាគីដែលបានកំណត់នៅក្នុងកិច្ចសន្យា។

ផ្ទុយមកវិញ ទោះបីជាកិច្ចសន្យា ត្រូវបានព្រមព្រៀងពីគូភាគីក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិ លើអចលនវត្ថុ នឹងមានអានុភាពបានលុះត្រាតែបានធ្វើលិខិតយថាភូត[6]។ បានន័យថា លិខិតយថាភូតចាំបាច់សម្រាប់ការបង្កើតកិច្ចសន្យាក្រុមហ៊ុន ចំពោះករណីដែលភាគីយកកម្មសិទ្ធិលើអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃការវិនិយោគ ទ្រព្យធន។

នៅពេលដែលភាគីយកប្រាក់ធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន បើមានការយឺតយ៉ាវក្នុងការបង់ប្រាក់ ភាគីត្រូវបង់ប្រាក់លើការយឺតយ៉ាវនោះ រួមទាំងបង់ប្រាក់លើការខូតខាតដែលបណ្តាលមកពីការយឺតយ៉ាវនោះផងដែរ[7]។ ដូច្នេះ បញ្ញត្តិនេះបានឆ្លុះបញ្ចាំងពីការទទួលខុសត្រូវរបស់ភាគីចំពោះការយឺតយ៉ាវរបស់ខ្លួនក្នុងការបង់ប្រាក់តាមពេលវេលាកំណត់ ដែលភាគីយកមកធ្វើជាកម្មវត្ថុវិនិយោគ។

[5] កថាខណ្ឌទី២ មាត្រា៧០០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[6] កថាខណ្ឌទី២ មាត្រា៣៣៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[7] កថាខណ្ឌទី៣ មាត្រា៧០០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

## ផ្នែកទី២ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាក្រុមហ៊ុន

លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា មានសារៈសំខាន់ដើម្បីឱ្យកិច្ចសន្យាមួយអាចអនុវត្តទៅបាន។ រាល់កិច្ចសន្យាដែលបានបង្កើត ត្រូវមានលក្ខខណ្ឌមួយចំនួន ទើបការបង្កើតកិច្ចសន្យាអាចធ្វើទៅបាន ដែលកិច្ចសន្យាក្រុមហ៊ុនក៏ជាកិច្ចសន្យាមួយ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីផងដែរ។ ហេតុនេះ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាក្រុមហ៊ុន បែងចែកជា២រួមមាន៖ (១) លក្ខខណ្ឌទម្រង់ និង(២) លក្ខខណ្ឌគ្រឹះ ឬ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា។ លើសពីនេះនៅក្នុងលក្ខខណ្ឌនីមួយៗ បានបង្ហាញពីតម្រូវការចាំបាច់ ដែលគូភាគីអាចបង្កើតកិច្ចសន្យាឡើង និងមានសុពលភាពបាន។

### ២.១. លក្ខខណ្ឌទម្រង់

គ្រប់កិច្ចសន្យាទាំងអស់ ចាំបាច់ត្រូវមានលក្ខខណ្ឌទម្រង់។ កិច្ចសន្យាមួយអាចធ្វើឡើងដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ។ ប៉ុន្តែកិច្ចសន្យាទាំងអស់ មិនមែនសុទ្ធតែមានសុពលភាពនោះទេព្រោះកិច្ចសន្យាមួយចំនួន ច្បាប់បានតម្រូវឱ្យធ្វើឡើងជាលាយលក្ខណ៍អក្សរ ទើបកិច្ចសន្យាអាចមានសុពលភាពគតិយុត្ត។ ដោយឡែក កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត[8]។

ក្រុមហ៊ុន ជាក្រុមមួយដែលបានបង្កើតឡើងដោយការសន្យា ដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា[9]។ ចំពោះកិច្ចសន្យាក្រុមហ៊ុន ពុំបានកំណត់ជាក់លាក់ លើទម្រង់នៃការបង្កើតកិច្ចសន្យានោះទេ ដូចនេះកិច្ចសន្យាក្រុមហ៊ុនអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។

#### ២.១.១. កិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់

កិច្ចសន្យាផ្ទាល់មាត់ ជាលិខិតឥតសរសេរ ដោយមិនមានការសរសេរព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរនោះទេ មានតែការនិយាយព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ។ តម្រូវការប្រចាំថ្ងៃ អាចមានលក្ខណៈស្មុគស្មាញសម្រាប់ភាគីនៃកិច្ចសន្យា ដោយការធ្វើជាលិខិតស្នាមដែលមានការដឹងឮពីអ្នកច្បាប់លើសកម្មភាពតូចតាចមួយចំនួន ព្រោះទម្រង់នៃកិច្ចសន្យានោះ មានភាពងាយស្រួល និងឆាប់រហ័សក្នុងការអនុវត្ត។ តែដោយឡែក វានឹងមានភាពលំបាកនៅពេលដែលមានវិវាទកើតឡើង បើកិច្ចសន្យា ធ្វើឡើងដោយផ្ទាល់មាត់មិនអាចបញ្ជាក់ថា កិច្ចសន្យាត្រូវបានបង្កើតឡើង និងព្រមព្រៀងគ្នាយ៉ាងដូចម្តេចខ្លះ។

[8] កថាខណ្ឌទី២ មាត្រា៣៣៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[9] កថាខណ្ឌទី១ មាត្រា៧០០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ជាពិសេស កិច្ចសន្យាក្រុមហ៊ុនអាចធ្វើឡើងដោយផ្ទាល់មាត់បាន គ្រាន់តែកិច្ចសន្យានេះ មិនមានអានុភាពពេញលេញតាមផ្លូវច្បាប់ ដោយសារការព្រមព្រៀងរបស់គូភាគីពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យធនក្នុងការវិនិយោគមិនមានបញ្ជាក់ជាលាយលក្ខណ៍អក្សរ ជាហេតុធ្វើឱ្យមានបញ្ហាលំបាកខ្លាំង នៅពេលមានវិវាទកើតឡើងរវាងសមាជិកក្រុមហ៊ុន ដូចនេះហើយកិច្ចសន្យាក្រុមហ៊ុន គួរធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

### ២.១.២. កិច្ចសន្យាធ្វើឡើងជាលាយលក្ខណ៍អក្សរ

ទិដ្ឋភាពបច្ចុប្បន្ន កិច្ចសន្យាដែលធ្វើឡើងជាលាយលក្ខណ៍អក្សរមានការនិយមជាងកិច្ចសន្យាដែលធ្វើឡើងដោយផ្ទាល់មាត់ ហេតុនេះហើយ កិច្ចសន្យាភាគច្រើនធ្វើឡើងជាលិខិតសរសេរ ឬជាលាយលក្ខណ៍អក្សរ។ ក្នុងនោះ កិច្ចសន្យាក្រុមហ៊ុនគឺដូចកិច្ចសន្យាទូទៅដែរ ដែលត្រូវបានសរសេរឡើងដោយគូភាគីនៃកិច្ចសន្យា ហើយក៏មានរំលេចពីកាលបរិច្ឆេទ ស្នាមមេដៃ រួមទាំងកម្មវត្ថុនៃកិច្ចសន្យាជាដើម។ កិច្ចសន្យាក្រុមហ៊ុននេះ ធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរមាន ២ ប្រភេទគឺ៖ លិខិតឯកជន និងលិខិតយថាភូត។

#### ២.១.២.១. លិខិតឯកជន

លិខិតឯកជន ជាលិខិតដែលធ្វើឡើងដោយពុំមានមន្ត្រីរាជការសាធារណៈណាមួយជួយដឹងឮ និងឃើញនោះទេមានតែហត្ថលេខានៃគូភាគីតែប៉ុណ្ណោះ។ ជាពិសេស លិខិតឯកជនជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ[10]។ ដូចនេះ កិច្ចសន្យាដែលធ្វើឡើងក្នុងទម្រង់ជាលិខិតឯកជន គឺជាកិច្ចសន្យាដែលធ្វើឡើងដោយការព្រមព្រៀងកិច្ចការណាមួយ ដើម្បីបង្កើតឱ្យមានលក្ខណៈគតិយុត្តតាមផ្លូវច្បាប់។

បានសេចក្ដីថា កិច្ចសន្យាក្រុមហ៊ុនដូចទៅនឹងកិច្ចសន្យាទូទៅដែរ នៅពេលដែលសមាជិកក្រុមហ៊ុនបានព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យា គឺត្រូវធ្វើឡើងរវាងសមាជិកក្រុមហ៊ុនទាំងអស់ក្នុងទម្រង់លិខិតឯកជនដោយមិនមានការចូលរួមពីសារការី។ ការបង្កើតកិច្ចសន្យាក្រុមហ៊ុនតាមរយៈលិខិតនេះ ងាយស្រួលក្នុងការបង្កើត និងការរំលាយ។

#### ២.១.២.២. លិខិតយថាភូត

ថ្វីបើលិខិតឯកជនដែលបានធ្វើឡើង ស្របតាមលក្ខខណ្ឌគតិយុត្តដែលមានភាពត្រឹមត្រូវអាចជឿជាក់បានក៏ពិតមែន ប៉ុន្តែវាមានតម្លៃគតិយុត្តទាបជាងលិខិតយថាភូត។ លិខិតយថាភូតជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសារធារណៈដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារ

[10] សន្ទានុក្រមផ្នែករដ្ឋប្បវេណី (អនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្ដីការរដ្ឋមន្ត្រី ឆ្នាំ២០០៧)

នេះហើយតាមន័យចង្អៀត វាក៏ជាលិខិតទាំងឡាយណាដែលរៀបចំឡើងដោយសារការី[11]។ តាមន័យនេះ លិខិតយថាភូតសំខាន់បំផុតសម្រាប់ភាគីក្នុងកិច្ចសន្យាដោយសារទម្រង់នេះមានលក្ខណៈរឹងមាំ និងមានការចុះបញ្ជីដោយបុគ្គលដែលមានសមត្ថកិច្ច និងច្បាប់។

ម្យ៉ាងទៀត មាត្រា៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បានកំណត់ផងដែរនូវអត្ថន័យនៃលិខិតយថាភូត ជាលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬលិខិតឯកជន ដោយសារការីចុះនិទ្ទេសថាលិខិតនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមផ្លូវច្បាប់។ ជាគោលការណ៍ កិច្ចសន្យាក្រុមហ៊ុនដែលធ្វើឡើងក្នុងទម្រង់លិខិតយថាភូត មានការការពារដោយច្បាប់រវាងសមាជិកក្រុមហ៊ុនទាំងអស់ដែលបានវិនិយោគទ្រព្យធនរបស់ខ្លួន ហើយនៅពេលដែលមានវិវាទលិខិតនេះជាភស្តុតាងចាំបាច់សម្រាប់ការតតាំងក្តី។

លើសពីនេះទៅទៀត លិខិតយថាភូតចាំបាច់បំផុត ចំពោះករណីដែល សមាជិកក្រុមហ៊ុនយកកម្មសិទ្ធិលើអចលនវត្ថុមកធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន[12]។ មានន័យថា នៅពេលដែលសមាជិកក្រុមហ៊ុនយកកម្មសិទ្ធិទៅលើអចលនវត្ថុមកធ្វើជាទ្រព្យវិនិយោគ កិច្ចសន្យានេះត្រូវតែជាប្រភេទលិខិតយថាភូត ហេតុនេះងាយស្រួលនៅពេលមានការធ្វើអនុប្បទាននូវកម្មសិទ្ធិ។

### ២.២. លក្ខខណ្ឌគ្រឹះ ឬលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា

លក្ខខណ្ឌគ្រឹះ ឬលក្ខខណ្ឌសុពលភាពក្នុងការបង្កើតកិច្ចសន្យាជាគោលការណ៍ដែលទាក់ទងទៅនឹងភាគី ហើយកិច្ចសន្យាដែលបានបង្កើតឡើង មិនមែនសុទ្ធតែមានសុពលភាពនោះទេ។ ដើម្បីឱ្យកិច្ចសន្យាមួយមានសុពលភាពបាន លុះត្រាតែកិច្ចសន្យានោះបានបង្កើតឡើងដោយមានការព្រមព្រៀង សមត្ថភាព និងមានកម្មវត្ថុនៃកិច្ចសន្យា។ ជារួម កិច្ចសន្យាក្រុមហ៊ុន ក៏ជាកិច្ចសន្យាមួយប្រភេទដែលទាមទារឱ្យមានការព្រមព្រៀង សមត្ថភាព និងកម្មវត្ថុទើបកិច្ចសន្យាក្រុមហ៊ុន អាចបង្កើតឡើងបាន។ ជាពិសេស ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងពីវិការៈក្នុងការបង្ហាញឆន្ទៈ និងលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាចាប់ពីមាត្រា ៣៤៥ រហូតដល់មាត្រា ៣៥៥។

#### ២.២.១. ការព្រមព្រៀង

ដំណាក់កាលដំបូងមុននឹងឈានដល់ការបង្កើតកិច្ចសន្យា គឺត្រូវមានការព្រមព្រៀងពីគូភាគីនៃកិច្ចសន្យាដែលការព្រមព្រៀង គឺជាការសម្តែងឆន្ទៈយល់ព្រមរបស់ភាគីនីមួយៗ ដើម្បីបង្ហាញ

[11] សន្ទានុក្រមផ្នែករដ្ឋប្បវេណី (អនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការរដ្ឋមន្ត្រី ឆ្នាំ២០០៧)

[12] កថាខណ្ឌទី១ មាត្រា៧០០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០ ភាគ៣: គន្លឹះទី៥

គោលបំណងពិតប្រាកដក្នុងការបង្កើតកិច្ចសន្យា[13]។ ការព្រមព្រៀង អាចកើតឡើងបានដោយសារភាគីម្ខាងបានធ្វើសំណើ និងភាគីម្ខាងទៀតបានទទួល និងតបសំណើដែលហៅថា ស្វីការ។ ក្នុងនោះការព្រមព្រៀងត្រូវធ្វើឡើងដោយសេរី ពិតប្រាកដ គ្មានការបន្លំបោកប្រាស់ និងពុំមានការបង្ខិតបង្ខំពីបុគ្គលណាមួយដែលមានផលប្រយោជន៍ទាក់ទងនៅក្នុងកិច្ចសន្យា។ ការព្រមព្រៀងមិនត្រូវមានការគាបសង្កត់លើរូបរាងកាយ ឬខាងផ្នែកសេដ្ឋកិច្ច ឬប្រើប្រាស់ឥទ្ធិពលបង្ក្រាបដោយមានការគំរាមកំហែងពីភាគីម្ខាងទៀត។ បានសេចក្តីថា នៅក្នុងការបង្កើតកិច្ចសន្យាក្រុមហ៊ុន ត្រូវមានការព្រមព្រៀងពីអ្នកវិនិយោគទ្រព្យធន ដែលជាសមាជិកក្រុមហ៊ុន ដោយមិនមានការបន្លំបោកប្រាស់ដោយការឆបោក ភូតភរ ដើម្បីឱ្យភាគីជឿទុកចិត្តហើយព្រមព្រៀង និងយល់ព្រមចុះកិច្ចសន្យាជាមួយខ្លួនដូចនេះវាបណ្តាលឱ្យមានការលុបចោលកិច្ចសន្យាកើតឡើងបាន។

**២.២.១.១ សំណើ**

សំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ[14]។ ដូចនេះ គេឱ្យនិយមន័យសំណើថាជាការស្នើបង្កើតកិច្ចសន្យាមួយរវាងបុគ្គលម្នាក់ទៅនឹងបុគ្គលម្នាក់ទៀត។ សំណើដែលបានស្នើអាចជាសំណើជាក់លាក់ និងប្រាកដប្រជា គឺត្រូវធ្វើឡើងតាមរយៈការសរសេរលិខិតជាលាយលក្ខណ៍អក្សរ ឬជាពាក្យសំដី ហើយត្រូវតែមានការបង្ហាញឱ្យបានច្បាស់លាស់ថា អ្នកស្នើ មានឆន្ទៈប្រាកដប្រជា ដើម្បីចុះកិច្ចសន្យា។ម្យ៉ាងទៀត សំណើ ត្រូវបង្ហាញពីគោលបំណងយ៉ាងរឹងមាំរបស់អ្នកផ្តល់សំណើ ក្នុងការធ្វើអ្វីមួយតាមការព្រមព្រៀង ដែលបានភ្ជាប់ដោយកាតព្វកិច្ចតាមផ្លូវច្បាប់។

អានុភាពរបស់សំណើ កើតឡើងនៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត[15] ដោយអនុលោមតាមគោលការណ៍ទាក់ទងនឹងរយៈពេលដែលការបង្ហាញឆន្ទៈមានអានុភាព។ ប៉ុន្តែ អានុភាព ត្រូវបាត់បង់ទៅវិញ នៅពេលដែលដំណឹងអំពីការដកសំណើវិញ បានដល់ភាគីម្ខាងទៀតនៅក្នុងពេលជាមួយគ្នា និងពេលសំណើដល់ ឬមុនពេលសំណើដល់។ សំណើ ក៏មានបែបបទមួយចំនួនរួមមាន សំណើដែលមានកំណត់អំឡុងពេល និងគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ។

---

[13] សៀវភៅ«នីតិកិច្ចសន្យា»ជិន វណ្ណារ៉ា បោះពុម្ពឆ្នាំ២០១៣

[14] កថាខណ្ឌទី១ មាត្រា៣៣៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[15] កថាខណ្ឌទី២ មាត្រា៣៣៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

- សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ គឺសំណើនោះ អាចកើតឡើងពេលដែលមានការកំណត់រយៈពេលមួយសម្រាប់ស្វីការ ហើយអំឡុងពេលសម្រាប់សំណើត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេងៗ លើសពីនេះ សំណើនឹងបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នៅពេលផុតអំឡុងពេលសម្រាប់ស្វីការ[16]។
- ចំពោះសំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ ត្រូវបាត់បង់អានុភាពពេលគូភាគីទទួលសំណើមិនយល់ព្រមភ្លាមៗ ក្នុងស្ថានភាពដែលគូភាគី កំពុងនិយាយគ្នា ហើយអាចឆ្លើយតបភ្លាមៗបាន។ អ្នកស្នើ មិនអាចដកសំណើវិញក្នុងអំឡុងពេលសមរម្យបានទេ បើគូភាគីមិនបាននិយាយគ្នា។ ដោយឡែក បើការជូនដំណឹងពីការដកនោះបាន ទៅដល់ភាគីម្ខាងទៀតមុនពេល ដែលភាគីនោះជូនដំណឹងពីស្វីការទើបការដកសំណើរមានអានុភាព[17]។

### ២.២.១.២. ស្វីការ

ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ[18]។ មានន័យថា ស្វីការជាការសំដែងឆន្ទៈ ដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួន ចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។ ស្វីការ អាចជាអំពើដែលកើតឡើងដោយអ្នកទទួលសំណើ ដែលឆ្លុះបញ្ចាំងពីគោលបំណងរបស់អ្នកទទួលសំណើ ក្នុងកិច្ចព្រមព្រៀងជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលផ្អែកលើរាល់លក្ខខណ្ឌសំណើដែលបានទទួល។ ជារួម ច្បាប់ពុំបានកំណត់ច្បាស់លាស់លើអត្ថន័យនៃស្វីការនោះទេ វាអាស្រ័យទៅតាមយុត្តិសាស្ត្រនាពេលបច្ចុប្បន្ន ដោយសកម្មភាពដែលត្រូវបានទទួលស្គាល់ថាជាស្វីការ ក៏ធ្វើឱ្យកិច្ចសន្យាអាចកើតឡើងបានដែរ។

អានុភាពនៃស្វីការ មាននៅពេលដែលស្វីការនោះបានដល់អ្នកស្នើ[19]។ នៅពេលដែលពុំមានការជំទាស់លើសំណើដែលអ្នកស្នើដាក់មក ការបង្ហាញឆន្ទៈស្វីការនេះ ជាការយល់ព្រមដោយ គ្មានលក្ខខណ្ឌ។ ដោយឡែក ប្រសិនបើមានការប្រឆាំង ឬជំទាស់លើសំណើនោះ ហើយអ្នកធ្វើស្វីការបានដាក់លក្ខខណ្ឌ ឬកែប្រែសារធាតុសំណើនាំឱ្យស្វីការមិនមានសុពលភាពទេ តែវានឹងមានអានុភាពជាសំណើថ្មី[20]។ ករណីដែលមានការជូនដំណឹងអំពីការដកស្វីការវិញ គឺមានលក្ខណៈដូចសំណើដែរ។ សរុបមក កិច្ចសន្យាត្រូវកើតឡើងពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ។

---

[16] មាត្រា៣៣៨ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[17] មាត្រា៣៣៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[18] កថាខណ្ឌទី៣ មាត្រា៣៣៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[19] កថាខណ្ឌទី៤ មាត្រា៣៣៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[20] វាក្យខណ្ឌទី១ កថាខណ្ឌទី១ មាត្រា៣៤២ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

**២.២.១.៣. វិការៈ**

កិច្ចសន្យាក្រុមហ៊ុន មិនអាចមានសុពលភាពបាននោះទេ ប្រសិនបើការព្រមព្រៀងរបស់ភាគីមានវិការៈ ដើម្បីអាចបង្កើតក្រុមហ៊ុននោះលុះត្រាតែភាគីបានព្រមព្រៀង មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្ហាញឆន្ទៈ និងកម្មវត្ថុនៃកិច្ចសន្យាមិនផ្ទុយនឹងច្បាប់។ ក្នុងករណី ដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយ ក្នុងចំណោមភាគីដែលបានព្រមព្រៀងបង្កើតក្រុមហ៊ុនក្លាយទៅជាមោឃៈ ឬត្រូវបានលុបចោលនៅពេលដែលការបង្កើតនោះមានវិការៈ។

**ក. ការលុបចោល**

បើការព្រមព្រៀង ដែលបានបង្កើតឡើងដោយមានការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ការរំលោភបំពានលើស្ថានភាព ការបង្ហាញព័ត៌មានមិនពិតទៅភាគីម្ខាងទៀត រួមទាំងការបង្ហាញឆន្ទៈដែលធ្វើឡើងដោយអំពើឆ្លៀតឱកាស ក្នុងគោលបំណងកេងយកចំណេញហួសហេតុកិច្ចសន្យាត្រូវលុបចោល។

- **ការភាន់ច្រឡំ**

ការភាន់ច្រឡំ គឺជាការយល់ខុសនូវព័ត៌មានដែលវាមិនមែនជាការពិត។ បានន័យថាការភាន់ច្រឡំនៅក្នុងកិច្ចសន្យា គឺភាគីណាម្ខាងបានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យា នៅពេលដែល ខ្លួនច្រឡំនឹងកម្មវត្ថុនៃកិច្ចសន្យានោះទាំងស្រុង ឬនៅផ្នែកណាមួយ ដែលជាហេតុធ្វើឱ្យកិច្ចសន្យាមានវិការៈ។ លើសពីនេះ ការភាន់ច្រឡំ មានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ទៅលើចំណុចសំខាន់ៗនៃកិច្ចសន្យា ដែលភាគីយល់ឃើញថាសំខាន់ និងការភាន់ច្រឡំដោយភាគីទាំងសងខាង។

ក្នុងពេលដែលមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ដែលបានបង្កើតឡើងខណៈដែលភាគីម្ខាងទៀត បានស្ថិតនៅក្នុងស្ថានភាពដែលអាចយល់ដឹងបានអំពីការភាន់ច្រឡំនេះ កិច្ចសន្យាអាចលុបចោលបាន។ បើការភាន់ច្រឡំលើចំណុចសំខាន់ៗនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ ដែលជាចំណុចសំខាន់ក្នុងពេលចាប់ផ្តើមបង្កើតកិច្ចសន្យា ខណៈដែលភាគីម្ខាងទៀត បានដឹងពីការភាន់ច្រឡំនាំឱ្យមានការលុបចោល។ ម្យ៉ាងទៀត បើមានការភាន់ច្រឡំដោយភាគីទាំងសងខាង អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ទោះបីជាភាគីម្ខាងទៀតមិនបានដឹងពីការភាន់ច្រឡំនេះក៏ដោយ នៅក្នុងករណីនេះគូភាគីទាំងសងខាងមានការភាន់ច្រឡំដូច្នេះ ភាពចាំបាច់ ក្នុងការការពារភាគីម្ខាងទៀត គឺមានកម្រិតទាប ហេតុនេះហើយមិនមានភាពចាំបាច់ក្នុងការពិចារណាទៅលើលទ្ធភាពក្នុងការដឹងរបស់ភាគីម្ខាងទៀតទេ[21]។ ជារួមការបង្កើតកិច្ចសន្យាក្រុមហ៊ុនដែលមានការភាន់ច្រឡំកើតឡើង ភាគីអាចលុបចោលកិច្ចសន្យាបានដោយហេតុខាងលើ។

[21] មាត្រា៣៤៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

- **ការឆបោក**

ការឆបោក ជាអំពើដែលបានបង្កើតឡើង ក្នុងគោលបំណងបោកបន្លំទៅលើកម្មវត្ថុនៃកិច្ចសន្យាដែលបានធ្វើឡើង ដើម្បីឱ្យភាគីម្ខាងទៀតយល់ព្រមធ្វើកិច្ចសន្យាជាមួយ ហើយភាគីនៃកិច្ចសន្យា ដែលបានដឹងអំពីការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលកិច្ចសន្យានោះបាន ដោយហេតុថា ការព្រមព្រៀងមានវិការៈ[22]។ ដូចនេះ ក្នុងពេលដែលការបង្កើតកិច្ចសន្យាក្រុមហ៊ុន សមាជិកក្រុមហ៊ុនបានទទួលរងការឆបោកពីសមាជិកក្រុមហ៊ុនផ្សេងទៀត ដើម្បីឱ្យខ្លួនចុះកិច្ចសន្យាជាមួយបើសមាជិកនេះដឹងថាមានការឆបោក ពីសមាជិកក្រុមហ៊ុនផ្សេងទៀតនោះ ខ្លួនអាចលុបចោលនូវកិច្ចសន្យាបាន។

- **ព័ត៌មានមិនពិត**

ព័ត៌មានមិនពិត បើសិនភាគីម្ខាង បានបង្ហាញឆន្ទៈយល់ព្រមបង្កើតកិច្ចសន្យា ដោយសារតែខ្លួនយល់ថា ព័ត៌មាននោះ ជាការពិត ប៉ុន្តែបើការបង្ហាញនោះជាព័ត៌មានមិនពិត ភាគីដែលបានទទួលព័ត៌មានមិនពិត អាចលុបចោលកិច្ចសន្យា ដោយមូលហេតុការព្រមព្រៀងមានវិការៈផងដែរ។ ម្យ៉ាងវិញទៀត ក្នុងចំណុចនេះ ភាគី អាចទាមទារសំណងខូតខាតពីបុគ្គលដែលបានបង្ហាញការមិនពិតនោះ ក្នុងករណីដែលបុគ្គលនោះមានកំហុស[23]។ ក្នុងពេលដែលកិច្ចសន្យាក្រុមហ៊ុនកើតឡើងដោយសារភាគីនៃកិច្ចសន្យាផ្តល់ព័ត៌មានមិនពិត ដែលការផ្តល់ព័ត៌មានមិនពិតនេះនាំឱ្យមានកិច្ចសន្យាកើតឡើង ភាគីដែលបានដឹងអាចលុបចោលកិច្ចសន្យាបាន។

- **ការគម្រាមកំហែង**

ក្នុងករណីដែលភាគី បានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីតតិយជន ភាគីនោះអាចលុបចោលកិច្ចសន្យានោះបាន ដោយហេតុថាការបង្ហាញឆន្ទៈមានវិការៈ[24]។ ការបង្កើតកិច្ចសន្យាក្រុមហ៊ុន ដែលធ្វើឡើងដោយមានការគម្រាមកំហែងពីភាគីម្ខាងទៀត ភាគីដែលទទួលរងការគម្រាមកំហែង អាចលុបចោលកិច្ចសន្យាជាមួយនឹងភាគីម្ខាងទៀតនោះ។

- **អំពើកេងយកចំណេញហួសហេតុ**

កិច្ចសន្យាមួយ ដែលបានបង្កើតឡើងដោយមានការកេងយកចំណេញហួសកំណត់ ក្នុងពេលដែលភាគីណាម្ខាងកំពុងតែជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍នោះ នាំឱ្យកិច្ចសន្យាអាចលុបចោលបាន[25]។

[22] កថាខណ្ឌទី១មាត្រា៣៤៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[23] កថាខណ្ឌទី២ មាត្រា៣៤៨ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[24] មាត្រា៣៥០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[25] មាត្រា៣៥១ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

– **ការរំលោភបំពានលើស្ថានភាព**

ក្នុងករណីដែលការព្រមព្រៀងទៅនឹងកិច្ចសន្យាមួយ ធ្វើឡើងដោយមានការប្រើឋានៈរបស់ភាគីណាម្ខាង មានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬប្រើស្ថានភាពផ្សេងទៀតដែលមិនអាចប្រឆាំងបាន ភាគីដែលត្រូវបានគេរំលោភបំពាន អាចលុបចោលកិច្ចសន្យាដោយហេតុថាមានវិការៈ[26]។

**ខ. មោឃភាព**

ក្នុងករណីដែលការព្រមព្រៀង មានឋបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈមិនពិត ភាពខុសច្បាប់ ឬភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អក្នុងអត្ថន័យនៃកិច្ចសន្យា រួមទាំងអលទ្ធភាពតាំងពីដំបូងនោះកិច្ចសន្យានឹងត្រូវមោឃភាព។

– **ឋបនីយផ្លូវចិត្ត**

ឋបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដោយភាគី ដែលដឹងខ្លួនថាខុសពីឆន្ទៈពិតរបស់ខ្លួន។ បើភាគីនៃកិច្ចសន្យា បានបង្កើតកិច្ចសន្យា ដោយធ្វើឡើងខុសពីឆន្ទៈរបស់ខ្លួន នៅក្នុងពេលបង្ហាញឆន្ទៈនោះភាគីដែលបានបង្ហាញឆន្ទៈខុសពីឆន្ទៈរបស់ខ្លួន អាចលុបចោលបាន តែប្រសិនបើភាគីនៃបានបង្ហាញឆន្ទៈមក ហើយខ្លួនដឹងខុសនៅក្នុងពេលបង្ហាញឆន្ទៈ នោះកិច្ចសន្យាមិនអាចលុបចោលបានទេ[27]។

– **ការបង្ហាញឆន្ទៈមិនពិត**

ការបង្ហាញឆន្ទៈមិនពិត ជាការធ្វើឡើងដោយមានការឃុបឃិតជាមួយភាគីម្ខាងទៀត ត្រូវបានចាត់ទុកជាមោឃៈ[28]។ ដោយឡែកមោឃភាពនៃកិច្ចសន្យា មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយការយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈជាមូលដ្ឋានបានឡើយ[29]។

– **ភាពខុសច្បាប់ ឬភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អក្នុងអត្ថន័យ នៃកិច្ចសន្យា**

នៅពេលដែលភាគីបានបង្កើតកិច្ចសន្យា ទោះបីជាបានបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងពេលដែលអត្ថន័យនៃកិច្ចសន្យានោះ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ តែបើនៅក្នុងអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ហើយបើ

[26] កថាខណ្ឌទី១ មាត្រា៣៤៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[27] មាត្រា៣៥២ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[28] កថាខណ្ឌទី១ មាត្រា៣៥៣ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[29] កថាខណ្ឌទី២ មាត្រា៣៥៣ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

មានចំនុចផ្សេងទៀត ក្នុងកិច្ចសន្យាដែលសមហេតុសមផលរបស់គូភាគី នោះមានតែចំណុចដែលធ្វើឱ្យប៉ះពាល់ទាំងអស់នេះប៉ុណ្ណោះដែលត្រូវទុកជាមោឃៈ[30]។

- **អលទ្ធភាពតាំងពីដំបូង**

អលទ្ធភាពតាំងពីដំបូង គឺជាការបង្ហាញឆន្ទៈឡើងក្នុងពេលដែលភាគីនៃកិច្ចសន្យា មិនអាចសម្រេចតាំងពីពេលដែលបង្កើតកិច្ចសន្យា ហើយការបង្ហាញឆន្ទៈនេះមិនអាចមោឃភាពបានទេ ប៉ុន្តែអាចលុបចោលបានក្នុងលក្ខខណ្ឌនៃការភាន់ច្រឡំ[31]។

ជាគោលការណ៍ ការបង្កើតកិច្ចសន្យាក្រុមហ៊ុនដែលការបង្ហាញឆន្ទៈមានវិការៈខាងលើមិនអាចលុបចោល ឬមោឃៈភាពបានទេក្នុងករណីដែលតតិយជន (ម្ចាស់បំណុល) ជាជនទុច្ចរិត ហើយគ្មានកំហុសអំពីវិការៈទាំងអស់នោះ។

**២.២.២. សមត្ថភាព**

កិច្ចសន្យាមួយ ដែលត្រូវបានបង្កើតឡើង អាស្រ័យលើបុគ្គលដែលមានសមត្ថភាពយល់ដឹងអំពីការទទួលខុសត្រូវក្នុងកិច្ចសន្យា។ ជាធម្មតាកិច្ចសន្យាដែលបង្កើតឡើង គឺត្រូវតែធ្វើឡើងដោយរូបវន្តបុគ្គល ដែលមានសមត្ថភាពចុះកិច្ចសន្យាបាន ហើយបុគ្គលនោះមិនមែនជាគំហាត់ជន ដែលជាជនមានសតិប្រាជ្ញាទន់ខ្សោយ ល្ងីល្ងើ ឬមានទោសខាងអាជ្ញា ដែលច្បាប់អាជ្ញា ឬច្បាប់ស៊ីវិលឃាត់មិនឱ្យមានសេរីភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន។

ដោយឡែក បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានកម្រិតផងដែរ នូវសមត្ថភាពរបស់បុគ្គលក្នុងការសម្តែងនូវឆន្ទៈ ដើម្បីការពារផលប្រយោជន៍បុគ្គល ដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ និងមិនទាន់មានការយល់ដឹងអំពីអានុភាពផ្លូវច្បាប់របស់ខ្លួនដែលបានចុះកិច្ចសន្យា។ ផ្អែកទៅតាមក្រមរដ្ឋប្បវេណី បុគ្គលដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពមាន ៣ ប្រភេទគឺ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតនៅក្នុងហិតូបត្ថម្ភ។ ចំពោះបុគ្គលដែលបានកម្រិតទាំងអស់នេះ ពុំមានសមត្ថភាពក្នុងការចុះកិច្ចសន្យាទេ លុះត្រាតែមាន ការចូលរួមពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈ បើពុំដូច្នេះទេ កិច្ចសន្យានឹងត្រូវលុបចោលដោយបុគ្គលដែលមានសិទ្ធិចំពោះបុគ្គលទាំងនោះ។ ដូច្នេះ កិច្ចសន្យាក្រុមហ៊ុនក៏បានតម្រូវឱ្យបុគ្គលទាំងពីរដែលចុះកិច្ចសន្យាក្រុមហ៊ុននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យា។ ហេតុនេះ សមត្ថភាពរបស់ភាគីនៃកិច្ចសន្យាក្រុមហ៊ុននេះបានបែងចែកជា ២ គឺជនដែលមានសមត្ថភាព និងជនដែលត្រូវបានកម្រិតសមត្ថភាពផងដែរ។

[30] មាត្រា៣៥៤ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[31] មាត្រា៣៥៥ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

### ២.២.២.១. ជនដែលមានសមត្ថភាព

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណៈសម្បត្តិ អាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន[32]។ រូបវន្តបុគ្គល ក្នុងន័យនេះ សំដៅលើ នីតិជនដែលមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ ហើយច្បាប់ បានផ្តល់អំណាចក្នុងការចុះកិច្ចសន្យាដោយហេតុថា ជននោះជានីតិជនដែលមានការគិតពិចារណាបានច្បាស់លាស់ និងមានការយល់ដឹង ព្រមទាំងអាចវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ជាពិសេស អនីតិជនដែលមានអត្តាធីនភាព ក៏មានសិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងនីតិជនដោយអនុលោមតាមលក្ខខណ្ឌអត្តាធីនភាពដែរ[33]។

លក្ខខណ្ឌអត្តាធីនភាពមានដូចជា៖

- អនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ ហេតុនេះ អាចដាក់ពាក្យសុំទៅតុលាការ ហើយតុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា និងប្រកាសអត្តាធីនភាពក្នុងករណីយល់ឃើញថា វាមានភាពសមស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។
- អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលបាននូវអត្តាធីនភាពដោយស្វ័យប្រវត្តិ ដោយពុំចាំបាច់មានការប្រកាសពីតុលាការទេ និងទោះបីជាអាពាហ៍ពិពាហ៍ត្រូវបានរលត់ក៏ដោយ ក៏អត្តាធីនភាពនេះមិនរលត់ឡើយ។

លើសពីនេះ នីតិបុគ្គល ក៏មានសមត្ថភាពបង្កើតកិច្ចសន្យាបានដែរ ដោយនីតិបុគ្គលសំដៅលើនីតិបុគ្គលដែលបង្កើតឡើងដោយស្របច្បាប់ និងមានការចុះបញ្ជីត្រឹមត្រូវ។ ការចុះកិច្ចសន្យាក្រុមហ៊ុនរបស់នីតិបុគ្គល គឺដោយរូបវន្តបុគ្គលជាអ្នកតំណាង។ ហេតុនេះ នីតិជន និងអនីតិជនដែលមានអត្តាធីនភាព អាចចុះកិច្ចសន្យាក្រុមហ៊ុន និងមានសិទ្ធិក្លាយខ្លួនជាសមាជិកក្រុមហ៊ុនដែរ។

សរុបមកវិញ រូបវន្តបុគ្គលគ្រប់រូបអាចចុះកិច្ចសន្យាក្រុមហ៊ុនបាន ដែលអាចទទួលខុសត្រូវនូវអំពើរបស់ខ្លួន ដោយសារបុគ្គលទាំងនោះ អាចយល់ដឹងអំពីលក្ខណៈនៃកិច្ចសន្យា ហើយម្យ៉ាងវិញទៀតច្បាប់ក៏បានអនុញ្ញាតឱ្យពួកគេធ្វើកិច្ចសន្យាផងដែរ។ ហើយជាទូទៅ បុគ្គលគ្រប់រូប មានសមត្ថភាពចុះកិច្ចសន្យាក្រុមហ៊ុនបាន ប្រសិនបើបុគ្គលនោះមិនមែនជាជនដែលត្រូវបានកម្រិតសមត្ថភាព។

---

[32] មាត្រា៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[33] មាត្រា២១ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

### ២.២.២.២. ជនដែលត្រូវបានកម្រិតសមត្ថភាព

ទោះបីជាច្បាប់បានទទួលស្គាល់រូបវន្តបុគ្គលដែលអាចចុះកិច្ចសន្យាបានក៏ដោយ តែដោយឡែក រូបវន្តបុគ្គល ដែលជាអនីតិជន មិនអាចចុះកិច្ចសន្យាបានទេ។ លើសពីនេះទៅទៀត នីតិជនទាំងអស់មិនមែនសុទ្ធតែមានសមត្ថភាពក្នុងការអនុវត្តកិច្ចសន្យាបាននោះទេ ហើយច្បាប់បានកម្រិតនូវសិទ្ធិរបស់នីតិជននោះ ក្នុងការបង្ហាញឆន្ទៈដោយខ្លួនឯងផ្ទាល់ ដែលបុគ្គលទាំងនោះមានដូចជានីតិជន ដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ និងនីតិជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ។

#### ក. អនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ[34]។ម្យ៉ាងទៀត អនីតិជនជាជនដែលត្រូវបានកម្រិតនូវអាយុ និងជាជនដែលទន់ខ្សោយបើប្រៀបធៀបទៅនឹងនីតិជន ហើយអនីតិជនជា ជនដែលគ្មានការយល់ដឹងពេញលេញ និងគ្មានសមត្ថភាពក្នុងការធ្វើអ្វីមួយតាមផ្លូវច្បាប់។ នៅក្នុងន័យនេះ បុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ មិនមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យានោះទេដោយសារអនីតិជននោះស្ថិតនៅក្រោមការមើលថែរក្សារបស់អ្នកមានអំណាចមេបាឬអាណាព្យាបាល និងមិនទាន់មានការវិនិច្ឆ័យត្រឹមត្រូវ ឬការទទួលខុសត្រូវទៅតាមច្បាប់ក្នុងការសម្រេចចិត្តចុះកិច្ចសន្យាជាមួយភាគីម្ខាងទៀត។ ក្នុងនោះដែរ កិច្ចសន្យាក្រុមហ៊ុនកំណត់សមត្ថភាពបុគ្គលដែលចុះកិច្ចសន្យា ដែលអនីតិជនពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យាទេ។

ជាគោលការណ៍ អនីតិជន មិនមានសម្បទាពេញលេញ ហើយច្បាប់បានការពារបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពនេះឱ្យរួចផុតពីផលវិបាកនៃការចុះកិច្ចសន្យា។ រាល់សកម្មភាពទាំងឡាយរបស់អនីតិជន គឺពុំមានអានុភាពឡើយពោលគឺអ្នកមានសិទ្ធិលុបចោលមានដូចជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកមានសិទ្ធិអំណាចមេបាលើអនីតិជន មានសិទ្ធិលុបចោលរាល់សកម្មភាពរបស់អនីតិជនបាន[35]។ ដូចនេះ ទោះបីជាអនីតិជនបានចុះកិច្ចសន្យាជាមួយភាគីម្ខាងទៀតក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចខាងលើអាចលុបចោលសកម្មភាពទាំងនោះបាន នេះសបញ្ជាក់ឱ្យឃើញថា កិច្ចសន្យាទាំងឡាយណាដែលអនីតិជន បានធ្វើឡើងជាទូទៅ អាចចាត់ទុកថាកិច្ចសន្យានោះត្រូវបានលុបចោល។ ផ្ទុយទៅវិញ សកម្មភាពរបស់អនីតិជន ចំពោះសកម្មភាពទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពទាក់ទងជីវភាពប្រចាំថ្ងៃ អ្នកមានសិទ្ធិលុបចោល ពុំអាចលុបចោលសកម្មភាពទាំងនោះបានទេ។

[34] មាត្រា១៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[35] វាក្យខណ្ឌទី១ មាត្រា១៨ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

យ៉ាងណាមិញ អនីតិជនក៏អាចមានសមត្ថភាពចំពោះច្បាប់ដូចជា ការចុះកិច្ចសន្យាដោយមានការយល់ព្រមពីអាណាព្យាបាល និងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួនដូចជា ការទិញចំណីអាហារ សម្ភារៈសិក្សា ឬសម្លៀកបំពាក់ផ្ទាល់ខ្លួន ដោយសារសកម្មភាពនេះជាការអនុវត្តប្រចាំថ្ងៃ ដោយខានពុំបាន ហើយបើមានការលុបចោល នឹងមានបញ្ហាលំបាកទៅដល់ផ្នែកណាមួយនៃសេដ្ឋកិច្ច។ ម្យ៉ាងទៀត អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយកំណត់គោលបំណងក្នុងទំហំនៃគោលបំណងនេះបាន ម៉្យាងវិញទៀត អនីតិជនក៏អាចចាត់ចែងនូវទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយមិនបានកំណត់គោលបំណងបានដែរ[36]។

លើសពីនេះ អនីតិជនមួយចំនួនដែលមានគំនិតប្រាជ្ញាខ្ពស់អាចធ្វើសកម្មភាព ប្រកបអាជីវកម្មបាន និងអាចត្រូវបានទទួលការអនុញ្ញាតផងដែរ ហើយអនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬច្រើនប្រភេទនោះ ត្រូវមានសមត្ថភាពដូចជានីតិជនចំពោះមុខជំនួញនោះ[37]។ ចំណុចនេះមានន័យថា អនីតិជន អាចយល់ដឹង និងវិនិច្ឆ័យលើការប្រកបអាជីវកម្មរបស់ខ្លួនបានពេញលេញដូចជានីតិជនទូទៅ លើកលែងតែ អនីតិជនដែលបានប្រកបអាជីវកម្ម នោះមិនអាចបំពេញកិច្ចការបាន អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោល ឬកម្រិតនូវការអនុញ្ញាតប្រកបអាជីវកម្មនោះបាន[38]។ ដូចនេះហើយ អនីតិជន មិនអាចបង្កើតកិច្ចសន្យាក្រុមហ៊ុនដោយពុំមានការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលបានទេ ហើយមិនមានសិទ្ធិចាត់ចែងកិច្ចការនៅក្នុងក្រុមហ៊ុនដូចទៅនឹងនីតិជនឡើយ ដោយហេតុថា កិច្ចសន្យាក្រុមហ៊ុនជាការវិនិយោគនូវទ្រព្យធន ដែលវាជាកត្តាចាំបាច់ ដែលសមាជិកក្រុមហ៊ុនម្នាក់ៗ ត្រូវមានសមត្ថភាពក្នុងយល់ដឹងច្បាស់លាស់ទៅលើកិច្ចការដែលបានវិនិយោគនោះ។

**ខ. ជននៅក្រោមអាណាព្យាបាលទូទៅ**

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់ផងដែរនូវជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅថា ជាជនដែលត្រូវបានកម្រិតសមត្ថភាព។ ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវ

[36] វាក្យខណ្ឌទី១ មាត្រា១៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[37] វាក្យខណ្ឌទី១ មាត្រា២០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[38] វាក្យខណ្ឌទី២ មាត្រា២០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី។ តុលាការ អាចប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅបានតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ និងញាតិ ដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភក: មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីសាមីខ្លួនមិនទាន់ដល់អាយុ១៥ឆ្នាំ នៅពេលមានពាក្យសុំ[39]។ ក្នុងន័យនេះ ជននៅក្រោមអាណាព្យាបាលទូទៅ មិនមានសមត្ថភាពក្នុងការចុះកិច្ចសន្យាបានទេ ដោយហេតុថា ជននោះ ពុំមានការយល់ដឹងនូវសកម្មភាពរបស់ខ្លួនដែលបានធ្វើជាមួយភាគីម្ខាងទៀតឡើយ ហើយជននេះ ត្រូវប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ។ របបអាណាព្យាបាលទូទៅនេះ គឺជារបបមួយសម្រាប់ការពារសិទ្ធិដែលមានដូចជា ជីវិត រូបកាយ សេរីភាព ទ្រព្យសម្បត្តិរបស់ជនដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យទាំងនេះ[40]។

បើមានពាក្យសុំឱ្យប្រកាសចាប់ផ្ដើមអ្នកអាណាព្យាបាល តុលាការត្រូវមើលស្ថានភាពដើម្បីវិនិច្ឆ័យនូវការចាប់ផ្ដើមអាណាព្យាបាលទូទៅ និងជ្រើសតាំងអ្នកសមរម្យ ដែលអាចធ្វើជាអ្នកអាណាព្យាបាលទូទៅ។ ជាពិសេស សកម្មភាពរបស់ជនស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅអាចលុបចោលបាន លើកលែងតែសកម្មភាពរបស់ជននោះ ទាក់ទងនឹងជីវភាពប្រចាំថ្ងៃ[41]។ ដោយហេតុថា សកម្មភាពដែលបុគ្គលនេះបានធ្វើ អាចមានការយល់ដឹង និងមានសមត្ថភាពខាងឆន្ទៈឡើងវិញ ប៉ុន្តែសមត្ថភាពនេះក៏អាច បាត់បង់ទៅវិញនៅពេលធ្វើសកម្មភាពទាំងនោះបានដែរ ដូចនេះហើយ អ្នកអាណាព្យាបាលទូទៅ អាចលុបចោលសកម្មភាពទាំងនោះបាន។

ដោយឡែក សកម្មភាពប្រចាំថ្ងៃពុំត្រូវបានបដិសេធទេ បើវាជាមានទំនាក់ទំនងនឹងការជួញដូរជាប្រចាំរវាងបុគ្គលដែលនៅក្រោមអាណាព្យាបាលទូទៅ និងភាគីផ្សេងទៀត ព្រោះថាសកម្មភាពនេះ វាមិនមានលក្ខណៈស្មុគស្មាញ និងមិនបង្កបញ្ហាដល់អ្នកអាណាព្យាបាលទូទៅទេ បើសកម្មភាពនេះមានការលុបចោល នឹងធ្វើឱ្យមានផលប៉ះពាល់រួមទាំងខូចប្រយោជន៍ដល់ភាគីម្ខាងទៀត។

**គ. ជននៅក្រោមហិតូបត្ថម្ភ**

ជននៅក្រោមហិតូបត្ថម្ភ ក៏ជាជនដែលត្រូវបានកម្រិតសមត្ថភាព ដែលមានកំណត់ច្បាស់លាស់ក្នុងក្រមរដ្ឋប្បវេណីផងដែរ។ ជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមាន

---

[39] កថាខណ្ឌទី១ មាត្រា២៤ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[40] មាត្រា១២ ភាគ១: គន្លឹ១-គន្លឹ៣ សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៩

[41] មាត្រា២៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

វិបត្តិផ្នែកបញ្ញាស្មារតី។ តុលាការអាចប្រកាសចាប់ផ្ដើមហិត្តូបត្ថម្ភលើជននោះបាន តាមពាក្យសុំដូចនឹងជននៅក្រោមអាណាព្យាបាលទូទៅដែរ[42]។ ករណីនេះ សមត្ថភាពខាងឆន្ទៈរបស់ជននៅក្រោមហិត្តូបត្ថម្ភ មិនមានលក្ខណៈពេញលេញ អាចយល់ដឹងទៅលើសកម្មភាពដែលខ្លួនបានធ្វើឡើយ ជាហេតុធ្វើឱ្យមានការចាប់ផ្ដើមហិត្តូបត្ថម្ភ ដោយតុលាការបានជ្រើសតាំងជន ដែលអាចក្លាយជាហិត្តូបត្ថម្ភកៈ។

ចំពោះបុគ្គលដែលស្ថិតក្រោមហិត្តូបត្ថម្ភ មានសមត្ថភាពយល់ដឹង និងវិនិច្ឆ័យលទ្ធផលតាមផ្លូវច្បាប់បាន តែមានកម្រិតតូចតាចក្នុងសកម្មភាពដែលខ្លួនបានធ្វើ មានន័យថាសកម្មភាពរបស់ជននេះ ជាសកម្មភាពដែលអាចគ្រាន់តែទិញសម្ភារៈប្រចាំថ្ងៃ គឺមិនអាចធ្វើកិច្ចសន្យាសំខាន់ៗ ដែលមានចែងក្នុង មាត្រា៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដោយឯកឯងបានទេ លើកលែងតែមានការយល់ព្រម និងទទួលស្គាល់ដោយហិត្តូបត្ថម្ភកៈ បើពុំនោះទេ សកម្មភាពទាំងអស់ត្រូវលុបចោល។ ប៉ុន្តែ សិទ្ធិអំណាចរបស់ហិត្តូបត្ថម្ភកៈ គ្រាន់តែផ្ដល់ការយល់ព្រមលើសកម្មភាពរបស់ជននៅក្រោមហិត្តូបត្ថម្ភ ដែលមិនអាចធ្វើដោយឯករាជ្យបានតែប៉ុណ្ណោះ។ ក្នុងករណីដែលបានឡើងនេះ នៅពេលដែលជននៅក្រោមហិត្តូបត្ថម្ភបានចុះកិច្ចសន្យាក្រុមហ៊ុន ហិត្តូបត្ថម្ភកៈអាចលុបចោលកិច្ចសន្យាបាន ដោយពុំធ្វើឱ្យខាតផលប្រយោជន៍របស់ជនដែលស្ថិតក្រោមហិត្តូបត្ថម្ភនោះ។

### ២.៣ កម្មវត្ថុនៃកិច្ចសន្យាក្រុមហ៊ុន

បន្ទាប់ពីមានមូលដ្ឋានក្នុងការបង្កើតកិច្ចសន្យាក្រុមហ៊ុនដែលមានជាលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌសុពលភាព ការបង្កើតកិច្ចសន្យាក្រុមហ៊ុនមួយ បានតម្រូវឱ្យមានកម្មវត្ថុនៃកិច្ចសន្យា។ កម្មវត្ថុ ត្រូវបានកំណត់លក្ខខណ្ឌតម្រូវ សម្រាប់សុពលភាពក្នុងការបង្កើតកិច្ចសន្យា[43]។ នៅក្នុងកិច្ចសន្យាមួយ អាចមានសុពលភាពបាន លុះត្រាតែកិច្ចសន្យានោះមានកម្មវត្ថុ ដែលសំដៅលើប្រតិបត្តិការគតិយុត្តដែលភាគីទាំងឡាយចង់ធ្វើ។ ជាទូទៅ កិច្ចសន្យាមួយ ត្រូវតែមានកម្មវត្ថុពិតប្រាកដអាចធ្វើទៅកើតហើយស្របច្បាប់ ឬក្រមសីលធម៌ ដែលជាគោលការណ៍គ្រឹះ។

កម្មវត្ថុនៃកិច្ចសន្យាក្រុមហ៊ុន ជាចំណុចចម្បងក្នុងការបង្កើតឲ្យមានក្រុមហ៊ុន។ នៅក្នុងកម្មវត្ថុ នៃកិច្ចសន្យាក្រុមហ៊ុន មានចំណុចមួយចំនួនរួមមានកម្មវត្ថុជាក់លាក់ ឬកម្មវត្ថុអាចធ្វើទៅបាន និងកម្មវត្ថុស្របច្បាប់។ ក្នុងនេះផងដែរ យើងបានបង្ហាញពីកម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុនដែលជាខដែលមានចែងនៅក្នុងកិច្ចសន្យាក្រុមហ៊ុន។

[42] មាត្រា២៨ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[43] ទំព័រ៨៤ សៀវភៅ «នីតិកិច្ចសន្យា» ជិន វណ្ណារ៉ា បោះពុម្ពឆ្នាំ២០១៣

### ២.៣.១ កម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន

នៅក្នុងកិច្ចសន្យាក្រុមហ៊ុន មានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី ពុំបានកំណត់ច្បាស់លាស់នោះទេ អាស្រ័យទៅតាមគោលបំណង ឬគោលដៅក្នុងការវិនិយោគនីមួយៗដែលជារួមការវិនិយោគត្រូវមានទ្រព្យធនដែលមានសិទ្ធិលើទ្រព្យសម្បត្តិ និងកម្លាំងពលកម្ម ជាកម្មវត្ថុនៃការបង្កើតកិច្ចសន្យា ដោយហេតុថា ការព្រមព្រៀងគ្នារបស់សមាជិកក្រុមហ៊ុនត្រូវមានទ្រព្យធនវិនិយោគជាកម្មវត្ថុផ្ទាល់។ ក្នុងនោះ កម្មវត្ថុនៅក្នុងកិច្ចសន្យាក្រុមហ៊ុន បានកំណត់ច្បាស់លាស់ពីកម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន ដែលជាទ្រព្យធនវិនិយោគរបស់សមាជិកក្រុមហ៊ុននីមួយៗ និងទ្រព្យសម្បត្តិក្រុមហ៊ុនផ្សេងទៀត ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់[44]។ យើងអាចនិយាយបានថា ការបង្កើតកិច្ចសន្យាក្រុមហ៊ុន ត្រូវបានកំណត់ទៅតាមគោលបំណងរបស់សមាជិកក្រុមហ៊ុនទាំងអស់ ដោយសហការគ្នាក្នុងការប្រកបកិច្ចការអ្វីមួយ ដែលកម្មសិទ្ធិអវិភាគនៃទ្រព្យជាខចែងមួយ ក្នុងការបង្កើតកិច្ចសន្យាឡើង ដូចនេះ ទោះបីជាកិច្ចសន្យាមានគោលដៅយ៉ាងណាក៏ដោយ ទ្រព្យធនដែលបានយកទៅវិនិយោគនោះ នៅតែស្ថិតក្រោមកម្មសិទ្ធិរួមរបស់សមាជិកក្រុមហ៊ុនទាំងអស់។

ឧទាហរណ៍៖ វិសុទ្ធ កក្កដា និងលីណា បានព្រមព្រៀងគ្នាប្រកបអាជីវកម្មមួយហើយបានធ្វើកិច្ចសន្យាក្រុមហ៊ុនមួយ ដែលកម្មវត្ថុនៅក្នុងកិច្ចសន្យាគឺលក់ឧបករណ៍អគ្គិសនី ដែលទទួលបានប្រាក់ចំណូលច្រើនគួរសម ហើយពួកគេក៏បានទិញហាងមួយដើម្បីពង្រីកជំនួញ ក្នុងនោះកម្មសិទ្ធិដែលមានទៅលើហាង និងឧបករណ៍អគ្គិសនីនេះ ជាកម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុនហេតុនេះ វិសុទ្ធ កក្កដា និងលីណាមានកម្មសិទ្ធិរួមទៅលើទ្រព្យនេះ។

### ២.៣.២ កម្មវត្ថុស្របច្បាប់

ជាទូទៅ គ្រប់កម្មវត្ថុនៃកិច្ចសន្យាទាំងអស់ ត្រូវតែស្របច្បាប់ដែលមិនមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬបុគ្គលឡើយ។ បើកម្មវត្ថុនោះ ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សារធារណៈ និងទំនៀមទម្លាប់ល្អត្រូវចាត់ទុកជាមោឃៈ[45]។ កម្មវត្ថុនៃកិច្ចសន្យាក្រុមហ៊ុន ត្រូវតែមិនផ្ទុយនឹងទំនៀមទម្លាប់ល្អ ឬបទប្បញ្ញត្តិច្បាប់ណាមួយដែលបានហាមឃាត់។

ឧទាហរណ៍៖ តារា និងណារ៉ា ធ្វើកិច្ចសន្យាក្រុមហ៊ុនជាមួយគ្នា តែដោយឡែកកម្មវត្ថុនៃកិច្ចសន្យានោះ ជាការជួញដូរខុសច្បាប់នូវអាវុធជាតិផ្ទុះ ដូចនេះកិច្ចសន្យា ត្រូវបានចាត់ទុកជាមោឃៈ។

---

[44] កថាខណ្ឌ ១ មាត្រា៧០១ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[45] មាត្រា៣៥៤ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

# ជំពូកទី ២
# អានុភាព និងការរំលាយនៃកិច្ចសន្យាក្រុមហ៊ុន

ជាគោលការណ៍ កិច្ចសន្យានីមួយៗ អាចកើតឡើងទៅបានតាមរយៈលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា និងលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា។ ជាមួយគ្នានេះផងដែរ អានុភាពនៃកិច្ចសន្យា (ផ្នែកទី១) ក៏ជាលក្ខខណ្ឌមួយដ៏ចាំបាច់សម្រាប់ធ្វើឱ្យកិច្ចសន្យាមានអានុភាព និងអាចអនុវត្តទៅបាន។ ទន្ទឹមនឹងនេះ កិច្ចសន្យាក៏អាចត្រូវបានរំលាយ (ផ្នែកទី២) នៅពេលដែលការរំលាយបានកើតឡើង។

## ផ្នែកទី១ អានុភាពនៃកិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុនមានអានុភាពទៅបាន ដោយសារសំណើ និងស្ទីការត្រូវគ្នា។ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយគោរពតាមលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ហើយបន្ទាប់ពីបំពេញលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ដែលក្នុងនោះរួមមានលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់រួចមក កិច្ចសន្យាក្រុមហ៊ុន ត្រូវតែមានអានុភាព ដើម្បីអាចឱ្យកិច្ចសន្យាក្រុមហ៊ុន អាចអនុវត្តទៅបានផងដែរ។ ហេតុនេះ អានុភាពនៃកិច្ចសន្យាក្រុមហ៊ុន មានការពាក់ព័ន្ធទៅនឹងសមាជិក និងទ្រព្យធនរបស់ក្រុមហ៊ុន។

ដោយយោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីមាត្រា៦៩៩ យើងកំណត់បានថា សមាជិកនៃកិច្ចសន្យាក្រុមហ៊ុន គឺជាបណ្ដុំរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសមត្ថភាពសហការគ្នាក្នុងការសម្រេចឆន្ទៈរួមមួយដែលមានសិទ្ធិ និងកាតព្វកិច្ច។

### ១.១. សិទ្ធិរបស់សមាជិកក្រុមហ៊ុន

បន្ទាប់ពីកិច្ចសន្យាក្រុមហ៊ុន ត្រូវបានបង្កើតឡើងស្របទៅតាមគោលការណ៍ នៃលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃច្បាប់រួចមក កិច្ចសន្យានេះ ក៏ត្រូវបានចងនូវសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកក្រុមហ៊ុនទាំងអស់ ដែលទាមទារឱ្យសមាជិកទាំងអស់ត្រូវតែគោរព និងអនុវត្តតាមគោលការណ៍នានាទាំងនោះដែលរួមមានៈ សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និងស្ថានភាពទ្រព្យសម្បត្តិ សិទ្ធិទាមទារចែកចំណេញភាគនៃការបែងចែកការចំណេញខាត សិទ្ធិអំណាចអនុវត្តកិច្ចការរបស់ សមាជិកក្រុមហ៊ុននៅក្នុងក្រុមហ៊ុន និងសិទ្ធិអ្នកតំណាង។

#### ១.១.១. សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និងស្ថានភាពទ្រព្យសម្បត្តិ

សមាជិកក្រុមហ៊ុននីមួយៗមាន សិទ្ធិក្នុងការដឹងឮពីការអនុវត្តកិច្ចការនានា នៅក្នុងដំណើរការរបស់ក្រុមហ៊ុនទាំងស្ថានភាពនៃការអនុវត្តកិច្ចការ និងស្ថានភាពនៃទ្រព្យសម្បត្តិ។ បើទោះបីជាសមាជិកក្រុមហ៊ុននោះ ពុំមែនជាអ្នកអនុវត្តកិច្ចការផ្ទាល់ក៏ដោយ ព្រោះអាជីវកម្ម និងទ្រព្យសម្បត្តិ

របស់ក្រុមហ៊ុនគឺជាកម្មសិទ្ធិអវិភាគ ដែលជាទ្រព្យរួមរបស់សមាជិកក្រុមហ៊ុនទាំងអស់។ ក្រមរដ្ឋប្បវេណី មាត្រា៧០៥ បានបញ្ញត្តិថា ទោះបីគ្មានសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុនក៏ដោយ ក៏សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចធ្វើការស្រាវជ្រាវលើកិច្ចការ និងស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះបានដែរ។

សមាជិកក្រុមហ៊ុននីមួយៗ មានសិទ្ធិដឹងឮនូវរាល់សកម្មភាព និងដំណើរការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ទោះបីជាសមាជិករូបនោះគ្មានសិទ្ធិក្នុងការអនុវត្តកិច្ចការក៏ដោយ។ នៅពេលសមាជិកក្រុមហ៊ុន ចង់ដឹងពីប្រតិបត្តិការការងាររបស់ក្រុមហ៊ុន សមាជិករូបនោះអាចប្រើប្រាស់សិទ្ធិ ធ្វើការស្រាវជ្រាវលើកិច្ចការនោះបាន។ ផ្ទុយទៅវិញ បើការប្រើប្រាស់សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ ផ្តល់ផលប៉ះពាល់ ឬធ្វើឲ្យខូចប្រយោជន៍របស់ក្រុមហ៊ុននោះ ការប្រើប្រាស់សិទ្ធិត្រូវបានបដិសេធ និងហាមឃាត់[46]។

ឧទាហរណ៍១៖ សុវត្ថិ និងភីរុំ បានបង្កើតកិច្ចសន្យាក្រុមហ៊ុន បើកកន្លែងលាងម៉ូតូមួយកន្លែង ដោយសុវត្ថិ បានចេញភាគទុនជាសាច់ប្រាក់ រីឯភីរុំបានចេញភាគទុនជាកម្លាំងពលកម្ម (ភីរុំ គឺជាអ្នកអនុវត្តកិច្ចការ)។ ដោយចង់ដឹងពីចំនួនអតិថិជន និងដំណើរការផ្សេងៗទៅលើអាជីវកម្មមួយនេះ ដូចនេះ សុវត្ថិបានប្រើប្រាស់សិទ្ធិស្រាវជ្រាវលើការអនុវត្តកិច្ចការ ដោយគាត់បានចំណាយពេលពីរថ្ងៃទៅបីថ្ងៃ ក្នុងការត្រួតពិនិត្យការងារនៅទីតាំងផ្ទាល់ ដើម្បីធ្វើការរាប់ចំនួនអតិថិជន ដែលទទួលបានក្នុងមួយថ្ងៃៗ និងត្រួតពិនិត្យពីតម្រូវការ និងកង្វះខាតទៅលើផ្នែកសម្ភារៈព្រមទាំងសេវាកម្ម។

លើសពីសិទ្ធិក្នុងការស្រាវជ្រាវលើការអនុវត្តកិច្ចការ សមាជិកនីមួយៗ ក៏មានសិទ្ធិក្នុងការស្រាវជ្រាវលើស្ថានភាពទ្រព្យសម្បត្តិផងដែរ។ សមាជិកក្រុមហ៊ុន មានសិទ្ធិធ្វើការផ្ទៀងផ្ទាត់លើទ្រព្យ សម្បត្តិរបស់ក្រុមហ៊ុននៅពេលណាក៏បាន ទោះបីជាបុគ្គលនោះ មិនមែនជាអ្នកអនុវត្តកិច្ចការផ្ទាល់ក៏ដោយ តាមរយៈការផ្ទៀងផ្ទាត់លើបញ្ជីចំណូល ចំណាយ និងការរាប់សន្និធិ(ស្តុក)ជាដើម។

ឧទាហរណ៍២៖ លីលី និងចរិយា បានធ្វើកិច្ចសន្យាក្រុមហ៊ុនមួយក្នុងការបង្កើតអាជីវកម្ម លក់កាបូបតាមអនឡាន ដោយលីលីគឺជាអ្នកអនុវត្តកិច្ចការផ្ទាល់ប្រចាំថ្ងៃ។ បន្ទាប់ពីដំណើរការអាជីវកម្មបានមួយរយៈក្រោយមក ចរិយា ចង់ធ្វើការស្រាវជ្រាវលើស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។ ដូច្នេះ នាងបានប្រើប្រាស់សិទ្ធិធ្វើការស្រាវជ្រាវលើស្ថានភាពទ្រព្យសម្បត្តិ ដើម្បីធ្វើការត្រួតពិនិត្យលើចំណូល ចំណាយ សន្និធិ(ស្តុក) និងធ្វើការត្រួតពិនិត្យលើចំនួនឧបករណ៍ប្រើប្រាស់ក្នុងក្រុមហ៊ុន ដូចជា ម៉ាស៊ីនត្រជាក់ កាមេរ៉ាសុវត្ថិភាព និងម៉ូតូសម្រាប់ដឹកជញ្ជូនជាដើម ដែលបម្រើផលអាជីវកម្មជាពិសេសទៅទៀតនោះ គឺសៀវភៅគណនីធនាគាររបស់ក្រុមហ៊ុន។

[46] កថាខណ្ឌទី២ មាត្រា៧០៥សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៩ ភាគ៣, គន្លឹះ៥

### ១.១.២. សិទ្ធិទាមទារចែកចំណេញ ភាគនៃការបែងចែកការចំណេញខាត

ក្នុងនាមជាភាគហ៊ុននិកម្នាក់ៗ មានសិទ្ធិលើទ្រព្យដែលជាផលចំណេញ និងទ្រព្យបំណុលដែលក្រុមហ៊ុនមាន តាមភាគទុនដែលខ្លួនបានវិនិយោគរៀងៗខ្លួន។ ដូចដែលបានបញ្ញត្តិនៅក្នុងមាត្រា៧០៦ នៃក្រមរដ្ឋប្បវេណី អំពីសិទ្ធិទាមទារនៃការបែងចែកការចំណេញ ខាត សមាជិកក្រុមហ៊ុន ត្រូវគណនាការចំណេញ ខាត នៅក្នុងអំឡុងពេលទៀងទាត់ ហើយក្នុងករណីដែលមានចំណេញ អាចទាមទារឱ្យបែងចែកផលចំណេញនោះបាន។ ប្រសិនបើសមាជិកក្រុមហ៊ុន មិនបានកំណត់ភាគនៃការបែងចែកការចំណេញ ខាតទេ ត្រូវកំណត់ទៅតាមសមាមាត្រនៃចំនួនតម្លៃវិនិយោគទ្រព្យធនរបស់សមាជិកនីមួយៗនៃក្រុមហ៊ុននោះ[47]។ ក្នុងករណីនេះ មានន័យថា បើសមាជិកក្រុមហ៊ុននីមួយៗ មិនបានកំណត់ភាគចំណែកនៃការចំណេញ ខាតច្បាស់លាស់ក្នុងកិច្ចសន្យាក្រុមហ៊ុនទេនោះ សមាជិកទាំងអស់ត្រូវយកចំណុចនេះមកអនុវត្តក្នុងការទូទាត់។ ផ្ទុយទៅវិញប្រសិនបើសមាជិក្រុមហ៊ុនទាំងអស់ ពុំបានកំណត់រូបមន្តនៃការបែងចែកការចំណេញ ខាតនោះទេ សមាជិកទាំងអស់អាចធ្វើការទូទាត់តាម ចំណែកភាគហ៊ុនដែលខ្លួនបានវិនិយោគ។ មួយវិញទៀត ក្នុងករណីដែលកិច្ចសន្យាក្រុមហ៊ុន កំណត់ចំពោះតែផ្នែកម្ខាងនៃការចំណេញ ឬខាត នោះការទូទាត់ការចំណេញ ឬខាត ត្រូវមានលក្ខណៈស្មើគ្នា តាមភាគហ៊ុនដែលសមាជិកវិនិយោគ ដូចដែលបានបញ្ញត្តិនៅក្នុងមាត្រា៧០៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីថា ប្រសិនបើបានកំណត់តែភាគនៃការបែងចែកចំពោះការចំណេញ ខាតណាមួយ ត្រូវសន្មត់ថាភាគនោះដូចគ្នាទៅនឹងការខាតបង់ និងការចំណេញ។ កិច្ចសន្យាត្រូវចែងឱ្យច្បាស់ពីតម្លៃនៃហ៊ុនរបស់សមាជិក ដែលពុំបានចេញប្រាក់ដើម ឬទ្រព្យជាសម្ភារៈនោះ។ បើកិច្ចសន្យាគ្មានចែងអំពីខនេះទេ ហ៊ុនដែលយកមកចូលនោះត្រូវទុកជាស្មើភាគគ្នាទាំងអស់។

ឧទាហរណ៍១៖ មន្ទីរពេទ្យ X (ភាគី ក) និងក្រុមហ៊ុន Y (ភាគី ខ) ព្រមព្រៀងគ្នាសហការវិនិយោគដោយភាគីម្ខាង ផ្តល់ជាទីតាំង ហើយភាគីម្ខាងទៀតផ្តល់ជាម៉ាស៊ីន CT SCAN 8 slices។ នៅពេលធ្វើកិច្ចសន្យា ភាគីទាំងពីរ បានកំណត់នូវភាគរយនៃភាគចំណេញដែលភាគីនីមួយៗត្រូវទទួលបាន។ ដោយ មន្ទីរពេទ្យ X (ភាគី ក) ទទួលបាន២៥% នៃប្រាក់ចំណូលសុទ្ធ (ក្រោយការទូទាត់ចំណាយរួច) ដោយទទួលបានជារៀងរាល់ខែនីមួយៗ។ ហើយក្រុមហ៊ុន Y (ភាគី ខ) ទទួលបាន ៧៥% នៃប្រាក់ចំណូលសុទ្ធ (ក្រោយការទូទាត់ចំណាយរួច) ដោយទទួលបានជារៀងរាល់ខែនីមួយៗ។

---

[47] កថាខណ្ឌទី២ មាត្រា៧០៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ឧទាហរណ៍២៖ សង្ហា និងណារិន បានធ្វើកិច្ចសន្យាក្រុមហ៊ុនរួមគ្នាមួយដើម្បីបង្កើតរបរថតរូប និងផ្តិតរូប។

តម្លៃសរុបនៃទ្រព្យវិនិយោគ: ២០០០០ដុល្លារ=១០០%

តម្លៃសរុបនៃទ្រព្យដែលសង្ហាវិនិយោគ: ៨០០០ដុល្លារ=៤០%

តម្លៃសរុបនៃទ្រព្យដែលណារិនវិនិយោគ: ១២០០០ដុល្លារ=៦០%

- ក្នុងលក្ខខណ្ឌទី១៖ នៅពេលបង្កើតកិច្ចសន្យាឡើងសមាជិកក្រុមហ៊ុនទាំងពីរ ពុំបានកំណត់ពីភាគនៃការបែងចែកការចំណេញខាតទេ ដូច្នេះភាគនៃការបែងចែកចំណេញខាតត្រូវកំណត់ទៅតាមសមាមាត្រនៃចំនួនតម្លៃវិនិយោគទ្រព្យធនរបស់សមាជិកទាំងពីរ។

ផលចំណេញដែលទទួលបានក្នុងខែទី១: ១៥០០ដុល្លារ

ផលចំណេញដែលសង្ហាទទួលបានក្នុងខែទី១= (១៥០០ x ៤០)/១០០=៦០០ដុល្លារ

ផលចំណេញដែលណារិនទទួលបានក្នុងខែទី១= (១៥០០ x ៦០)/១០០=៩០០ដុល្លារ

នៅខែទី២អាជីវកម្មរបស់ពួកគេទទួលរងការខាត ដោយរដូវចូលវស្សាបានមកដល់ដូច្នេះចំនួននៃពិធីរៀបអាពាហ៍ពិពាហ៍មានការធ្លាក់ចុះ ដែលធ្វើឲ្យប៉ះពាល់ដល់មុខរបរមួយនេះ។

ប្រាក់ដែលត្រូវខាតសរុបនៅខែទី២: ២០០០ដុល្លារ

ប្រាក់ដែលសង្ហាត្រូវខាតនៅខែទី២=(២០០០ x ៤០)/១០០=៨០០ដុល្លារ

ប្រាក់ដែលណារិនត្រូវខាតនៅខែទី២=(២០០០ x ៦០)/១០០=១២០០ដុល្លារ

- ក្នុងលក្ខខណ្ឌទី២៖ វាក៏ដូចគ្នាផងដែរ បើក្នុងកិច្ចសន្យា បានកំណត់ពីភាគរយដែលសមាជិកម្នាក់ៗត្រូវទទួលបានប្រាក់ចំណេញ ដូច្នេះភាគរយដែលគាត់ត្រូវចំណាយលើការខាតស្មើគ្នាលើភាគរយនៃប្រាក់ចំណេញ។

បើកិច្ចសន្យាបានកំណត់ថាសង្ហា នឹងត្រូវទទួលបាន៤០%នៃផលចំណេញសរុប ហើយណារិននឹងទទួលបាន៦០%នៃផលចំណេញសរុប។ ដូច្នេះយើងទាញបានថាការទូទាត់លើការខាតសង្ហាត្រូវចំណាយ៤០% ចំណែកណារិនត្រូវចំណាយ៦០%។ ម្យ៉ាងទៀត បើការព្រមព្រៀងរបស់សមាជិកក្រុមហ៊ុន បានកំណត់ទៅលើភាគនៃការចំណេញ ឬភាគនៃការទទួលបន្ទុកខាតបង់ ដូចនេះ ភាគនៃការចំណេញខាត ត្រូវអនុលោមតាមការព្រមព្រៀងរបស់សមាជិកទាំងអស់ដែរ។ ដោយឡែក ករណីដែលការព្រមព្រៀងរបស់សមាជិកក្រុមហ៊ុនដែលឱ្យសមាជិកណាម្នាក់ មិនទទួលបន្ទុកខាត បង់សោះអាចមានសុពលភាព ក៏ប៉ុន្តែ បើការព្រមព្រៀងនោះឱ្យសមាជិកណាម្នាក់មិនបានទទួល ផលចំណេញការព្រមព្រៀងនោះមិនអាចអនុវត្តទៅបានឡើយ ដោយហេតុថាគោលដៅនៃក្រុមហ៊ុន បង្កើតឡើងដើម្បីរកផលចំណេញ (សេចក្តីកំណត់ចំពោះមាត្រា៧០៦នៃក្រមរដ្ឋប្បវេណី)។

### ១.១.៣ សិទ្ធិអំណាចអនុវត្តកិច្ចការរបស់សមាជិកក្រុមហ៊ុននៅក្នុងក្រុមហ៊ុន

ជាទូទៅ នៅក្នុងក្រុមហ៊ុនភាគច្រើនដែលមានសមាជិកតិច គេពុំបានកំណត់អ្នកអនុវត្តកិច្ចការសម្រាប់ក្រុមហ៊ុនទេ ដូច្នេះហើយសមាជិកម្នាក់ៗ មានសិទ្ធិស្មើគ្នាក្នុងការអនុវត្តកិច្ចការ។ ជាមួយគ្នានេះដែរ ការអនុវត្តកិច្ចការត្រូវធ្វើតាមសម្លេងលើសពាក់កណ្តាល នៃចំនួនសមាជិកទាំងអស់។ ក្នុងនោះ បញ្ញត្តិក្នុងមាត្រា ៧០២ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ក្នុងករណីដែលពុំបានកំណត់សមាជិកក្រុមហ៊ុន ឬតតិយជនទទួលអាណត្តិអនុវត្តកិច្ចការនៅក្នុងកិច្ចសន្យាក្រុមហ៊ុននោះទេ សមាជិកនីមួយៗនៃក្រុមហ៊ុន មានសិទ្ធិអំណាចអនុវត្តកិច្ចការរបស់ក្រុមហ៊ុននោះ ប៉ុន្តែការអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ត្រូវសម្រេចដោយសម្លេងលើសពាក់កណ្តាល នៃចំនួនសមាជិកនោះ[48]។

ប្រសិនបើមានការកំណត់ថាសមាជិកក្រុមហ៊ុន ឬតតិយជនដែលទទួលអាណត្តិអនុវត្តកិច្ចការនៅក្នុងកិច្ចសន្យាក្រុមហ៊ុន ដែលត្រូវមានសមាជិកច្រើននាក់ ការអនុវត្តកិច្ចការក្រុមហ៊ុនត្រូវសម្រេច ដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ[49]។ នេះបានន័យថា បើកិច្ចសន្យាក្រុមហ៊ុនបានកំណត់ពីចំនួនបុគ្គលដែលអនុវត្តកិច្ចការ ដែលជាសមាជិកក្រុមហ៊ុន ដែលត្រូវមានចំនួនច្រើននាក់នោះ ត្រូវមានសម្លេងគាំទ្រលើសពីពាក់កណ្តាល ទើបអាចអនុវត្តកិច្ចការនៅក្នុងក្រុមហ៊ុនបាន។ លើសពីនេះ សមាជិកក្រុមហ៊ុននីមួយៗ ឬ អ្នកអនុវត្តកិច្ចការម្នាក់ៗ អាចអនុវត្តកិច្ចការក្រុមហ៊ុន ដោយឯកតោភាគីបាន តែផ្ទុយមកវិញ បើមានមតិតវ៉ាពីសមាជិកក្រុមហ៊ុន ឬអ្នកអនុវត្តកិច្ចការផ្សេងទៀត នៅមុនពេលបញ្ចប់កិច្ចការ ការអនុវត្តកិច្ចការដោយឯកតោភាគីមិនអាចសម្រេចទៅបានឡើយ[50]។

បន្ថែមពីនេះទៅទៀត យោងតាមមាត្រា៧០៣នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិផងដែរថា បញ្ញត្តិចាប់ពីមាត្រា៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន។ ដោយផ្អែកតាមខ្លឹមសារដែលបានបញ្ញត្តិក្នុងមាត្រាខាងលើ យើងអាចទាញបានថា ទំនាក់ទំនងគតិយុត្តរវាងអ្នកអនុវត្តកិច្ចការ និងក្រុមហ៊ុនគឺជាប្រភេទកិច្ចសន្យាអាណត្តិ ឬវាមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចសន្យាអាណត្តិដែរ ដូចនេះហើយ ទំនាក់ទំនងគតិយុត្តរវាងអ្នកអនុវត្តកិច្ចការត្រូវអនុវត្ត ដូចគ្នា

[48] កថាខណ្ឌទី១ មាត្រា ៧០២ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[49] កថាខណ្ឌទី២ មាត្រា ៧០២ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[50] កថាខណ្ឌទី៣ មាត្រា ៧០២ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ផងដែរទៅនឹងបញ្ញត្តិស្តីពីអាណត្តិ (ចាប់ពីមាត្រា៦៤០ដល់មាត្រា៦៥៦ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧)។

### ១.១.៤. សិទ្ធិក្នុងការជ្រើសតាំងអ្នកតំណាង

ការតំណាង គឺជាទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យា ត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យាជាមួយនឹងភាគីម្ខាងទៀត ដោយបង្ហាញថាការធ្វើកិច្ចសន្យានោះ គឺធ្វើសម្រាប់ម្ចាស់សិទ្ធិក្នុងទំហំនៃសិទ្ធិអ្នកតំណាង[51]។ ការតំណាងពាក់ព័ន្ធនឹងបញ្ហាខាងក្រៅដែលកើតឡើង នៅពេលអ្នកតំណាងដែលមានសិទ្ធិតំណាងធ្វើកិច្ចការ ឬប្រតិបត្តិការ ជាមួយតតិយជនសម្រាប់ម្ចាស់សិទ្ធិ រីឯអាណត្តិពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិ និងករណីយកិច្ច (ទំនាក់ទំនងខាងក្នុង) រវាងម្ចាស់សិទ្ធិ និងអ្នកតំណាង[52]។ ហេតុនេះហើយអាណត្តិ និងការតំណាងគួរត្រូវបានបែងចែកពីគ្នា។ ជាមួយគ្នានេះដែរ សិទ្ធិនៃអ្នកតំណាងត្រូវបានធ្វើការបែងចែកជាពីរគឺៈ សិទ្ធិតំណាងដោយច្បាប់ និងសិទ្ធិតំណាងដោយឆន្ទៈ ឬការព្រមព្រៀង។

សិទ្ធិតំណាងដោយច្បាប់ គឺជាការកកើតឡើងនៃសិទ្ធិតំណាងតាមរយៈការជ្រើសតាំងដោយបញ្ញត្តិច្បាប់[53]។ សិទ្ធិនេះ ចាប់ផ្តើមនៅពេលមានការកកើតឡើងនៃរបបអាណាព្យាបាលទូទៅ របបអំណាចមេបា របបអាណាព្យាបាលសម្រាប់អនីតិជន។

សិទ្ធិតំណាងដោយឆន្ទៈ អាចកើតឡើងដោយការព្រមព្រៀងគ្នា រវាងម្ចាស់សិទ្ធិ និងអ្នកតំណាង[54]។ ដោយយោងតាមអត្ថន័យ និងខ្លឹមសារនៃសិទ្ធិតំណាង យើងអាចកំណត់បានថា សិទ្ធិតំណាងដោយឆន្ទៈត្រូវបានយកមកប្រើប្រាស់នៅក្នុងបរិបទកិច្ចសន្យាក្រុមហ៊ុន។ បើទោះបី មានការព្រមព្រៀង ផ្តល់ឱ្យអ្នកតំណាងធ្វើសកម្មភាពជាច្រើនយ៉ាងណាក៏ដោយ ក៏សកម្មភាពមួយចំនួនច្បាប់បានកម្រិតជាមុនថាអ្នកតំណាងមិនអាចធ្វើសកម្មភាពនោះ ក្នុងនាមជាអ្នកតំណាងបានទេ។ ពោលគឺសកម្មភាពនោះធ្វើឲ្យផ្ទុយពីផលប្រយោជន៍ម្ចាស់សិទ្ធិ និងអ្នកតំណាង លើកលែងតែទទួលបានការយល់ព្រមពីម្ចាស់សិទ្ធិ[55]។ បញ្ញត្តិនេះបានបង្ហាញថា សកម្មភាពរបស់អ្នកតំណាង ធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ម្ចាស់សិទ្ធិនោះទេ ហើយសកម្មភាពនោះ នឹងមិនមានអានុភាពទេ ប៉ុន្តែវាអាចនឹងមានអានុភាពប្រសិនបើមានការយល់ព្រមពីម្ចាស់សិទ្ធិ នៅពេលដែលម្ចាស់សិទ្ធិ ដឹងពីសកម្មភាពដែលមានភាពផ្ទុយគ្នាពីឆន្ទៈម្ចាស់សិទ្ធិតែមិនមានការតវ៉ា។

---

[51] មាត្រា ៣៦៤ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[52] កថាខណ្ឌទី៣ ចំណុចទី១ មាត្រា ៣៦៤ សេចក្តីកំណត់ចំពោះមាត្រាណីមួយៗនៃក្រមរដ្ឋប្បវេណីភាគ២,គន្លឹ៥

[53] មាត្រា ៣៦៥ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[54] មាត្រា ៣៦៥ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[55] កថាខណ្ឌទី២ មាត្រា ៣៦៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ស្របពេលនឹងមានការផ្ទេរនូវសិទ្ធិ ក៏ដូចជាកាតព្វកិច្ចមួយចំនួនទៅឲ្យអ្នកតំណាងដោយអាណត្តិនោះ។ អាណត្តិគាហក ត្រូវបំពេញនូវកិច្ចការរបស់ខ្លួនដោយប្រុងប្រយ័ត្ន ជៀសវាងនូវកំហុសដែលនាំឲ្យ មានភយន្តរាយចំពោះក្រុមហ៊ុន។ អាណត្តិគាហក មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិព្រម ទាំងត្រូវធ្វើការរាយការណ៍ទៅឲ្យអាណត្តិទាយក អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបី នៅពេលណាក៏ដោយ ឬត្រូវរាយការណ៍អំពីហេតុការណ៍ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេល ដែលបានបញ្ចប់អាណត្តិហើយ។ ម្យ៉ាងវិញទៀត អាណត្តិគាហកអាចនឹងត្រូវបានដកហូត ចេញពី តំណែងជាអ្នកតំណាងក្រុមហ៊ុន ផ្អែកទៅតាមការសម្រេចរបស់អាណត្តិទាយក (សមាជិកក្រុមហ៊ុន) បាន នៅពេលដែលអាណត្តិគាហកបានប្រព្រឹត្តិផ្ទុយទៅនឹង ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក ឬបានដឹកនាំក្រុមហ៊ុនឆ្ពោះទៅកាន់ការខាតបង់។

**១.២. ភាតព្វកិច្ចរបស់សមាជិកក្រុមហ៊ុន**

ក្រៅពីទទួលបាននូវសិទ្ធិ ក្នុងការអនុវត្តទៅលើកិច្ចការរបស់ក្រុមហ៊ុន សមាជិកក្រុមហ៊ុនក៏មាន កាតព្វកិច្ចមួយចំនួន ដែលជាចំណងសម្រាប់ចងទៅលើភាគីនីមួយៗ។ ទន្ទឹមនឹងការទទួលបានផលចំណេញភាគីនីមួយៗត្រូវបានចងនូវកាតព្វកិច្ចក្នុងការទូទាត់បំណុល ដែលត្រូវបានបង្កើតឡើងជាកាតព្វកិច្ចសាមគ្គីភាព។ កាតព្វកិច្ចក្នុងការទូទាត់សងបំណុលនេះ សមាជិកក្រុមហ៊ុនទាំងអស់ត្រូវយកទ្រព្យសម្បត្តិរួមរបស់ក្រុមហ៊ុនមកធ្វើការទូទាត់បំណុលទាំងនោះ ប៉ុន្តែក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិរួមរបស់ក្រុមហ៊ុន មិនគ្រប់គ្រាន់ក្នុងការទូទាត់បំណុលទេ សមាជិកក្រុមហ៊ុនទាំងអស់ត្រូវយកទ្រព្យផ្ទាល់របស់ខ្លួនមកទូទាត់បន្ថែម[56]។

ក្រមរដ្ឋប្បវេណី កថាខណ្ឌទី១នៃមាត្រា៧០៧ បានបញ្ញត្តិថា កាតព្វកិច្ចដែលកើតឡើងដោយកិច្ចការរបស់ក្រុមហ៊ុន គឺជាកាតព្វកិច្ចដោយសាមគ្គីភាព ប៉ុន្តែកាតព្វកិច្ចនោះត្រូវសងដោយទ្រព្យសម្បត្តិក្រុមហ៊ុនសិន ហើយប្រសិនបើមិនអាចសងកាតព្វកិច្ចទាំងអស់ដោយទ្រព្យសម្បត្តិទើបសងដោយទ្រព្យដោយឡែករបស់សមាជិកនីមួយៗ។ ជាមួយគ្នានេះដែរ យើងបានដឹងហើយថាកាតព្វកិច្ចនៃការសងបំណុលជាកាតព្វកិច្ច ដោយសាមគ្គីភាពរវាងសមាជិកក្រុមហ៊ុនទាំងអស់។ ជាការពិតណាស់ ប្រសិនបើការបង្កើតកិច្ចសន្យាក្រុមហ៊ុន នេះបានចងនូវកិច្ចសន្យាពិសេសមួយដែលនិយាយអំពីលក្ខខណ្ឌនៃការបែងចែកគ្នាសងបំណុលនោះ ការអនុវត្តនីតិវិធីគឺត្រូវអនុវត្តតាមកិច្ចសន្យាដែលបានកំណត់នោះ។ ផ្ទុយទៅវិញ បើនៅក្នុងកិច្ចសន្យាក្រុមហ៊ុននោះ ពុំបានកំណត់ពីលក្ខខណ្ឌក្នុងការសងបំណុលនេះទេ នោះបន្ទុករបស់សមាជិកនីមួយៗត្រូវធ្វើតាមសមាមាត្រនៃ

[56] កថាខណ្ឌទី២ មាត្រា ៧០៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ភាគទុនដែលខ្លួនបានវិនិយោគ[57]។ យ៉ាងណាមិញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន គឺជាកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ដូចនេះ កូនបំណុលរបស់ក្រុមហ៊ុនពុំអាចទូទាត់កាតព្វកិច្ចនោះ ជាមួយនឹងសិទ្ធិលើបំណុលចំពោះសមាជិកនីមួយៗនៃក្រុមហ៊ុនបានឡើយ។ បានសេចក្ដីថា ក្នុងករណីដែលមានបុគ្គលណាម្នាក់បានជំពាក់បំណុលក្រុមហ៊ុន ហើយមានសមាជិកក្រុមហ៊ុនណាម្នាក់បានជំពាក់បំណុលរបស់បុគ្គលរូបនោះ ដូច្នេះបុគ្គលនោះពុំអាចយកសិទ្ធិដែលខ្លួនមានទៅលើសមាជិកក្រុមហ៊ុនណាម្នាក់នោះមកធ្វើការទូទាត់បំណុលដែលខ្លួនបានជំពាក់ក្រុមហ៊ុនបានឡើយ។

ឧទាហរណ៍: ភារ៉ា សោភា និងរ៉ានី ជាសមាជិកក្រុមហ៊ុននៃកិច្ចសន្យាក្រុមហ៊ុនមួយ ដោយឡែកភ័ណ្ឌ បានជំពាក់លុយក្រុមហ៊ុន ហើយសោភាធ្លាប់ជំពាក់លុយភ័ណ្ឌ ដូចនេះភ័ណ្ឌមិនអាចយកបំណុលដែលសោភាបានជំពាក់ខ្លួន ទៅកាត់កងគ្នាជាមួយនឹងបំណុលដែលខ្លួនជំពាក់ក្រុមហ៊ុនបានឡើយ។ សរុបជារួមមក បំណុលផ្ទាល់របស់សមាជិកក្រុមហ៊ុនណាម្នាក់ ពុំអាចសងដោយទ្រព្យសម្បត្តិរួមបានឡើយ។

### ១.៣. របៀបដកខ្លួន

បន្ទាប់ពីមានការចូលខ្លួនដើម្បីសហការគ្នាក្នុងការដាក់ទុនវិនិយោគ យ៉ាងណាមិញ វាអាចបណ្ដាលឱ្យកើតមានការដកខ្លួនផងដែរ។ ចំពោះការដកខ្លួន មានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលរួមមាន (១) ការដកខ្លួនដោយស្ម័គ្រចិត្ត និង(២) ការដកខ្លួនតាមច្បាប់។

#### ១.៣.១. ការដកខ្លួនដោយស្ម័គ្រចិត្ត

ក្នុងករណីសមាជិកក្រុមហ៊ុនទាំងអស់ពុំបានកំណត់ពីអំឡុងពេលនៃអត្ថិភាព ឬអាចនិយាយបានថាពុំបានកំណត់ពីអាយុកាលនៃក្រុមហ៊ុននៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ នោះសមាជិកនីមួយៗអាចធ្វើការដកខ្លួនចេញនៅពេលណាក៏បាន[58]។ ត្រង់ចំនុចនេះមានន័យថា ប្រសិនបើសមាជិកក្រុមហ៊ុន ពុំបានកំណត់ពីអាយុកាលនៃការតាំងនៅរបស់ក្រុមហ៊ុននៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេនោះ សមាជិកក្រុមហ៊ុននីមួយៗ អាចដកខ្លួនចេញនៅអំឡុងពេលណាក៏បាន ប៉ុន្តែត្រូវធានាឲ្យបានការថា ការដកខ្លួនរបស់សមាជិកណាម្នាក់ ពុំផ្ដល់ផលប៉ះពាល់ដែលនាំឲ្យខូចប្រយោជន៍ដល់ក្រុមហ៊ុនឡើយ លើកលែងតែករណីចាំបាច់បំផុតដែលពុំអាចជៀសបាន។

ឧទាហរណ៍: លោកដារ៉ា លោកកុសល និងលោកចិត្របានចូលហ៊ុនគ្នាទិញឡានដឹកទំនិញមួយគ្រឿង ដើម្បីបម្រើសេវាដឹកទំនិញ។ ជាអកុសលលោកដារ៉ា និងលោកចិត្រមានទំនាស់ពាក្យ

[57] កថាខណ្ឌទី២ មាត្រា៧០៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[58] កថាខណ្ឌទី១ មាត្រា៧០៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

សម្តីគ្នាយ៉ាងខ្លាំង ដែលជាហេតុធ្វើឲ្យអ្នកទាំងពីរមើលមុខគ្នាលែងចំ។ ចាប់តាំងពីពេលនោះមក ទំនាក់ទំនងការងារចាប់ផ្តើមមានភាពរកាំរកូស ដែលជាហេតុធ្វើអោយលោកចិត្រទាមទារដកខ្លួនចេញពីកិច្ចសន្យាក្រុមហ៊ុន។ នេះគឺជាហេតុផលដែលពុំអាចជៀសបានរបស់ចិត្រដែលត្រូវតែធ្វើការដកខ្លួនចេញពីកិច្ចសន្យាក្រុមហ៊ុន បើទោះបីជាគាត់ដឹងថាវានឹងធ្វើឲ្យខូចប្រយោជន៍ក្រុមហ៊ុនក៏ដោយ។

ម្យ៉ាងវិញទៀត ការដកខ្លួនដោយស្ម័គ្រចិត្តរបស់សមាជិកនីមួយៗ ក៏អាចដកខ្លួន នៅពេលណាក៏បាន ប្រសិនបើបានកំណត់អត្ថិភាពដែលក្រុមហ៊ុនត្រូវមានក្នុងរយៈពេលមួយជីវិតរបស់សមាជិកណាម្នាក់[59]។ បានសេចក្តីថា បើសមាជិកក្រុមហ៊ុនបានព្រមព្រៀងគ្នាកំណត់ពីអាយុ កាលនៃក្រុមហ៊ុនស្មើនឹងរយៈពេលមួយជីវិតរបស់សមាជិកណាម្នាក់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ដូច្នេះសមាជិកនីមួយៗ ក៏អាចដកខ្លួនចេញពេលណាក៏បាន ទោះបីជាអាយុកាលក្រុមហ៊ុន ស្មើអាយុកាលរបស់គាត់នៅមានជីវិតក៏ដោយ ប៉ុន្តែការដកខ្លួននោះ ពុំអាចធ្វើបានឡើយបើ បណ្តាលឱ្យខូចប្រយោជន៍ដល់ក្រុមហ៊ុន លើកលែងតែករណីដែលពុំអាចជៀសវាងបានប៉ុណ្ណោះ។

ឧទាហរណ៍៖ លោកដារ៉ា លោកកុសល និងលោកចិត្របានចូលហ៊ុនគ្នាទិញឡានដឹកទំនិញមួយគ្រឿង ដើម្បីបម្រើសេវាដឹកទំនិញ ដោយភាគីទាំងបី ដាក់ហ៊ុនជាប្រាក់តាមភាគទុនដែលខ្លួនមាន។ ដោយក្នុងចំណោមសមាជិកក្រុមហ៊ុនទាំងបីនាក់ មានតែលោកដារ៉ាប៉ុណ្ណោះ ដែលចេះបើកឡាន ដូច្នេះហើយ ពួកគេក៏បានព្រមព្រៀងគ្នា ដោយឱ្យលោកដារ៉ាធ្វើជាតៃកុងឡានក្នុងការបម្រើសេវាដឹកទំនិញ។ ហើយពួកគេក៏បានកំណត់យកអាយុជីវិតរបស់ក្រុមហ៊ុន ស្មើនឹងអាយុជីវិតរបស់លោកដារ៉ា ដែលជាអ្នកបើកឡាន។ មួយរយៈក្រោយមក ចិត្រ មានទំនាស់ជាខ្លាំងជាមួយនឹងសមាជិកក្រុមហ៊ុនទាំងពីរនាក់ទៀត ដែលជាហេតុធ្វើឱ្យគាត់មិនអាចបន្តការរកស៊ីជាមួយភាគីទាំងពីរឲ្យបន្តទៀតបាន វាជាហេតុផលដែលពុំអាចជៀសវាងបាន ដែលតម្រូវឱ្យគាត់ត្រូវតែដកខ្លួនចេញពីសមាជិកក្រុមហ៊ុន។

ជាមួយគ្នានេះដែរ ក្នុងករណីដែលបានកំណត់អំឡុងពេលនៃអត្ថិភាព របស់ក្រុមហ៊ុន សមាជិកក្រុមហ៊ុននីមួយៗ អាចដកខ្លួនបានក្នុងករណីដែលពុំអាចជៀសវាងបាន[60]។ បានន័យថា ករណី ដែលកិច្ចសន្យាក្រុមហ៊ុនបានកំណត់ពីរយៈពេលនៃការតាំងនៅច្បាស់លាស់ សមាជិកក្រុមហ៊ុន នៅតែធ្វើការដកខ្លួនបានដោយស្ម័គ្រចិត្តដោយហេតុផលណាមួយដែលពុំអាចជៀសបាន។

---

[59] កថាខណ្ឌទី១ មាត្រា៧០៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[60] កថាខណ្ឌទី២ មាត្រា៧០៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ឧទាហរណ៍៖ ដា ឧត្តម និងចិត្រាជាជាងសំណង់ បានបង្កើតកិច្ចសន្យាក្រុមហ៊ុនមួយ ដោយចូលហ៊ុនគ្នាដេញថ្លៃ បាន គម្រោងសាងសង់សាលារៀន ដោយកិច្ចសន្យាក្រុមហ៊ុននេះ នឹងត្រូវកំណត់យករយៈពេល២ឆ្នាំ ដែលមានរយៈពេលស្មើនឹងដំណើរការនៃគម្រោង។ បន្ទាប់ពីដំណើរការបានប្រមាណមួយឆ្នាំ លោកដា បានជួបប្រទះនឹងបញ្ហាសេដ្ឋកិច្ចគ្រួសារធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ ដែលជាហេតុឱ្យគាត់សម្រេចចិត្តធ្វើការដកខ្លួនដោយស្ម័គ្រចិត្តចេញពីសមាជិកក្រុមហ៊ុន។ បន្ថែមពីលើនេះ ការដកខ្លួនដោយស្ម័គ្រចិត្តនេះអាចធ្វើទៅបាន ដោយសមាជិកដែលចង់ដកខ្លួន ត្រូវធ្វើការបង្ហាញឆន្ទៈទៅសមាជិកផ្សេងទៀត[61]។

### **១.៣.២. ការដកខ្លួនតាមច្បាប់**

បន្ថែមលើលក្ខខណ្ឌនៃការដកខ្លួនបានដោយស្ម័គ្រចិត្តខាងលើ ច្បាប់ក៏បានបញ្ញត្តិពីមូលហេតុដែលតម្រូវឱ្យសមាជិកក្រុមហ៊ុនធ្វើការដកខ្លួនតាមច្បាប់ពីកិច្ចសន្យាក្រុមហ៊ុន ដោយផ្អែកលើមូលហេតុដែលបានកំណត់ដូចជា៖ មរណភាព ធនក្ស័យ បានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ និងការលុបឈ្មោះ[62]។

នៅពេលដែលសមាជិកក្រុមហ៊ុនណាម្នាក់ បានទទួលមរណភាព នោះមានន័យថា បុគ្គលនោះលែងមានអត្ថិភាពជាសមាជិកក្រុមហ៊ុនក្នុងក្រុមហ៊ុននោះទៀតហើយ។ ជាការពិតណាស់ កិច្ចសន្យាក្រុមហ៊ុន អាចកើតមានឡើងបានលុះត្រាតែសមាជិកក្រុមហ៊ុនទាំងអស់មានការទុកចិត្តលើគ្នា និងឆន្ទៈរួមគ្នាក្នុងការសម្រេចគោលដៅរួមមួយ។ ដូច្នេះទំនុកចិត្តរវាងសមាជិកក្រុមហ៊ុន និងសមាជិកក្រុមហ៊ុនពិតជាមានសារៈសំខាន់ណាស់ក្នុងការចងកាតព្វកិច្ច ដើម្បីសម្រេចគោលដៅរួមនោះ។ ក្នុងនោះដែរប្រសិនបើឱ្យសន្តតិជនរបស់សមាជិកដែលទទួលមរណៈភាព ស្នងបន្តដោយស្វ័យប្រវត្តិនូវឋានៈជាសមាជិក នឹងអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់អត្ថិភាពនៃក្រុមហ៊ុន[63]។ ហេតុនេះហើយ សន្តតិជន មិនអាចស្នងបន្តនូវឋានៈជាសមាជិកក្រុមហ៊ុន បន្ទាប់ពីមរណៈភាពរបស់សមាជិកក្រុមហ៊ុនបានឡើយ ព្រោះទំនាក់ទំនងរវាងសន្តតិជន និងសមាជិកក្រុមហ៊ុនដទៃទៀតអាចទើបនឹងមានការចាប់ផ្តើម ដូចនេះ ការជឿជាក់របស់សមាជិកក្រុមហ៊ុនទៅលើសន្តតិជន ក៏មិនដូចគ្នាទៅនឹងការជឿជាក់របស់សមាជិកក្រុមហ៊ុន ដែលបានទទួលមរណៈភាពនោះឡើយ។ ផ្ទុយទៅវិញ ប្រសិនបើនៅក្នុងកិច្ចសន្យាក្រុមហ៊ុន បានកំណត់ជាមុនថាឱ្យសន្តតិជនរបស់សមាជិកក្រុមហ៊ុនស្នងបន្តនូវឋានៈជាសមាជិកនោះ ការស្នងបន្តនឹងត្រូវបានទទួលស្គាល់។ ដូច្នេះ មរណៈភាពនៃសមាជិកក្រុមហ៊ុននាំឱ្យមានការដកខ្លួនតាមច្បាប់។

---

[61] កថាខណ្ឌទី៣ មាត្រា៧០៩ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[62] មាត្រា៧១០ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[63] កថាខណ្ឌទី២ មាត្រា៧១០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ២០១០ ភាគ៣: គន្លឹះ ៥

នៅពេលដែលសមាជិកក្រុមហ៊ុនណាម្នាក់ជួបប្រទះបញ្ហាធនក្ស័យ ច្បាប់បានបញ្ញត្តិឲ្យសមាជិកនោះធ្វើការដកខ្លួនចេញពីសមាជិកក្រុមហ៊ុន ប៉ុន្តែដើម្បីការពារកាតព្វកិច្ចសងបំណុលរបស់សមាជិកធនក្ស័យនោះ ចំណែកភាគហ៊ុនរបស់បុគ្គលនោះត្រូវរក្សាទុកដើម្បីធ្វើការទូទាត់បំណុលរបស់សមាជិកធនក្ស័យ និងគ្មានការសន្យាពិសេសដែលអនុញ្ញាតឱ្យជនធនក្ស័យនៅជាសមាជិកក្នុងកិច្ចសន្យាក្រុមហ៊ុនបានទេ[64]។

បើសមាជិកក្រុមហ៊ុនណាម្នាក់ ត្រូវបានប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ សមាជិកក្រុមហ៊ុនរូបនោះ ត្រូវធ្វើការដកខ្លួនចេញពីក្រុមហ៊ុន ដើម្បីជៀសវាងការប៉ះពាល់ដល់ផលប្រយោជន៍ដល់ សមាជិកផ្សេងទៀត[65]។ ដូចដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីផងដែរថា ជនដែលស្ថិតនៅក្រោម អាណាព្យាបាលទូទៅ គឺជាជនដែលត្រូវបានកម្រិតសមត្ថភាព។ ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថាជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ[66]។ ជននៅក្រោមអាណាព្យាបាលទូទៅមិនមានសមត្ថភាពក្នុងការចុះកិច្ចសន្យាបានទេ ដោយហេតុថា ជននោះពុំមានការយល់ដឹងនូវសកម្មភាពរបស់ខ្លួនដែលបាន ធ្វើជាមួយភាគីម្ខាងទៀតឡើយ ហើយជននេះ ត្រូវប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ។ របបអាណាព្យាបាលទូទៅនេះ គឺជារបបមួយសម្រាប់ការពារសិទ្ធិដែលមានដូចជា ជីវិត រូបកាយ សេរីភាព ទ្រព្យសម្បត្តិជាដើមរបស់ជនដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យទាំងនេះ[67]។ ដូច្នេះ របបនេះ បានការពារផលប្រយោជន៍ដល់ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ពីការខូចខាតផ្សេងៗ ដែលបង្កដោយសកម្មភាពរបស់ខ្លួនជាមួយនឹងភាគីម្ខាងទៀត។

សមាជិកភាពរបស់សមាជិកក្រុមហ៊ុននីមួយៗ អាចត្រូវបានបាត់បង់តាមការបញ្ញត្តិនៃច្បាប់តាមរយៈការលុបឈ្មោះ។ ការលុបឈ្មោះ គឺជាការដកហូតលក្ខណៈសម្បត្តិជាសមាជិកក្រុមហ៊ុនរបស់សមាជិកណាម្នាក់ដោយការព្រមព្រៀងជាឯកច្ឆន្ទរបស់សមាជិកដទៃទៀត[68]។ ដូចដែលបានលើកឡើងមកថា ចំពោះក្រុមហ៊ុនដែលចាត់ទុកទំនុកចិត្ត គឺជាកត្តាសំខាន់ដែលចងសមាជិកក្រុមហ៊ុននីមួយៗ ប៉ុន្តែ ក្នុងករណីបាត់បង់ទំនុកចិត្តលើសមាជិកណាម្នាក់

[64] កថាខណ្ឌទី៣ មាត្រា៧១០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ២០១០ ភាគ៣: គន្លឹះ ៥
[65] កថាខណ្ឌទី៤ មាត្រា៧១០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ២០១០ ភាគ៣: គន្លឹះ ៥
[66] មាត្រា២៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[67] មាត្រា២៤ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី២០០៩ ភាគ១: គន្លឹះទី១-ទី៣
[68] កថាខណ្ឌទី១ មាត្រា៧១១ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

សមាជិកផ្សេងទៀតអាចមូលមតិគ្នាជាឯកច្ឆន្ទ ដោយផ្អែកលើមូលហេតុត្រឹមត្រូវ ដើម្បីដកសមាជិកភាពរបស់សមាជិកក្រុមហ៊ុនម្នាក់នោះចេញ។ ការលុបឈ្មោះនេះ អាចធ្វើទៅបានស្របច្បាប់ ដោយសមាជិកក្រុមហ៊ុនទាំងអស់ ត្រូវធ្វើការជូនដំណឹងទៅសមាជិកនោះ។ ការលុបឈ្មោះ នឹងគ្មានអានុភាព ដែលអាចតតាំងនឹងសមាជិកដែលត្រូវបានលុបឈ្មោះនោះទេ ប្រសិនបើសមាជិកទាំងអស់ពុំបានជូនដំណឹងទៅសមាជិកនោះ។ ជាមួយគ្នានេះផងដែរ បើសមាជិកដែលត្រូវបានលុបឈ្មោះនោះ ពុំយល់ព្រមក្នុងការសម្រេចចិត្តឱ្យ គេលុបឈ្មោះរបស់ខ្លួនសមាជិករូបនោះ អាចធ្វើការដាក់ពាក្យបណ្ដឹងទៅតុលាការបាន[69]។

**១.៤. ទ្រព្យធនរបស់ក្រុមហ៊ុន**

ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន គឺជាកម្មសិទ្ធិអវិភាគនៃសមាជិកក្រុមហ៊ុនទាំងអស់។ ដោយយោង តាមស្មារតីមាត្រា២០២នៃក្រមរដ្ឋប្បវេណី ក៏បានបញ្ញត្តិផងដែរពីនិយមន័យនៃកម្មសិទ្ធិអវិភាគថា ស្ថានភាពដែលបុគ្គលច្រើននាក់មានភាគចំណែកទៅលើទ្រព្យរួមមួយ ហៅថាកម្មសិទ្ធិអវិភាគ។ ក្នុងន័យនេះមានន័យថា ទ្រព្យសម្បត្តិក្រុមហ៊ុន គឺជាទ្រព្យរួមរបស់សមាជិកហ៊ុនទាំងអស់ ដែលមិនមែនជាកម្មសិទ្ធិផ្ដាច់មុខរបស់សមាជិកណាម្នាក់នោះទេ។

នៅក្នុងបរិបទនៃកិច្ចសន្យាក្រុមហ៊ុន សមាជិកក្រុមហ៊ុនត្រូវបានសន្មត់ថា មានសិទ្ធិស្មើគ្នាទៅលើកម្មសិទ្ធិអវិភាគលើទ្រព្យសម្បត្តិ ក្នុងករណីដែលមិនបានកំណត់ច្បាស់លាស់ពីភាគចំណែកនៃសិទ្ធិលើទ្រព្យសម្បត្តិនៅពេលដែលបង្កើតកិច្ចសន្យាក្រុមហ៊ុន[70]។ ផ្ទុយទៅវិញ ក្នុងករណីដែលសមាជិកក្រុមហ៊ុនទាំងអស់ បានកំណត់ពីភាគចំណែកនៃសិទ្ធិទៅលើទ្រព្យសម្បត្តិ នៅក្នុងក្រុមហ៊ុននៅពេលបង្កើតកិច្ចសន្យាក្រុមហ៊ុននោះ សមាជិកនីមួយៗ មានសិទ្ធិទៅលើទ្រព្យសម្បត្តិទៅតាមការដែលបានកំណត់នៅក្នុងកិច្ចសន្យានោះ។

កម្មសិទ្ធិអវិភាគនៅក្នុងខ្លឹមសារនៃកិច្ចសន្យាក្រុមហ៊ុន វាមានលក្ខណៈដោយឡែកពីកម្មសិទ្ធិអវិភាគនៃខ្លឹមសារទូទៅ ដោយហេតុថា នៅក្នុងខ្លឹមសារទូទៅ ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើអនុប្បទាន ឬដាក់ជាប្រាតិភោគនៃចំណែករបស់ខ្លួនបាន។ ម្ចាស់បំណុលនៃម្ចាស់កម្មសិទ្ធិអវិភាគនេះអាចរឹបអូសចំណែកនេះបាន[71]។ បន្ថែមលើនេះទៅទៀត ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចទាមទារឲ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគបានគ្រប់ពេលវេលា ប៉ុន្តែ ម្ចាស់កម្មសិទ្ធិអវិភាគអាចធ្វើកិច្ចសន្យា

[69] កថាខណ្ឌទី២ មាត្រា៧១១ សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី២០១០ ភាគ៣: គន្លឹះទី៥

[70] មាត្រា២០៣នៃក្រមរដ្ឋប្បវេណី សមភាពនៃចំណែកកម្មសិទ្ធិអវិភាគ "ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗត្រូវបានសន្មត់ថាស្មើគ្នា"

[71] មាត្រា២០៤ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ហាមមិនឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគក្នុងអំឡុងពេលមិនលើសពី៥ឆ្នាំបាន[72]។ ក្រឡេកទៅមើលខ្លឹមសារក្នុងកិច្ចសន្យាក្រុមហ៊ុនវិញ សមាជិកក្រុមហ៊ុនម្នាក់ៗ មិនអាចទាមទារឱ្យបែងចែកកម្មសិទ្ធិអវិភាគនោះបានឡើយ នៅពេលក្រុមហ៊ុននោះនៅមានអត្ថិភាព ដោយយោងទៅតាមកថាខណ្ឌទី២ មាត្រា៧០១ នៃក្រមរដ្ឋប្បវេណី ដែលបានបញ្ញត្តិថា សមាជិកក្រុមហ៊ុន ពុំអាចទាមទារឱ្យបែងចែកទ្រព្យសម្បត្តិក្រុមហ៊ុន នៅមុនពេលធ្វើការជម្រះបញ្ជីរបស់ក្រុមហ៊ុនបានឡើយ ប៉ុន្តែក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុនមានការព្រមព្រៀង ទោះបីជានៅមុនពេលធ្វើការជម្រះបញ្ជីក៏ដោយ ក៏អាចទាមទារឱ្យបែងចែកបានដែរ។

បានសេចក្តីថា សមាជិកទាំងអស់នៅតែអាចទាមទារឱ្យបែងចែកចំណែកនៃទ្រព្យសម្បត្តិរបស់ខ្លួននៅក្នុងក្រុមហ៊ុនបានមុនពេលជម្រះបញ្ជី ក្នុងករណីដែលសមាជិកផ្សេងទៀតមានការឯកភាព។ យ៉ាងណាមិញ ច្បាប់មិនអនុញ្ញាតឱ្យសមាជិកក្រុមហ៊ុនធ្វើការបែងចែកទ្រព្យសម្បត្តិនោះបានទេ ក្នុងករណីដែលក្រុមហ៊ុននៅជាប់កាតព្វកិច្ច ជាមួយនឹងតតិយជនក្នុងមុខរបររបស់ក្រុមហ៊ុន ពោលគឺត្រូវរង់ចាំរហូតដល់មានការជម្រះបញ្ជីរួចរាល់។[73] ម្យ៉ាងវិញទៀត សមាជិកក្រុមហ៊ុនមិនអាចធ្វើអនុប្បទានភាគដែលខ្លួនមាន ឱ្យទៅអ្នកដទៃបានឡើយ ដោយយោងតាមមាត្រា៧០១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា សមាជិកក្រុមហ៊ុនពុំអាចចាត់ចែងភាគដែលខ្លួនមានចំពោះទ្រព្យសម្បត្តិក្រុមហ៊ុននោះបានឡើយ។

ជាងនេះទៅទៀត នៅក្នុងខ្លឹមសារនៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីចំពោះមាត្រា២០២ ក៏បានកំណត់ផងដែរថា កម្មសិទ្ធិអវិភាគនៃ កិច្ចសន្យាក្រុមហ៊ុន មិនអាចចាត់ចែងភាគចំណែកបាន ហើយដែលមានលក្ខណៈខុសពីកម្មសិទ្ធិអវិភាគដែលមានចែងក្នុងមាត្រា២១១ និងមាត្រា២០៤នៃក្រមរដ្ឋប្បវេណី។

## ផ្នែកទី២ ការរំលាយកិច្ចសន្យាក្រុមហ៊ុន

រាល់កិច្ចសន្យាទាំងអស់រមែងតែងតែមានការរំលាយកើតឡើង ដោយផ្អែកតាមមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច។ កិច្ចសន្យាត្រូវបានរំលាយ បើសិនជាមានមូលហេតុសមស្របមួយចំនួនជាពិសេសក្នុងកិច្ចសន្យាក្រុមហ៊ុន សមាជិកក្រុមហ៊ុនអាចបង្កើត និងរំលាយទៅវិញបានដែរ។ ការរំលាយនៅក្នុងកិច្ចសន្យាក្រុមហ៊ុន មានដូចជា (១) លក្ខខណ្ឌនៃការរំលាយកិច្ចសន្យាក្រុមហ៊ុន (២) អានុភាពនៃការរំលាយកិច្ចសន្យាក្រុមហ៊ុន និង(៣) ការជម្រះបញ្ជី។

[72] កថាខណ្ឌទី១ មាត្រា២១១ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[73] កថាខណ្ឌទី៣ មាត្រា៧០១ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

## ២.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យាក្រុមហ៊ុន

ចំពោះលក្ខខណ្ឌនៃការរំលាយកិច្ចសន្យាត្រូវអនុលោមទៅតាមច្បាប់ត្រង់ចំនុចដែលមានចែងទាក់ទងនឹងកិច្ចសន្យាក្រុមហ៊ុន ហើយដោយហេតុថា ក្រុមហ៊ុន ត្រូវបានបង្កើតឡើងក្រោមរូបភាពជាកិច្ចសន្យាក្រុមហ៊ុន ដូចនេះ ការរំលាយក្រុមហ៊ុនអាចធ្វើទៅបានត្រូវស្របទៅតាមលក្ខខណ្ឌមួយចំនួនដូចតទៅ៖

- ការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុន ឬអលទ្ធភាពក្នុងការបំពេញកិច្ចការនោះ
- បើមានការព្រមព្រៀងពីសមាជិកទាំងអស់ របស់សមាជិកក្រុមហ៊ុន
- បើនៅសល់សមាជិកក្រុមហ៊ុនតែម្នាក់
- អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុនត្រូវបានបញ្ចប់[74]។

### ២.១.១. ការបញ្ចប់កម្មវត្ថុរបស់ក្រុមហ៊ុន ឬអលទ្ធភាពក្នុងការបំពេញកិច្ចការ

ជាទូទៅ កិច្ចសន្យាក្រុមហ៊ុនត្រូវបានបង្កើតឡើងដើម្បីសម្រេចនូវកម្មវត្ថុមួយ ឬច្រើនដែលបានកំណត់ដោយសមាជិកក្រុមហ៊ុនក្នុងពេលបង្កើត។ នៅពេលកិច្ចការដែលជាកម្មវត្ថុមួយឬច្រើននោះ ត្រូវបានសម្រេចបញ្ចប់ដោយជោគជ័យ ក្រុមហ៊ុនអាចនឹងត្រូវបានរំលាយទៅវិញ។

ឧទាហរណ៍១៖ លីតា និងដេវីត មានបំណងចង់រកមូលនិធិ ដើម្បីជួយដល់មណ្ឌលកុមារកំព្រាមួយកន្លែង ដោយពួកគេបានបង្កើតកិច្ចសន្យាក្រុមហ៊ុនមួយ គឺចូលហ៊ុនគ្នាលក់ទឹកបរិសុទ្ធឱ្យអស់ចំនួន២០០កេស ហើយលុយ ដែលចំណេញពីការលក់ នឹងយកទៅឧបត្ថម្ភដល់មណ្ឌលកុមារកំព្រានោះ។ ត្រង់ចំណុចនេះ កិច្ចសន្យាក្រុមហ៊ុន នឹងត្រូវបានរំលាយ នៅពេលពួកគេលក់ទឹកបរិសុទ្ធអស់ចំនួន២០០កេស។

ម៉្យាងវិញទៀត កិច្ចសន្យាក្រុមហ៊ុន នឹងត្រូវបានរំលាយផងដែរ ប្រសិនបើសមាជិកក្រុមហ៊ុនមិនមានលទ្ធភាពក្នុងការធ្វើកិច្ចការងារដែលជាកម្មវត្ថុនៃកិច្ចសន្យា។

ឧទាហរណ៍២៖ បញ្ញា និងសីហា បានបង្កើតកិច្ចសន្យាក្រុមហ៊ុន ដោយសន្យាគ្នាបង្កើតកម្មវិធីកុំព្យូទ័រមួយដើម្បីលក់។ ក្រោយពីបានអនុវត្តកិច្ចការនេះមួយរយៈក្រោយមក បញ្ញា យល់ថា ខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីបន្តធ្វើកម្មវិធីកុំព្យូទ័រនេះទេ ជាហេតុនាំឱ្យគាត់សុំដកខ្លួនពីកិច្ចសន្យា។

ហេតុដូច្នេះ កិច្ចសន្យាក្រុមហ៊ុន ក៏ត្រូវបានរំលាយដោយសមាជិកក្រុមហ៊ុនម្នាក់អលទ្ធភាពក្នុងការបំពេញកិច្ចការនេះ។

[74] កថាខណ្ឌទី១ មាត្រា៧១៣ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

### ២.១.២. ការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន

ជាការពិតណាស់ កិច្ចសន្យាក្រុមហ៊ុនអាចកើតមានទៅបានលុះត្រាតែមានសមាជិកពីរ ឬច្រើននាក់មានឆន្ទៈរួម ដើម្បីសម្រេចគោលដៅរួមគ្នា។ មិនត្រឹមតែប៉ុណ្ណោះកិច្ចសន្យានេះ អាចមានសុពលភាពទៅបាន លុះត្រាតែសំណើ និងស្ទីការរបស់សមាជិកទាំងអស់ត្រូវគ្នាផងដែរ។ នៅពេលដែលសំណើរ និងស្ទីការត្រូវគ្នាសមាជិកទាំងអស់ ធ្វើការព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាក្រុមហ៊ុនឡើង។ យ៉ាងណាមិញ ការរំលាយកិច្ចសន្យាក្រុមហ៊ុន ពុំមានលក្ខណៈខុសគ្នាពីការបង្កើត កិច្ចសន្យាក្រុមហ៊ុនប៉ុន្មាននោះទេ គឺកិច្ចសន្យាក្រុមហ៊ុនអាចត្រូវរំលាយ បើគូភាគីទាំងអស់ឯកភាពគ្នាក្នុងការរំលាយកិច្ចសន្យានេះចោល ដោយហេតុផលផ្សេងៗ។

### ២.១.៣. សមាជិកក្រុមហ៊ុនតែម្នាក់

ជាធម្មតា គ្មានកិច្ចសន្យាណាមួយដែលកើតឡើងដោយបុគ្គលតែម្នាក់នោះទេ គឺវាអាចកើតឡើងដោយមានភាគីចាប់ពីពីរនាក់ឡើងទៅ។ ហេតុដូច្នេះហើយ ប្រសិនបើនៅពេលណាមួយសមាជិកក្រុមហ៊ុនទាំងអស់ត្រូវបានដកខ្លួន ដោយនៅសល់សមាជិកតែម្នាក់នោះ វាត្រូវបានបាត់បង់លក្ខណៈជាក្រុមហ៊ុន ព្រោះកិច្ចសន្យាក្រុមហ៊ុន សំដៅទៅលើការកិច្ចសន្យាដែលបង្កើតជាក្រុម ក្នុងករណីនេះ ច្បាប់ត្រូវបានកំណត់ថា កិច្ចសន្យាក្រុមហ៊ុននឹងត្រូវបានរំលាយដោយកង្វះសមាជិក។ មិនថាតែការបង្កើត និងការរំលាយនោះទេ បើសមាជិកក្រុមហ៊ុននៅសល់តែមួយរូបនោះ ក្រុមហ៊ុនពុំអាចបន្តដំណើរការបាននោះទេ ដោយសារតែកង្វះភាគីនៃកិច្ចសន្យា។

### ២.១.៤. អំឡុងពេលនៃអត្ថិភាព របស់ក្រុមហ៊ុនដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុនត្រូវបានបញ្ចប់

អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន មានន័យថានៅក្នុងអំឡុងពេលដែលបង្កើតកិច្ចសន្យាក្រុមហ៊ុន សមាជិកទាំងអស់ បានកំណត់ជាក់លាក់ពីអត្ថិភាពរបស់ក្រុមហ៊ុន(អាយុកាលក្រុមហ៊ុន) ហេតុដូនេះហើយនៅពេលការកំណត់អត្ថិភាពរបស់ក្រុមហ៊ុននោះបានឈានចូលមកដល់ក្រុមហ៊ុននឹងត្រូវបានរំលាយ។

ឧទាហរណ៍: កិច្ចសន្យាក្រុមហ៊ុនមួយបានបង្កើតឡើង ដោយសមាជិកក្រុមហ៊ុនទាំងអស់បានព្រមព្រៀងគ្នាកំណត់ពីអត្ថិភាពរបស់ក្រុមហ៊ុនរយៈពេល៣ឆ្នាំ។ ដូច្នេះ នៅចន្លោះរយៈពេល៣ឆ្នាំក្រុមហ៊ុននៅមានអត្ថិភាពបើកដំណើរការធម្មតា ប៉ុន្តែដល់ពេលកំណត់មកដល់គ្រប់រយៈពេល៣ឆ្នាំកិច្ចសន្យាក្រុមហ៊ុននឹងត្រូវបានរំលាយ។

ហេតុដូច្នេះ កិច្ចសន្យាក្រុមហ៊ុននឹងត្រូវបានរំលាយ នៅពេលក្រុមហ៊ុនដល់អត្ថិភាពត្រូវបានបញ្ចប់ ដោយស្របទៅតាមការកំណត់របស់សមាជិកក្រុមហ៊ុនក្នុងកិច្ចសន្យា។

## ២.២. អានុភាពនៃការរំលាយកិច្ចសន្យា

កិច្ចសន្យាបង្កើតឱ្យមាន ចំណងគតិយុត្តរវាងភាគី និងភាគី ហេតុដូច្នេះ ហើយច្បាប់បាន កំណត់អំពី អានុភាពនៃការរំលាយកិច្ចសន្យា។ នៅពេលរំលាយកិច្ចសន្យា មានគំនិតពីរបញ្ជាក់ពី អានុភាពនៃការរំលាយកិច្ចសន្យា ដែលត្រូវបានលើកយកមកពិភាក្សា ដោយគំនិតទី១ និយាយពី ការរំលាយកិច្ចសន្យាមានអានុភាពប្រតិសកម្ម និងគំនិតទី២ និយាយពីការរំលាយកិច្ចសន្យាមិនមាន អានុភាពប្រតិសកម្មឡើយ។ ការរំលាយកិច្ចសន្យាមានអានុភាពប្រតិសកម្ម មានន័យថានៅក្នុង ករណីដែលកិច្ចសន្យាត្រូវបានរំលាយ វាត្រូវចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង។ ដូច្នេះ ប្រសិន បើភាគី បានទទួលតាវកាលិកនៅមុនពេលរំលាយ គាត់ត្រូវធ្វើបដិទានឡើងវិញទៅស្ថានភាពដើម របស់ភាគីម្ខាងទៀត ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ[75]។ នៅក្នុងករណីសេចក្តីចម្រើន ដោយឥតហេតុ ជាទូទៅត្រូវបានកម្រិតត្រឹមផលប្រយោជន៍ដែលមាន[76]។ ម្យ៉ាងវិញទៀត ការរំលាយ កិច្ចសន្យាមិនមានអានុភាពប្រតិសកម្មត្រូវបានចាត់ទុកថា សិទ្ធិលើបំណុល និងកាតព្វកិច្ចដើមត្រូវ ផ្លាស់ប្តូរទៅជាសិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់គូភាគី បានសេចក្តីថា បញ្ញត្តិនៃការរំលាយកិច្ចសន្យា ត្រូវយកមកអនុវត្តនៅពេលអនាគត ហើយទាក់ទងនឹងកាតព្វកិច្ច ដែលមិនទាន់ត្រូវបានអនុវត្ត គឺមិនមានអត្ថិភាពទៀតទេនៅពេលអនាគត។ ផ្ទុយទៅវិញ កាតព្វកិច្ច ដែលបានអនុវត្តហើយ មិនអាចក្លាយជាសេចក្តីចម្រើនដោយឥតហេតុទេ[77]។

យោងតាមខ្លឹមសារនៃការបកស្រាយខាងលើ កិច្ចសន្យាក្រុមហ៊ុន បង្កើតឱ្យមានចំណងគតិ យុត្តរវាងសមាជិកក្រុមហ៊ុនទាំងអស់ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណី មាត្រា ៧១៤ បានបញ្ញត្តិពីភាព គ្មានប្រតិសកម្មនៃការរំលាយ "ការរំលាយក្រុមហ៊ុន ពុំមានអានុភាពប្រតិសកម្មឡើយ"។ យ៉ាងណា ក៏ដោយ ការអនុវត្តប្រតិសកម្មនូវការរំលាយកិច្ចសន្យាក្រុមហ៊ុន នាំឱ្យមានភាពស្មុគស្មាញ និង ឧបសគ្គជាច្រើនកើតឡើងនៅពេលដែលសមាជិកណាម្នាក់ធ្វើការទាមទារនូវសិទ្ធិ និងកាតព្វកិច្ច ដែលបានកើតឡើងមុនពេលរំលាយកិច្ចសន្យាក្រុមហ៊ុន ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ របស់សមាជិកក្រុមហ៊ុនផ្សេងទៀត ឬតតិយជន។ ហេតុនេះហើយ ទើបអានុភាពនៃការរំលាយ កិច្ចសន្យា ក្រុមហ៊ុន មិនមានភាពប្រតិសកម្មឡើយ ពោលគឺវាមានអានុភាពឆ្ពោះទៅអនាគតតែ ប៉ុណ្ណោះ។

[75] ចំណុច ៥.១ កថាខណ្ឌទី១ ទំព័រ៤៤ ភាគ៣ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី បោះពុម្ពក្នុងខែ មីនា ឆ្នាំ២០១២
[76] កថាខណ្ឌទី១ មាត្រា៧៣៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
[77] ចំណុច ៥.១ កថាខណ្ឌទី២ ទំព័រ៤៦ ភាគ៣ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី បោះពុម្ពក្នុងខែ មីនា ឆ្នាំ២០១២

### ២.៣. ការជម្រះបញ្ជី

ការជម្រះបញ្ជីក្រុមហ៊ុន គឺជានីតិវិធីចុងក្រោយនៃការទូទាត់ក្នុងការរំលាយក្រុមហ៊ុន។ ដើម្បីធ្វើការជម្រះបញ្ជី សមាជិកក្រុមហ៊ុនទាំងអស់ ត្រូវស្រុះស្រួលគ្នាក្នុងការចាត់ចែងកិច្ចការជម្រះបញ្ជី។ ប៉ុន្តែ ក្នុងករណីដែលសមាជិកក្រុមហ៊ុនទាំងអស់ មានគំនិតមិនស្របគ្នា ក្នុងការចាត់ចែងកិច្ចការនេះ សមាជិកក្រុមហ៊ុនចាំបាច់ត្រូវឯកភាពគ្នាក្នុងការជ្រើសតាំងអ្នកជម្រះបញ្ជី ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា៧១៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ កំណត់ថា ប្រសិនបើក្រុមហ៊ុន ត្រូវបានរំលាយ ការជម្រះបញ្ជី ត្រូវធ្វើដោយសហការគ្នារវាងសមាជិកទាំងអស់របស់ក្រុមហ៊ុន ឬដោយអ្នកជម្រះបញ្ជីដែលត្រូវបានជ្រើសតាំងដោយសមាជិកក្រុមហ៊ុន។ ក្នុងចំនុចនេះត្រូវបានបែងចែកជា៣ គឺអ្នកជម្រះបញ្ជី មុខងារ និងសិទ្ធិអំណាចអ្នកជម្រះបញ្ជី និងការលាឈប់ និងការបញ្ឈប់អ្នកជម្រះបញ្ជី។

#### ២.៣.១. អ្នកជម្រះបញ្ជី

ជាដំបូង អ្នកជម្រះបញ្ជីជាសមាជិកក្រុមហ៊ុនទាំងអស់ដែលសហការគ្នាធ្វើការជម្រះបញ្ជី ឬអាចជ្រើសតាំងអ្នកជម្រះបញ្ជីដោយសមាជិកក្រុមហ៊ុន។ ប្រសិនបើ មិនមានការកំណត់ជាមុននៅក្នុងកិច្ចសន្យាក្រុមហ៊ុនអំពីការជ្រើសរើសអ្នកជម្រះបញ្ជី នោះការជ្រើសរើសអ្នកជម្រះបញ្ជី ត្រូវធ្វើឡើងដោយសម្លេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមហ៊ុន[78]។ មួយវិញទៀត អ្នកជម្រះបញ្ជីអាចត្រូវបានជ្រើសចេញពីចំណោមសមាជិកក្រុមហ៊ុន បើមានការព្រមព្រៀងពីសមាជិកទាំងអស់។

#### ២.៣.២. មុខងារ និងសិទ្ធិអំណាចអ្នកជម្រះបញ្ជី

ក្នុងករណីដែលក្រុមហ៊ុនជ្រើសរើសយកការជម្រះបញ្ជី ដោយពឹងផ្អែកលើអ្នកជម្រះបញ្ជី នោះសិទ្ធិក្នុងការកាន់កាប់ និងចាត់ចែងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនត្រូវប្រគល់ឱ្យអ្នកជម្រះបញ្ជី។ អ្នកជម្រះបញ្ជី មានសិទ្ធិពេញលេញក្នុងការចាត់ចែង និងទូទាត់លើការជម្រះបញ្ជី។ អ្នកជម្រះបញ្ជី មានសិទ្ធិអំណាចត្រឹមតែធ្វើសកម្មភាពដើម្បីជម្រះបញ្ជីប៉ុណ្ណោះ។ ក្នុងនោះផងដែរ ករណីដែលមានអ្នកជម្រះបញ្ជីច្រើនរូប ការអនុវត្តកិច្ចការរបស់អ្នកជម្រះបញ្ជី មានលក្ខណៈដូចគ្នា ទៅនឹងវិធីអនុវត្តកិច្ចការ[79]។ អ្នកជម្រះបញ្ជីមានសិទ្ធិយកទ្រព្យសម្បត្តិ ដែលនៅសេសសល់ក្នុង ក្រុមហ៊ុនទៅធ្វើការទូទាត់បំណុលផ្សេងៗដូចជា បង់ពន្ធជូនរដ្ឋ និងបំណុលផ្សេងៗទៀតដែលក្រុមហ៊ុនជាប់ពាក់ព័ន្ធ។ ទ្រព្យធនដែលនៅសល់បន្ទាប់ពីការជម្រះបញ្ជី ត្រូវធ្វើការបែងចែកឱ្យ សមាជិកក្រុមហ៊ុនទៅតាមសមាមាត្រហ៊ុនដែលសមាជិកក្រុមហ៊ុនបានវិនិយោគ[80]។

---

[78] កថាខណ្ឌទី២ មាត្រា៧១៥ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[79] មាត្រា៧១៦ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[80] កថាខណ្ឌទី២ មាត្រា៧១៨ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ម្យ៉ាងអ្នកជម្រះបញ្ជី នៅក្នុងកិច្ចសន្យាក្រុមហ៊ុន មានមុខងារ និងសិទ្ធិអំណាចដូចគ្នាទៅនឹងអ្នកជម្រះបញ្ជីរបស់ក្រុមហ៊ុនដែលជានីតិបុគ្គល ដូចដែលបានបញ្ញត្តិក្នុងកថាខណ្ឌទី១ មាត្រា៧១៨ នៃក្រមរដ្ឋប្បវេណី ពោលគឺអ្នកជម្រះបញ្ជីនៅក្នុងចំណុចនេះ មានមុខងារ និងសិទ្ធិអំណាចដូចមានចែង ក្នុងមាត្រា៧១ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះ អ្នកជម្រះបញ្ជី មានមុខងារ និងសិទ្ធិអំណាចដូចខាងក្រោម[81]៖

- បំពេញបង្ហើយនូវកិច្ចការបច្ចុប្បន្នរបស់សមាជិកក្រុមហ៊ុន
- ប្រមូលសិទ្ធិលើបំណុល និងសងកាតព្វកិច្ច
- ប្រគល់ទ្រព្យសម្បត្តិដែលនៅសេសសល់។

**២.៣.៣. ការលាឈប់ និងការបញ្ឈប់អ្នកជម្រះបញ្ជី**

ក្នុងពេលដែលអ្នកជម្រះបញ្ជីបានប្រព្រឹត្តអំពើដែលខុសពីឆន្ទៈ របស់សមាជិកក្រុមហ៊ុនទាំងអស់ អ្នកជម្រះអាចនឹងត្រូវបញ្ឈប់ដោយសម្លេងលើសពីពាក់កណ្តាលរបស់សមាជិកទាំងអស់ ក្នុងករណីដែលបានព្រមព្រៀងគ្នាជ្រើសតាំងអ្នកជម្រះបញ្ជី ពីក្នុងចំណោមសមាជិកក្រុមហ៊ុននោះ[82]។ ផ្ទុយមកវិញ បើរកឃើញថាអ្នកជម្រះបញ្ជីពុំមានកំហុសលើការជម្រះបញ្ជីទេ អ្នកជម្រះបញ្ជី ពុំអាចលាឈប់ ឬត្រូវបញ្ឈប់បានឡើយ។

[81] មាត្រា៧១៨ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[82] មាត្រា ៧១៧ ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

# សេចក្តីសន្និដ្ឋាន

កិច្ចសន្យាក្រុមហ៊ុន គឺជាសកម្មភាពដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ប៉ុន្តែសម្រាប់ការអនុវត្តមានជាយូរមកហើយ គ្រាន់តែគេពុំស្គាល់ថាជាសញ្ញាណគតិយុត្តនៃ «កិច្ចសន្យាក្រុមហ៊ុន»នេះ។ ដូច្នេះប្រសិនបើមានវិវាទកើតឡើងអំពីការចូលហ៊ុនគ្នាបែបនឹង ពួកគេមិនដឹងថាគួរយកអ្វីមកដោះស្រាយឡើយ ដោយឡែកសកម្មភាពដែលពួកគេអនុវត្តគឺបាន បំពេញលក្ខខណ្ឌរបស់កិច្ចសន្យាក្រុមហ៊ុន ហេតុនេះហើយនៅពេលមានវិវាទកើតឡើង ពួកគេត្រូវយកសញ្ញាណគតិយុត្ត ដែលមានចែងត្រង់កិច្ចសន្យាក្រុមហ៊ុននេះមកអនុវត្តផងដែរ។ ក្រោយពីបានធ្វើការស្រាវជ្រាវទៅលើប្រធានបទ «កិច្ចសន្យាក្រុមហ៊ុន» នេះរួចមកឃើញថា កិច្ចសន្យា ប្រភេទនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងវិស័យ ទំនាក់ទំនងឯកជន ជាពិសេសក្នុង ដំណើរនៃការអនុវត្តកិច្ចការអាជីវកម្មដែលគូភាគីចូលទុនគ្នា ដើម្បីសម្រេចនូវឆន្ទៈរួមមួយ និងគុណប្រយោជន៍ជាការចែករំលែកចំណេះដឹង សម្រាប់សិស្សប្អូនៗជំនាន់ក្រោយក្នុងការ សិក្សាស្រាវជ្រាវ ផងដែរ។ ម្យ៉ាងវិញទៀត គឺបានផ្តល់ចំណេះដឹងដល់ ប្រជាពលរដ្ឋទូទៅដែលមាន បំណងចង់ ចូលហ៊ុនសហការគ្នារកស៊ីអាចអាចបង្កើតក្រុមហ៊ុនបាន។ ជាក់ស្តែងបុគ្គលមួយចំនួនយល់ថា កិច្ចសន្យាក្រុមហ៊ុនជាកិច្ចសន្យាបង្កើតក្រុមហ៊ុនដែលអនុលោមតាមច្បាប់ពាណិជ្ជកម្ម ផ្ទុយមកវិញ កិច្ចសន្យាក្រុមហ៊ុននេះ ជាកិច្ចសន្យាបង្កើតនូវក្រុមហ៊ុន ឬជា ក្រុមដែលគ្មានការរៀបចំ លក្ខណៈជានីតិបុគ្គល ហើយស្ថិតក្នុងបរិបទក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ប៉ុណ្ណោះ។ ហេតុដូច្នេះយើងក៏បានបកស្រាយពីលំហូរនៃការបង្កើតរហូតដល់ការរំលាយកិច្ចសន្យា។

ជំហានដំបូងត្រូវយល់ថា កិច្ចសន្យាក្រុមហ៊ុន គឺជាប្រភេទកិច្ចសន្យាមួយដែលមានលក្ខណៈសាមញ្ញសម្រាប់ចងនូវសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីដែលមានបំណងចូលហ៊ុនគ្នាក្នុងការវិនិយោគទៅលើមុខរបរណាមួយដែលជាឆន្ទៈរួមរបស់គូភាគី នៃកិច្ចសន្យានោះ។ គោលការណ៍ក្នុងការបង្កើតកិច្ចសន្យាក្រុមហ៊ុន ត្រូវធ្វើឡើងដោយគោរពទៅតាម គោលការណ៍លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ ដែលមានលក្ខណៈដូចគ្នាទៅនឹងកិច្ចសន្យាផ្សេងៗទៀតដែរ ពោលគឺត្រូវគោរពតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីផងដែរ ដើម្បីការពារផលប្រយោជន៍របស់គូភាគីនៃកិច្ចសន្យា (សមាជិកក្រុមហ៊ុន) នៅពេលដែលមានវិវាទកើតឡើង។ រួមជាមួយគ្នានេះ កិច្ចសន្យាក្រុមហ៊ុន មិនត្រឹមតែបានកំណត់ពីលក្ខខណ្ឌសុពលភាព នៃការបង្កើតកិច្ចសន្យាប៉ុណ្ណោះទេ តែវាថែមទាំងបានកំណត់ពីសមត្ថភាព ក្នុងការចុះកិច្ចសន្យា ថាតើជនណាខ្លះដែលមានសមត្ថភាពក្នុងការចុះកិច្ចសន្យានោះ។ ការបង្កើតកិច្ចសន្យាក្រុមហ៊ុន គឺត្រូវបានកំណត់ទៅតាមគោលបំណងរបស់សមាជិកក្រុមហ៊ុននីមួយៗដោយសហការគ្នា ដូច្នេះ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន គឺជាកម្មសិទ្ធិ

អវិភាគ ដែលជាទ្រព្យរួមគ្នារបស់សមាជិកក្រុមហ៊ុនទាំងអស់។ បន្ថែមពីនេះទៀត កាតព្វកិច្ចដែលកើតឡើងដោយកិច្ចការរបស់ក្រុមហ៊ុន គឺជាកាតព្វកិច្ច ដែលសមាជិកក្រុមហ៊ុនទាំងអស់ត្រូវមានសាមគ្គីភាពគ្នា ក្នុងការទទួលខុសត្រូវចំពោះកាតព្វកិច្ចដែលខ្លួនជាប់ ហើយនៅពេលដែលទ្រព្យរបស់ក្រុមហ៊ុនពុំអាចសងគ្រប់កាតព្វកិច្ចដល់ម្ចាស់បំណុល ដូច្នេះត្រូវសងដោយទ្រព្យដោយឡែករបស់សមាជិកនីមួយៗ។ ម្យ៉ាងវិញទៀត កិច្ចសន្យាក្រុមហ៊ុន ក៏បានកំណត់ពីលក្ខខណ្ឌមួយចំនួននៃការរំលាយផងដែរ ដើម្បីការពារប្រយោជន៍គូភាគីដែលក្នុងនោះ នៅពេលមានការរំលាយកិច្ចសន្យាត្រូវមានការជម្រះបញ្ជីនៅដំណាក់កាលបញ្ចប់។

សរុបជារួមមក ដោយមើលឃើញកាលានុវត្តភាពនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នស្របពេលដែលប្រទេសមានសន្តិភាព និងការអភិវឌ្ឍន៍ ការបង្កើតកិច្ចសន្យាក្រុមហ៊ុនដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ងាយស្រួលក្នុងការបង្កើត និងរំលាយ ដោយសារតែក្រុមហ៊ុន ដែលបង្កើតតាមរយៈកិច្ចសន្យានេះ មិនត្រូវតម្រូវឲ្យមានការចុះបញ្ជី ហេតុផលគឺវាមិនមែនជានីតិបុគ្គលដែលច្បាប់តម្រូវឲ្យមានការចុះបញ្ជី។

តែទោះបីជាយ៉ាងនេះក៏ដោយ មានចំណុច និងសកម្មភាពមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចសន្យាក្រុមហ៊ុន នៅមានចំណុចប្រឈមនៅឡើយ៖

- នៅក្នុងមាត្រា៦៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងសេចក្តីកំណត់មាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ពុំបានកំណត់ឱ្យច្បាស់លាស់ និងឱ្យដាច់ស្រេចពីសញ្ញាណគតិយុត្ត របស់កិច្ចសន្យាក្រុមហ៊ុននេះទេ។ ជាពិសេសមាត្រានេះមានលក្ខណៈស្រពិចស្រពិល ដោយធ្វើឱ្យភាពមិនច្បាស់លាស់ ទៅលើសញ្ញាណគតិយុត្តិរបស់វា ថាតើកិច្ចសន្យានេះមានលក្ខណៈ ជានីតិបុគ្គល ឬមិនមានលក្ខណៈជានីតិបុគ្គល។
- ក្នុងនោះផងដែរ នៅក្នុងច្បាប់ពុំបានចែងច្បាស់ពីការប្រែប្រួលសញ្ញាណគតិយុត្តរបស់កិច្ចសន្យាក្រុមហ៊ុននេះ ថាតើវាអាចផ្លាស់ប្តូរសញ្ញាណគតិយុត្តិទៅជានីតិបុគ្គលបានដែរ ឬទេ? បើវាអាចផ្លាស់ប្តូរបាន តើវាតម្រូវឱ្យមានលក្ខខណ្ឌចាំបាច់អ្វីខ្លះ ដើម្បីអនុវត្ត និងធ្វើការកែប្រែសញ្ញាណគតិយុត្តនោះ។ ហើយវាអាចប្រែក្លាយខ្លួនជាប្រភេទនីតិបុគ្គលអ្វី?

នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ការជម្រះបញ្ជី ច្បាប់មិនបានបង្ហាញច្បាស់លាស់ថាតើការជ្រើសតាំងអ្នកជម្រះបញ្ជីដោយសមាជិកក្រុមហ៊ុនគួរជាបុគ្គលណាខ្លះ ឬអាចជ្រើសរើសស្របតាមការជម្រះបញ្ជីរបស់នីតិបុគ្គលដែរឬទេ?

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ នូវរាល់បទដ្ឋានគតិយុត្តដែលទាក់ទងនឹងសិទ្ធិ និងករណីយកិច្ច រួមទាំងលក្ខខណ្ឌផ្សេងៗទៀត ដែលទាក់ទងនឹង **"កិច្ចសន្យាក្រុមហ៊ុន"** រួចមក យើងសង្កេតឃើញថាវាមានភាពល្អប្រសើរដោយសារតែ កិច្ចសន្យាក្រុម ដ៏សមស្រប ដើម្បីធ្វើការគ្រប់គ្រងនូវហ៊ុន គឺជាប្រភេទកិច្ចសន្យាដ៏សាមញ្ញមួយ យ៉ាងណាមិញ វាក៏មានប្រព័ន្ធច្បាប់មួយសកម្មភាពនានាជុំវិញកិច្ចសន្យានេះ។ ពោលគឺនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គន្ថីយ៥ ជំពូក១១ ដែលបានបញ្ញត្តិពី កិច្ចសន្យាក្រុមហ៊ុននេះ។ ហើយលក្ខខណ្ឌផ្សេងៗនៃកិច្ចសន្យានេះ ក៏ត្រូវអនុវត្តតាមបញ្ញត្តិដែលពាក់ព័ន្ធនានានៅក្នុងក្រមរដ្ឋប្បវេណីផងដែរ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ យើងខ្ញុំសំណូមពរ និងផ្តល់អនុសាសន៍មួយចំនួនដូចជា៖

- ដោយយោងតាមបញ្ហាដែលបានលើកឡើងខាងលើ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ គួរជំរុញឱ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅលើផ្នែកទ្រឹស្តី និងការអនុវត្តពីប្រភេទនៃកិច្ចសន្យាដល់បុគ្គលដែលសិក្សាផ្នែកច្បាប់ និងប្រជាជនទូទៅឱ្យកាន់តែយល់ច្បាស់ពីប្រយោជន៍នៃការបង្កើតកិច្ចសន្យាដូចជា កិច្ចសន្យាក្រុមហ៊ុននេះជាដើម។ លើសពីនេះ ក្រសួងគប្បីយកចិត្តទុកដាក់បន្ថែម តាមរយៈការលើកទឹកចិត្តដល់សាស្ត្រាចារ្យ បុគ្គល ដែលមានសមត្ថភាពក្នុងការចែករំលែកចំណេះដឹងផ្នែករដ្ឋប្បវេណី ឱ្យកាន់តែច្បាស់លាស់ទៅលើកិច្ចសន្យាប្រភេទនេះ។
- បន្ថែមពីនេះ គួរតែមានលិខិតបទដ្ឋានគតិយុត្តមួយដើម្បីបន្ថែមទៅលើចំនុចដែលខ្វះខាតទៅលើសញ្ញាណគតិយុត្តរបស់កិច្ចសន្យាក្រុមហ៊ុននេះផងដែរ។ ជាពិសេស ទៅលើការជម្រះបញ្ជីគួរតែកំណត់ឱ្យបានច្បាស់ពីបុគ្គលដែលត្រូវជ្រើសតាំងជាអ្នកជម្រះបញ្ជី ដើម្បីងាយស្រួលដល់ភាគីនៃកិច្ចសន្យាក្រុមហ៊ុនជ្រើសតាំងនៅពេលដែលមានការរំលាយ។
- យ៉ាងណាមិញ ចំពោះបុគ្គលដែលមានបំណងរកស៊ីបណ្តាក់ទុន ជាមួយបុគ្គលផ្សេងទៀតគួរពិភាក្សាជាមួយអ្នកមានវិជ្ជាជីវៈ ក្នុងការបង្កើតកិច្ចសន្យាក្រុមហ៊ុន ដែលមានលក្ខណៈគតិយុត្តដើម្បីឱ្យការធ្វើអាជីវកម្មមានទំនុកចិត្ត និងសុវត្ថិភាពនៅពេលដែលមានបញ្ហារវាងបុគ្គលកើតឡើង។

យើងខ្ញុំ សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះការយកចិត្តទុកដាក់ ក្នុងការអានសារណារបស់យើងខ្ញុំតាំងពីដើមរហូតដល់ចប់ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះ នឹងអាចជួយបន្ថែមទៅលើចំណេះដឹងដល់មត្តិអ្នកអានដែលយល់កន្លងមក។

# ឯកសារយោង

- **បទដ្ឋានគតិយុត្ត**

- ក្រមរដ្ឋប្បវេណី២០០៧នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ១៩២០ (និរាករណ៍)
- ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

- **សៀវភៅ និងឯកសារផ្សេងៗ**

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី បោះពុម្ពលើកទី១ ឆ្នាំ២០១០
- សេចក្តីពន្យល់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ១ ដល់ភាគ៦ បោះពុម្ពនៅក្នុងខែមីនា ឆ្នាំ២០១២
- សន្ទានុក្រមរដ្ឋប្បវេណី បោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧។
- ជិន វណ្ណារ៉ា រៀបរៀងសៀវភៅលើប្រធានបទស្ដីពី "នីតិកាតព្វកិច្ច" បោះពុម្ពឆ្នាំ២០១៣
- ឈិន ដារិត, រៀបរៀងសៀវភៅសង្ខេបមេរៀនស្ដីពី "កិច្ចសន្យាពិសេស"
- អ៊ីវ ប៉ូលី រៀបរៀងសៀវភៅលើប្រធានបទស្ដីពី "កិច្ចសន្យា" ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

- **សារណាបញ្ចប់ការសិក្សា**

- ប៊ិន ពុទ្ធិតា និងណុន លក្ស្មី, សៀវភៅសារណាបញ្ចប់ការសិក្សា ប្រធានបទស្ដីពី "អត្ថន័យនៃកិច្ចសន្យា" ឆ្នាំ២០១៨
- ថេង មួយឡេង និងអ៊ន់ ផាន់ណូ សៀវភៅសារណាបញ្ចប់ការសិក្សា ប្រធានបទស្ដីពី "សុពលភាពនៃកិច្ចសន្យា" ,ឆ្នាំ២០០៩
- វង្ស ស្រីដែន សៀវភៅសារណាបញ្ចប់ការសិក្សា ប្រធានបទស្ដីពី "ភតិសន្យាអចលនវត្ថុនៅកម្ពុជា" ,ឆ្នាំ២០១៣

ទារចំនួនទឹកប្រាក់ ជាកម្រៃដែលសមរម្យ ពីអ្នកផ្ញើបាន ។

**មាត្រា ៦៩៦.–** ការសងវត្ថុដែលជាកម្មវត្ថុនៃវិវាទ

វិសុណ្ឋាបនិកមានករណីយកិច្ចត្រូវសងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថា មានសិទ្ធិ នៅក្រោយពេលដែលវិវាទបានបញ្ចប់ ។

**មាត្រា ៦៩៧.–** ការរំលាយកិច្ចសន្យាវិសុណ្ឋាប័ន

វិសុណ្ឋាបនិកពុំអាចសងវត្ថុនោះ ទៅឱ្យអ្នកផ្ញើ នៅមុនពេលវិវាទនោះត្រូវបានដោះស្រាយឡើយ លើកលែងតែករណីមានការយល់ព្រមពីអ្នកផ្ញើទាំងអស់ ។

**មាត្រា ៦៩៨.–** វិសុណ្ឋាប័ន ដោយការបង្គាប់របស់តុលាការ

ក្នុងករណីដែលសិទ្ធិកាន់កាប់វត្ថុ ឬ កម្មសិទ្ធិនៃវត្ថុ ត្រូវបានយកជាកម្មវត្ថុនៃវិវាទនៅក្នុងតុលាការ ទោះបីជាគ្មានការព្រមព្រៀងរវាងភាគីក៏ដោយ តុលាការអាចឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ។

## ជំពូកទី ១១
## កិច្ចសន្យាក្រុមហ៊ុន

**មាត្រា ៦៩៩.–** និយមន័យនៃកិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុន សំដៅទៅលើកិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការ ដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន ។

**មាត្រា ៧០០.–** ការបង្កើតកិច្ចសន្យាក្រុមហ៊ុន

១-ក្រុមហ៊ុន គឺជាក្រុមដែលបានបង្កើតដោយការសន្យា ដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា ។

២-ទ្រព្យធនដែលភាគីនីមួយៗត្រូវវិនិយោគ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ក្រៅពីសិទ្ធិលើទ្រព្យសម្បត្តិ អាចយកពលកម្ម មកធ្វើជាកម្មវត្ថុបាន ។

៣-ក្នុងករណីដែលភាគីបានយកប្រាក់ធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន បើមានការយឺតយ៉ាវក្នុងការបង់ប្រាក់នោះ ក្រៅពីត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ក៏ត្រូវបង់ទៅលើការខូចខាតដែលកើតឡើងដោយសារការយឺតយ៉ាវនោះ ចំពោះក្រុមហ៊ុនផងដែរ ។

៤-ក្នុងករណីដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយ ក្នុងចំណោមភាគីដែលបានព្រមព្រៀងបង្កើតក្រុមហ៊ុន ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោល ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) ជំពូកទី ២ នៃគន្ថីទី ៤ ត្រូវចាត់ទុកថា ក្រុមហ៊ុននោះ ត្រូវបានបង្កើត ដោយភាគីដទៃទៀត ។ ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនពុំអាចសម្រេចគោលបំណងបាន ដោយសារកង្វះភាគីនោះ ត្រូវចាត់ទុកថាក្រុមហ៊ុននោះ ពុំត្រូវបានបង្កើតឡើយ ។

**មាត្រា ៧០១.–** កម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន

១-ទ្រព្យធនវិនិយោគរបស់សមាជិកក្រុមហ៊ុននីមួយៗ និង ទ្រព្យសម្បត្តិក្រុមហ៊ុនផ្សេងៗទៀត ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ។

២-សមាជិកក្រុមហ៊ុន ពុំអាចទាមទារឱ្យបែងចែកទ្រព្យសម្បត្តិក្រុមហ៊ុន នៅមុនពេលធ្វើការជម្រះបញ្ជីរបស់ក្រុមហ៊ុន បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន មានការព្រមព្រៀង ទោះបីជានៅមុនពេលធ្វើការជម្រះបញ្ជីក៏ដោយ ក៏អាចទាមទារឱ្យបែងចែកបានដែរ ។

៣-ការបែងចែកដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ខាងលើនេះ ពុំអាចយកមកតតាំងចំពោះតតិយជន ដែលបានធ្វើជំនួញជាមួយនឹងក្រុមហ៊ុន នៅមុនពេលធ្វើការបែងចែកនោះបានឡើយ ។

៤-សមាជិកក្រុមហ៊ុន ពុំអាចចាត់ចែងភាគដែលខ្លួនមាន ចំពោះទ្រព្យសម្បត្តិក្រុមហ៊ុននោះ បានឡើយ ។

**មាត្រា ៧០២.–** វិធីអនុវត្តកិច្ចការ

១-ក្នុងករណីដែលពុំបានកំណត់សមាជិកក្រុមហ៊ុន ឬ តតិយជនទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ សមាជិកនីមួយៗនៃក្រុមហ៊ុន មានសិទ្ធិ

អំណាចអនុវត្តកិច្ចការរបស់ក្រុមហ៊ុននោះ ។ ប៉ុន្តែ ការអនុវត្តកិច្ចការក្រុមហ៊ុន ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

២-ប្រសិនបើបានកំណត់ថាសមាជិកក្រុមហ៊ុន ឬ តតិយជនដែលទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវមានច្រើននាក់ ការអនុវត្តកិច្ចការក្រុមហ៊ុនត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

៣-ទោះបីមានបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះក៏ដោយ សមាជិកក្រុមហ៊ុននីមួយៗ ឬ អ្នកអនុវត្តកិច្ចការម្នាក់ៗ អាចអនុវត្តកិច្ចការប្រក្រតីរបស់ក្រុមហ៊ុនដោយឯកតោភាគីបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើសមាជិកនៃក្រុមហ៊ុន ឬ អ្នកអនុវត្តកិច្ចការផ្សេងទៀត បានបញ្ចេញមតិតវ៉ា នៅមុនពេលបញ្ចប់កិច្ចការនោះ ។

**មាត្រា ៧០៣.-** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ។

**មាត្រា ៧០៤.-** ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ

១-ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ ពុំអាចលាឈប់ ឬ ត្រូវបញ្ឈប់បានឡើយ ។

២-ដើម្បីបញ្ឈប់សមាជិកដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ដោយមានមូលហេតុត្រឹមត្រូវ ត្រូវមានសម្លេងយល់ព្រម លើសពីពាក់កណ្តាលនៃចំនួនសមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ។

**មាត្រា ៧០៥.-** សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិ

ទោះបីជាគ្មានសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុនក៏ដោយ ក៏សមាជិក

នីមួយៗរបស់ក្រុមហ៊ុន អាចធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះបានដែរ ។

**មាត្រា ៧០៦.-** សិទ្ធិទាមទារចែកចំណេញ ភាគនៃការបែងចែកការចំណេញ ខាត

១-សមាជិកក្រុមហ៊ុន ត្រូវគណនាការចំណេញ ខាត នៅក្នុងអំឡុងពេលទៀងទាត់ ហើយក្នុងករណីដែលមានចំណេញ អាចទាមទារឱ្យបែងចែកផលចំណេញនោះបាន ។

២-ប្រសិនបើសមាជិកក្រុមហ៊ុន មិនបានកំណត់ភាគនៃការបែងចែកការចំណេញ ខាតទេ ត្រូវកំណត់ទៅតាមសមាមាត្រនៃចំនួនតម្លៃវិនិយោគទ្រព្យធនរបស់សមាជិកនីមួយៗនៃក្រុមហ៊ុននោះ ។

៣-ប្រសិនបើបានកំណត់តែភាគនៃការបែងចែកចំពោះការចំណេញ ខាតណាមួយ ត្រូវសន្មតថាភាគនោះ ដូចគ្នាទៅនឹងការខាតបង់ និង ការចំណេញ ។

**មាត្រា ៧០៧.-** ភាគដែលត្រូវទទួលបន្ទុកនៃការខាតបង់របស់សមាជិកក្រុមហ៊ុន ចំពោះម្ចាស់បំណុល

១-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចការរបស់ក្រុមហ៊ុន ជាកាតព្វកិច្ចដោយសាមគ្គីភាព ។ ប៉ុន្តែ កាតព្វកិច្ចនោះ ត្រូវសងដោយទ្រព្យសម្បត្តិក្រុមហ៊ុនសិន ហើយប្រសិនបើមិនអាចសងកាតព្វកិច្ចទាំងអស់ ដោយទ្រព្យសម្បត្តិក្រុមហ៊ុន ទើបសងដោយទ្រព្យដោយឡែករបស់សមាជិកនីមួយៗ ។

២-បន្ទុករបស់សមាជិកនីមួយៗ ត្រូវអនុលោមតាមសមាមាត្រនៃភាគវិនិយោគ លើកលែងតែមានការសន្យាពិសេស ។

**មាត្រា ៧០៨.-** ការហាមឃាត់មិនឱ្យទូទាត់កាតព្វកិច្ចក្រុមហ៊ុន

កូនបំណុលរបស់ក្រុមហ៊ុន ពុំអាចទូទាត់កាតព្វកិច្ចនោះ ជាមួយនឹងសិទ្ធិលើបំណុលចំពោះសមាជិកនីមួយៗនៃក្រុមហ៊ុន បានឡើយ ។

**មាត្រា ៧០៩.-** ការដកខ្លួនដោយស្ម័គ្រចិត្ត

១-ប្រសិនបើពុំបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុននៅក្នុងកិច្ចសន្យា

ក្រុមហ៊ុនទេ ឬ បើបានកំណត់អត្ថិភាពដែលក្រុមហ៊ុនត្រូវមាន ក្នុងរយៈពេលមួយជីវិតរបស់សមាជិកណាម្នាក់ សមាជិកនីមួយៗ អាចដកខ្លួនចេញ នៅពេលណាក៏បាន ។ ប៉ុន្តែការដកខ្លួននេះ ពុំអាចធ្វើបានឡើយ បើបណ្តាលឱ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន លើកលែងតែក្នុងករណីដែលពុំអាចជៀសវាងបាន ។

២-ទោះបីជាបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុនក៏ដោយ នៅក្នុងករណីដែលពុំអាចជៀសវាងបាន សមាជិកនីមួយៗ អាចដកខ្លួនបាន ។

៣-ការដកខ្លួនអាចធ្វើទៅបាន ដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន ។

**មាត្រា ៧១០.-** ការដកខ្លួនតាមច្បាប់

ក្រៅពីបញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា ៧០៩ (ការដកខ្លួនដោយស្ម័គ្រចិត្ត) ខាងលើ សមាជិកក្រុមហ៊ុន ត្រូវដកខ្លួន ដោយមូលហេតុណាមួយ ដូចខាងក្រោមនេះ :

ក-មរណភាព ។

ខ-ធនក្ស័យ ។

គ-បានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ។

ឃ-ការលុបឈ្មោះ ។

**មាត្រា ៧១១.-** ការលុបឈ្មោះ

ការលុបឈ្មោះសមាជិកក្រុមហ៊ុន អាចអនុវត្តបាន ដោយមតិយល់ព្រមជាឯកច្ឆន្ទពីសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន តែក្នុងករណីដែលមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ ។ ប៉ុន្តែ បើមិនបានជូនដំណឹងពីការលុបឈ្មោះ ដល់សមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះទេ ពុំអាចយកទៅតតាំងជាមួយនឹងសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះនោះ បានឡើយ ។

**មាត្រា ៧១២.-** ការសងវិញ នូវចំណែករបស់សមាជិកក្រុមហ៊ុន ដែលដកខ្លួន

១-ការគណនារវាងសមាជិកក្រុមហ៊ុនដែលបានដកខ្លួន និង សមាជិកផ្សេងទៀត

របស់ក្រុមហ៊ុន ចាំបាច់ត្រូវអនុវត្ត ដោយផ្អែកតាមស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន នៅពេលដែលដកខ្លួននោះ ។

២-ចំណែកដែលសមាជិកក្រុមហ៊ុនដែលបានដកខ្លួននោះមាន អាចសងវិញជាប្រាក់បាន ដោយពុំគិតពីប្រភេទនៃទ្រព្យធនដែលវិនិយោគនោះឡើយ ។

៣-ចំពោះចំណុចដែលពុំទាន់បានបញ្ចប់ នៅពេលដកខ្លួន អាចគណនាបាន នៅក្រោយពេលធ្វើការបញ្ចប់នោះ ។

៤-ការសងចំណែកដែលមាន ទៅសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះ ត្រូវភ្ជាប់ការប្រាក់ តាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ចំពោះអំឡុងពេលគិតចាប់ពីពេលដែលបានជូនដំណឹងអំពីការលុបឈ្មោះ រហូតដល់ពេលដែលបានសងវិញ ។

**មាត្រា ៧១៣.–** ការរំលាយក្រុមហ៊ុន

១-ក្រុមហ៊ុន ត្រូវរំលាយតាមករណីណាមួយ ដូចកំណត់ខាងក្រោមនេះ :

ក-ការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុន ឬ អលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ។

ខ-បើមានការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន ។

គ-បើនៅសល់សមាជិកក្រុមហ៊ុន តែម្នាក់ ។

ឃ-បើអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវបានបញ្ចប់ ។

២-ក្នុងករណីដែលមានមូលហេតុមិនអាចជៀសវាងបាន សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចទាមទារឱ្យរំលាយក្រុមហ៊ុនបាន ។

៣-ការទាមទារនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់ របស់ក្រុមហ៊ុន ។

**មាត្រា ៧១៤.–** ភាពគ្មានប្រតិសកម្មនៃការរំលាយ

ការរំលាយក្រុមហ៊ុន ពុំមានអានុភាពប្រតិសកម្មឡើយ ។

**មាត្រា ៧១៥.-** អ្នកជម្រះបញ្ជី

១-ប្រសិនបើក្រុមហ៊ុនត្រូវបានរំលាយ ការជម្រះបញ្ជីត្រូវធ្វើ ដោយសហការគ្នារវាងសមាជិកទាំងអស់របស់ក្រុមហ៊ុន ឬ ដោយអ្នកជម្រះបញ្ជី ដែលត្រូវបានជ្រើសតាំងដោយសមាជិកក្រុមហ៊ុន ។

២-ការជ្រើសតាំងអ្នកជម្រះបញ្ជីនៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលគ្មានកំណត់ពិសេសនៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមហ៊ុននោះ ។

**មាត្រា ៧១៦.-** ការអនុវត្តកិច្ចការរបស់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០២ (វិធីអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលអ្នកជម្រះបញ្ជី មានចំនួនច្រើននាក់ ។

**មាត្រា ៧១៧.-** ការលាឈប់ និង ការបញ្ឈប់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០៤ (ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន បានព្រមព្រៀងជ្រើសតាំងអ្នកជម្រះបញ្ជី ពីក្នុងចំណោមសមាជិកក្រុមហ៊ុននោះ ។

**មាត្រា ៧១៨.-** មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី វិធីបែងចែកទ្រព្យសម្បត្តិដែលនៅសេសសល់

១-បញ្ញត្តិនៃមាត្រា ៧១ (មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទី និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី ។

២-ទ្រព្យសម្បត្តិដែលនៅសេសសល់ ត្រូវបែងចែកដោយសមាមាត្រតាមតម្លៃនៃទ្រព្យធនដែលសមាជិកនីមួយៗរបស់ក្រុមហ៊ុន បានវិនិយោគ ។

អំណាច ដែលឲ្យ នោះ ត្រូវ រលាយ ។

មាត្រា ១២៨៦.- អ្នក, ដែលកាន់កាប់ គ្មាន សិទ្ធិប្រទាន នូវ ការងារ របស់ជនដទៃ ដើម្បីកុំឲ្យ គេ មាន ព្យសនកម្ម, ត្រូវមាន ភាតព្វកិច្ច ដូចខ្លួន ជាអ្នកតំណាង ដែរ; សិទ្ធិ នៃអ្នក ដែលធ្វើការជួស ជន ដទៃ នេះ ត្រូវគិត ដូចមាន ចែង ក្នុងមាត្រា៨២៥·៨២៦នោះ ។

## ចំពូក ទី ១១
## អំពី ក្រុមហ៊ុន

មាត្រា ១២៨៧.- ដែល ហៅថា ក្រុមហ៊ុន នោះ គឺ កិច្ចសន្យា ដែលមនុស្ស ទាំងឡាយ ព្រមព្រៀង គ្នា យក ធនធាន របស់ខ្លួន ទៅ ដាក់ រួមគ្នា ក្នុងគោលបំណង ណាមួយ ដើម្បីនឹងចែក ចំណេញ ឬ ចែក ខាត គ្នា ដែលអាច កើតឡើង ពីការ នេះ ។

កិច្ចសន្យា ក្រុមហ៊ុន ត្រូវធ្វើ លិខិត ជាលាយល័ក្សអក្សរ មាន សេចក្តី បញ្ជាក់ ផង បើ កិច្ចសន្យា នោះ ប្តេជ្ញា អំពីអចលវត្ថុ ។

មាត្រា ១២៨៨.- ឯ ប្តី ប្រពន្ធ នឹងចូល ហ៊ុនគ្នា ពុំបាន ឡើយ ។

មាត្រា ១២៨៩.- ចំណែក ហ៊ុន នោះ ស្មើគ្នា ក៏បាន, មិនស្មើ គ្នា ក៏បាន ។

មាត្រា ១២៩០.- សមាជិក ទាំងឡាយ ពោល យក ទុន មក រួម

ក៏បាន, យក ប្រាជ្ញា, សកម្មភាព, ចំណេះ ឬ ការពិសោធ មកដាក់ ក្នុង មូលនិធិ រួម ក៏បាន ។

មាត្រា ១២៩១.- មូលនិធិ រួម របស់ ក្រុមហ៊ុន គឺ ជាដើមទុន នៃក្រុមហ៊ុន, ដើមទុន នោះ ជារបស់ សមាជិក ទាំងអស់គ្នា ។

អ្វី ដែលសមាជិក ម្នាក់ ៗ មាន ក្រៅ ពីវត្ថុ ដែលយក ទៅចូល ក្នុង ក្រុមហ៊ុន នោះ មិនមែន ជារបស់ ក្រុមហ៊ុន ឡើយ គឺ ជារបស់ កម្មសិទ្ធិ ផ្ទាល់ ខ្លួន ម្នាក់ ៗ ។

មាត្រា ១២៩២-. សមាជិក ម្នាក់ ៗ ត្រូវបាន ចំណេញ តាម សមាមាត្រ នៃហ៊ុន ដែលខ្លួន យកមក ចូល ។ កិច្ចសន្យា ត្រូវ ចែង ឲ្យ ច្បាស់ ពីតម្លៃ នៃហ៊ុន របស់សមាជិក ដែលពុំ បានចេញ ប្រាក់ដើម, ពុំ បានចេញ ទ្រព្យ ជាសម្ភារៈ នោះ ។

បើ កិច្ចសន្យា គ្មាន ចែង អំពីរ នេះ ទេ , ហ៊ុន ដែលយក មកចូល នោះ ត្រូវទុក ជា ស្មើ ភាគ គ្នា ទាំងអស់ ។

មាត្រា ១២៩៣ .- សមាជិក ណា ក៏ដោយ មិនអាច បន្ថែម សមាជិក ផងគ្នា ឲ្យបញ្ចូលគតិយជន ក្នុងក្រុមហ៊ុន បាន ទេ; បើ សមាជិក ទាំងអស់ ព្រម ទាំងអស់គ្នា ជាឯកច្ឆ័ន្ទ, ទើប អ្នក ថ្មី អាច ចូលបាន ។

មាត្រា ១២៩៤.— ភារកិច្ច នៃសមាជិក ទាំងឡាយ ត្រូវតែ ចែង ក្នុងកិច្ចសន្យា ឲ្យច្បាស់ លាស់ ។

វិវាទថា អ្នកណាជាអ្នកមានសិទ្ធិចំពោះវត្ថុនោះ វិសុណ្ណាប័នមិនអាចសងវត្ថុទេ លើកលែងតែអ្នកផ្ញើទាំងអស់យល់ព្រម ។
(មាត្រាពាក់ព័ន្ធ)

មាត្រា ២៣០៩ នៃក្រមរដ្ឋប្បវេណី

**មាត្រា ៦៩៨.-** វិសុណ្ណាប័ន ដោយការបង្គាប់របស់តុលាការ

ក្នុងករណីដែលសិទ្ធិកាន់កាប់វត្ថុ ឬ កម្មសិទ្ធិនៃវត្ថុ ត្រូវបានយកជាកម្មវត្ថុនៃវិវាទនៅក្នុងតុលាការ ទោះបីជាគ្មានការព្រមព្រៀងរវាងភាគីក៏ដោយ តុលាការអាចឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ។

(កំណត់)

ក្នុងដំណើរការនៃបណ្តឹង តុលាការអាចគិតថា វាសមរម្យក្នុងការផ្ទុកផ្តាក់ឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទ ។ ឧទាហរណ៍ តុលាការអាចគិតដូច្នេះ ក្នុងករណីដែលអ្នកលក់កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ប៉ុន្តែ ដោយសារភាគីទាំងពីរនៃវិវាទដោយអះអាងម្នាក់ៗថា ខ្លួនជាអ្នកទិញពិតប្រាកដ មិនយល់ព្រមចំពោះវិសុណ្ណាប័ន អ្នកលក់មិនអាចធ្វើវិសុណ្ណាប័នដោយការព្រមព្រៀងបានឡើយ ។ ប្រសិនបើច្បាប់ស្តីពីការតម្កល់គ្របដណ្តប់លើករណីបែបនេះ បញ្ហានេះអាចត្រូវបានដោះស្រាយបាន តាមការតម្កល់ ។ ប៉ុន្តែ ប្រសិនបើច្បាប់ស្តីពីការតម្កល់មិនអនុញ្ញាតឱ្យតម្កល់នូវចលនវត្ថុ និងអចលនវត្ថុទេ បញ្ហានេះមិនអាចត្រូវបានដោះស្រាយដោយការតម្កល់បានឡើយ ។ ក្នុងករណីនេះ វាជាការងាយស្រួលប្រសិនបើវិសុណ្ណាប័ន អាចត្រូវបានធ្វើដោយការបង្គាប់របស់តុលាការបាន ។
(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៦៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, ២៣១១ នៃក្រមរដ្ឋប្បវេណីគេបិច

## ជំពូកទី ១១ កិច្ចសន្យាក្រុមហ៊ុន

**មាត្រា ៦៩៩.-** និយមន័យនៃកិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុន សំដៅទៅលើកិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការ ដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន ។

(កំណត់)

មាត្រានេះចែងថា អាចបង្កើតក្រុមហ៊ុនដោយកិច្ចសន្យាក្រុមហ៊ុន ព្រមទាំងបានឱ្យនិយមន័យនៃកិច្ចសន្យាក្រុមហ៊ុន ។

នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ចាំបាច់ត្រូវមានវិនិយោគទ្រព្យធនរៀងៗខ្លួន និង កិច្ចព្រមព្រៀងអំពីកិច្ចការដែលត្រូវបានធ្វើដោយសហការគ្នា ។ មាត្រានេះបានចែងច្បាស់លាស់ថា លក្ខណៈពិសេសរបស់ក្រុមហ៊ុនគឺជាក្រុមដែលពុំមានលក្ខណៈជានីតិបុគ្គល ។ ក្រុមដែលមានខ្លឹមសារជាសារធាតុដូចក្រុមហ៊ុនដែរ គឺ នីតិបុគ្គលសាជីវកម្មដែលមានការទទួលខុសត្រូវគ្មានកម្រិត ក៏ប៉ុន្តែ ក្រុមនេះអាចមានលក្ខណៈជានីតិបុគ្គល ។ សូមមើល កថាខណ្ឌទី ៣ នៃមាត្រា ៤៦ និង បញ្ញត្តិចាប់ពីមាត្រា ១០១ ដល់ មាត្រា ១០៩ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៨៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៦៦៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧០៥ និង មាត្រា ៧០៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៣២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣០ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០០.-** ការបង្កើតកិច្ចសន្យាក្រុមហ៊ុន

១-ក្រុមហ៊ុន គឺជាក្រុមដែលបានបង្កើតដោយការសន្យា ដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា ។

២-ទ្រព្យធនដែលភាគីនីមួយៗត្រូវវិនិយោគ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ក្រៅពីសិទ្ធិលើទ្រព្យសម្បត្តិ អាចយកពលកម្ម មកធ្វើជាកម្មវត្ថុបាន ។

៣-ក្នុងករណីដែលភាគីបានយកប្រាក់ធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន បើមានការយឺតយ៉ាវក្នុងការបង់ប្រាក់នោះ ក្រៅពីត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ក៏ត្រូវបង់ទៅលើការខូចខាតដែលកើតឡើងដោយសារការយឺតយ៉ាវនោះ ចំពោះក្រុមហ៊ុនផងដែរ ។

៤-ក្នុងករណីដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយ ក្នុងចំណោមភាគីដែលបានព្រមព្រៀងបង្កើតក្រុមហ៊ុន ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោល ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) ជំពូកទី ២ នៃគន្ថីទី ៤ ត្រូវចាត់ទុកថា ក្រុមហ៊ុននោះ ត្រូវបានបង្កើត ដោយភាគីដទៃទៀត ។ ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនពុំអាចសម្រេចគោលបំណងបាន ដោយសារកង្វះភាគីនោះ ត្រូវចាត់ទុកថាក្រុមហ៊ុននោះ ពុំត្រូវបានបង្កើតឡើយ ។

(កំណត់)

(1) កថាខណ្ឌទី ១ នៃមាត្រានេះ កំណត់និយមន័យនៃក្រុមដែលហៅថាជាក្រុមហ៊ុន ។ ម្យ៉ាងទៀត កិច្ចសន្យាក្រុមហ៊ុន

គឺជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀង ក៏ប៉ុន្តែ ចំណុចដែលត្រូវប្រយ័ត្ន គឺ បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៦ ត្រូវយកមកអនុវត្ត ចំពោះករណីដែលយកកម្មសិទ្ធិលើអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន ។

(2) កថាខណ្ឌទី ២ ចែងអំពីខ្លឹមសារនៃការវិនិយោគទ្រព្យធន ។ ក្រៅពីសិទ្ធិលើទ្រព្យសម្បត្តិ ពលកម្មក៏អាចក្លាយទៅជាកម្មវត្ថុនៃការវិនិយោគទ្រព្យធនដែរ ។

(3) កថាខណ្ឌទី ៣ ជាបញ្ញត្តិស្ដីពីការទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការបង់ប្រាក់តាមពេលកំណត់ ក្នុងករណីដែលកម្មវត្ថុនៃការវិនិយោគទ្រព្យធនជាប្រាក់ ។

(4) កថាខណ្ឌទី ៤ ចែងអំពីលទ្ធផលចំពោះក្រុមហ៊ុន ក្នុងករណីដែលសកម្មភាពនៃការបង្កើតរបស់អ្នកវិនិយោគខ្លះ ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោល ។ ដោយពិនិត្យមើលទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ព្រមទាំងការគោរពនូវឆន្ទៈភាគី គួរតែទទួលស្គាល់នូវអត្ថិភាពនៃក្រុមហ៊ុន តាមការដែលអាចធ្វើទៅបាន ហេតុនេះហើយបានជាបញ្ញត្តិនេះទទួលស្គាល់នូវការបង្កើតក្រុមហ៊ុនដោយបុគ្គលដែលជាភាគីដទៃ ទោះបីជាសកម្មភាពនៃការបង្កើតរបស់បុគ្គលណាម្នាក់ ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោលក៏ដោយ ។ ប៉ុន្តែ ប្រសិនបើគោលបំណងនៃក្រុមហ៊ុនមិនអាចសម្រេចបានដោយសារកង្វះបុគ្គលនោះ ការទទួលស្គាល់នូវអត្ថិភាពនៃក្រុមហ៊ុននោះនឹងបាត់បង់នូវអត្ថន័យ ហេតុនេះហើយ ក្នុងករណីនេះ ត្រូវចាត់ទុកថា ក្រុមហ៊ុននោះមិនត្រូវបានបង្កើតឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៤៦ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧០១**.- កម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន

១-ទ្រព្យធនវិនិយោគរបស់សមាជិកក្រុមហ៊ុននីមួយៗ និង ទ្រព្យសម្បត្តិក្រុមហ៊ុនផ្សេងៗទៀត ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ។

២-សមាជិកក្រុមហ៊ុន ពុំអាចទាមទារឱ្យបែងចែកទ្រព្យសម្បត្តិក្រុមហ៊ុន នៅមុនពេលធ្វើការជម្រះបញ្ជីរបស់ក្រុមហ៊ុន បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន មានការព្រមព្រៀង ទោះបីជានៅមុនពេលធ្វើការជម្រះបញ្ជីក៏ដោយ ក៏អាចទាមទារឱ្យបែងចែកបានដែរ ។

៣-ការបែងចែកដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ខាងលើនេះ ពុំអាចយកមកតតាំងចំពោះតតិយជន ដែលបានធ្វើជំនួញជាមួយនឹងក្រុមហ៊ុន នៅមុនពេលធ្វើការបែងចែកនោះបានឡើយ ។

៤-សមាជិកក្រុមហ៊ុន ពុំអាចចាត់ចែងភាគដែលខ្លួនមាន ចំពោះទ្រព្យសម្បត្តិក្រុមហ៊ុននោះ បានឡើយ ។

(កំណត់)

(1) តាមធម្មតា ក្រុមហ៊ុនមានទ្រព្យសម្បត្តិផ្សេងៗ ដើម្បីសម្រេចនូវគោលដៅនៃកិច្ចការរបស់ខ្លួន ។ ទ្រព្យសម្បត្តិនេះត្រូវបានប្រើប្រាស់ និង គ្រប់គ្រង ដើម្បីសម្រេចនូវគោលបំណងនៃក្រុមហ៊ុន ហើយជាគ្រឹះនៃទំនុកចិត្តរបស់ក្រុមហ៊ុនដែលជាអង្គភាព (ដូចជាភាគី) នៃការជួញដូរ ។ ដូច្នេះហើយ ទោះបីជាក្រុមហ៊ុនមិនមែនជានីតិបុគ្គលក៏ដោយ ក៏ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន គួរតែគិតផ្សេងដោយឡែកពីទ្រព្យសម្បត្តិរបស់សមាជិកម្នាក់ៗនៃក្រុមហ៊ុននោះ ។ មាត្រានេះចែងច្បាស់លាស់អំពីបញ្ហានេះ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនមិនមែនជានីតិបុគ្គលទេ ដូច្នេះហើយ ក្រុមហ៊ុនមិនអាចចុះបញ្ជីជាកម្មសិទ្ធិករអចលនវត្ថុក្នុងនាមខ្លួនបានឡើយ ។ ការចុះបញ្ជីអចលនវត្ថុរបស់ក្រុមហ៊ុនជាគោលការណ៍ ត្រូវធ្វើឡើងក្នុងរូបភាពជាកម្មសិទ្ធិអវិភាគរបស់សមាជិកទាំងអស់ ។ ប៉ុន្តែ បើធ្វើដូច្នេះ នឹងមានភាពស្មុគស្មាញចំពោះនីតិវិធី ។ មានករណីខ្លះដែលសមាជិកដែលអនុវត្តកិច្ចការម្នាក់ ក្នុងចំណោមសមាជិកក្រុមហ៊ុនឈរឈ្មោះចុះបញ្ជី ក្នុងនាមឯកជន ប៉ុន្តែ ភាគច្រើនអាចក្លាយទៅជាវិវាទ ។

(2) មាត្រានេះ កម្រិតអំពីការទាមទារឱ្យបែងចែកមុនការជម្រះបញ្ជី និង អំពីការចាត់ចែងភាគដែលខ្លួនមាន ហើយបញ្ជាក់អំពីខ្លឹមសារនៃការកម្រិតនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧១៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, កថាខណ្ឌទី ១ មាត្រា ៥៤៤ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០២.-** វិធីអនុវត្តកិច្ចការ

១-ក្នុងករណីដែលពុំបានកំណត់សមាជិកក្រុមហ៊ុន ឬ តតិយជនទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ សមាជិកនីមួយៗនៃក្រុមហ៊ុន មានសិទ្ធិអំណាចអនុវត្តកិច្ចការរបស់ក្រុមហ៊ុននោះ ។ ប៉ុន្តែ ការអនុវត្តកិច្ចការក្រុមហ៊ុន ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

២-ប្រសិនបើបានកំណត់ថាសមាជិកក្រុមហ៊ុន ឬ តតិយជនដែលទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវមានច្រើននាក់ ការអនុវត្តកិច្ចការក្រុមហ៊ុនត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

៣-ទោះបីមានបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះក៏ដោយ សមាជិកក្រុមហ៊ុននីមួយៗ ឬ អ្នកអនុវត្តកិច្ចការម្នាក់ៗ អាចអនុវត្តកិច្ចការប្រក្រតីរបស់ក្រុមហ៊ុនដោយឯកតោភាគីបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើសមាជិកនៃក្រុមហ៊ុន ឬ អ្នកអនុវត្តកិច្ចការផ្សេងទៀត បានបញ្ចេញមតិតវ៉ា នៅមុនពេលបញ្ចប់កិច្ចការនោះ ។

(កំណត់)

(1) ជាទូទៅ ក្រុមហ៊ុនភាគច្រើនដែលមានសមាជិកតិច មិនបានកំណត់អ្នកអនុវត្តកិច្ចការរបស់ក្រុមហ៊ុនទេ ។ ហេតុដូច្នេះ ក្នុងករណីដែលពុំមានការកំណត់នេះទេ ត្រូវចាត់ទុកថា សមាជិកម្នាក់ៗមានសិទ្ធិអនុវត្តកិច្ចការ (វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១) ហើយការអនុវត្តកិច្ចការជាក់ស្តែងត្រូវធ្វើតាមសម្លេងលើសពាក់កណ្តាល (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។ម្យ៉ាងទៀត ចំណុចដែលត្រូវប្រយ័ត្ន គឺ បញ្ហានៃសិទ្ធិអនុវត្តកិច្ចការជាបញ្ហាផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ រីឯបញ្ហាទំនាក់ទំនងខាងក្រៅស្តីពីសិទ្ធិតំណាងវិញ ត្រូវដោះស្រាយតាមបញ្ញត្តិស្តីពីការតំណាង (ការតំណាងក្រុមហ៊ុន) ទៅវិញ ។

(2) ម្យ៉ាងទៀត ចំពោះកិច្ចការស្រាលៗដែលក្រុមហ៊ុនត្រូវអនុវត្តដដែលៗរៀងរាល់ថ្ងៃវិញ មានន័យថាជាកិច្ចការប្រក្រតី ប្រសិនបើសមាជិកក្រុមហ៊ុនម្នាក់ៗអាចបំពេញរៀង១ខ្លួន នេះជាការល្អសម្រាប់ក្រុមហ៊ុន ហើយពុំមានអ្វីជាឧបសគ្គដល់ក្រុមហ៊ុនផង ។ ដូច្នេះហើយ កថាខណ្ឌទី ៣ បានចែងច្បាស់លាស់អំពីចំណុចនេះ ។ ក៏ប៉ុន្តែ ទោះបីជាកិច្ចការប្រក្រតីក៏ដោយ ក្នុងករណីដែលកិច្ចការនោះត្រូវបានអនុវត្តរៀង១ខ្លួន អាចមានឧបសគ្គដោយសារការវិនិច្ឆ័យរបស់សមាជិករៀង១ខ្លួននោះ ដូច្នេះហើយ ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ទទួលស្គាល់អំពីការតវ៉ាពីសមាជិកផ្សេងទៀត មុនពេលបញ្ចប់កិច្ចការនោះ ។ ទោះបីជាមានការតវ៉ាពីសមាជិកផ្សេងទៀតក៏ដោយ ប្រសិនបើសមាជិកនោះនៅតែបន្តការអនុវត្តកិច្ចការដូចគ្នាដដែល នោះសកម្មភាពរបស់សមាជិកដែលបានអនុវត្តកិច្ចការនេះក្លាយជាអំពើខុសច្បាប់ ហើយសមាជិកនេះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតចំពោះមុខសមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ។

(3) ក្រុមហ៊ុនពុំអាចយកឈ្មោះក្រុមហ៊ុនធ្វើជាដើមចោទបានឡើយ ដូច្នេះត្រូវជ្រើសរើសសមាជិកដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ជាដើម ជាភាគីដែលត្រូវបានជ្រើសរើស ឬ សមាជិកទាំងអស់ត្រូវដាក់ពាក្យបណ្តឹងក្នុងនាមជាសហដើមចោទ ។ ម្យ៉ាងទៀត ក្រុមហ៊ុនមិនអាចត្រូវបានប្តឹងជាចុងចម្លើយបានឡើយ ដូច្នេះហើយ បុគ្គលដែលមានបំណងប្តឹងក្រុមហ៊ុនត្រូវប្តឹងសមាជិកទាំងអស់ ក្នុងនាមជាសហចុងចម្លើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧០៩ និង មាត្រា ៧១០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៥៩ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣៥ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០៣.-** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ។

(កំណត់)

ទំនាក់ទំនងគតិយុត្តរវាងអ្នកអនុវត្តកិច្ចការ និង ក្រុមហ៊ុន គឺជាកិច្ចសន្យាអាណត្តិ ឬ ប្រហាក់ប្រហែលនឹងកិច្ចសន្យាអាណត្តិដែរ ហេតុនេះហើយបញ្ញត្តិស្តីពីអាណត្តិ (ចាប់ពីមាត្រា ៦៤០ ដល់មាត្រា ៦៤៦) ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះទំនាក់ទំនងគតិយុត្តនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧០៨ និង មាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៣៨ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០៤.-** ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ

១-ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ ពុំអាចលាឈប់ ឬ ត្រូវបញ្ឈប់បានឡើយ ។

២-ដើម្បីបញ្ឈប់សមាជិកដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ដោយមានមូលហេតុត្រឹមត្រូវ ត្រូវមានសម្លេងយល់ព្រម លើសពីពាក់កណ្តាលនៃចំនួនសមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ។

(កំណត់)

(1) ក្នុងករណីដែលអ្នកអនុវត្តកិច្ចការដែលមិនមែនជាសមាជិកក្រុមហ៊ុន ត្រូវបានជ្រើសតាំងដោយកិច្ចសន្យាអាណត្តិ អ្នកអនុវត្តកិច្ចការនេះ អាចត្រូវបានបញ្ឈប់ នៅពេលណាក៏បានដែរ ក្រោមកិច្ចសន្យាអាណត្តិ (កថាខណ្ឌទី ១ នៃមាត្រា ៦៤៧) ។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកអនុវត្តកិច្ចការត្រូវបានជ្រើសរើសក្នុងចំណោមសមាជិកក្រុមហ៊ុន តាមកិច្ចសន្យាក្រុមហ៊ុន ប្រសិនបើយើងអនុញ្ញាតឱ្យបញ្ឈប់អ្នកអនុវត្តកិច្ចការនោះដូចកិច្ចសន្យាអាណត្តិនេះទៅ នឹងធ្វើឱ្យឋានៈរបស់សមាជិកអនុវត្តកិច្ចការនោះពុំមានស្ថិរភាព ហើយអាចមានឥទ្ធិពលខ្លាំងទៅលើលទ្ធផលនៃការអនុវត្តកិច្ចការ ។ ផ្ទុយទៅវិញ ប្រសិនបើមិនទទួលស្គាល់ការលាលែងទេ នឹងធ្វើឱ្យមានការកម្រិតយ៉ាងខ្លាំងចំពោះសេរីភាពរបស់អ្នកអនុវត្ត

កិច្ចការ ដូច្នេះហើយ វាជាការមួយដែលមិនសមរម្យទេ ។ ដោយពិនិត្យដល់បញ្ហាទាំងនេះទៅ កថាខណ្ឌទី ១ នៃមាត្រានេះ បានចែងទទួលស្គាល់នូវការលាលែង និង ការបញ្ឈប់របស់អ្នកអនុវត្តកិច្ចការ ប្រសិនបើមានមូលហេតុត្រឹមត្រូវ ។ម្យ៉ាងទៀត ដើម្បីបញ្ឈប់អ្នកអនុវត្តកិច្ចការដោយមានមូលហេតុត្រឹមត្រូវ ចាំបាច់ត្រូវមានសម្លេងយល់ព្រមរបស់សមាជិកផ្សេង លើសពាក់កណ្ដាល ។

(2) ក្នុងករណីដែលសមាជិកក្រុមហ៊ុនទាំងអស់អនុវត្តកិច្ចការក្រុមហ៊ុនវិញ បញ្ញត្តិនៃមាត្រានេះ មិនត្រូវយកមកអនុវត្តទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧១២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៥៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣២ នៃច្បាប់ស្ដីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧០៥.- សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិ

ទោះបីជាគ្មានសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុនក៏ដោយ ក៏សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះបានដែរ ។

(កំណត់)

(1) អាជីវកម្មរបស់ក្រុមហ៊ុន គឺជាអាជីវកម្មរួមរបស់សមាជិកទាំងអស់នៃក្រុមហ៊ុន ហើយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន គឺជាកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ហេតុនេះហើយ សមាជិកដែលពុំមានសិទ្ធិអនុវត្តកិច្ចការ ចាំបាច់ត្រូវមានសិទ្ធិដឹងអំពីស្ថានភាពនៃការអនុវត្តកិច្ចការ ឬ ស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ដូច្នេះហើយ មាត្រានេះទទួលស្គាល់សិទ្ធិស្រាវជ្រាវអំពីកិច្ចការ និង អំពីទ្រព្យសម្បត្តិ ដើម្បីធានាសិទ្ធិដឹងនេះ ។

(2) សិទ្ធិស្រាវជ្រាវនេះ គឺជាសិទ្ធិមូលដ្ឋានរបស់សមាជិកក្រុមហ៊ុន ហេតុនេះហើយ មិនអាចបដិសេធសិទ្ធិនេះដោយការសន្យាពិសេសឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលសិទ្ធិស្រាវជ្រាវនោះត្រូវបានប្រើប្រាស់ ក្នុងគោលបំណងរារាំងកិច្ចការរបស់ក្រុមហ៊ុន ការប្រើប្រាស់សិទ្ធិអាចបដិសេធបាន ដើម្បីការពារកុំឱ្យមានការប្រើសិទ្ធិនេះដោយបំពាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧៧៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៤១ នៃច្បាប់ស្ដីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧០៦.- សិទ្ធិទាមទារចែកចំណេញ ភាគនៃការបែងចែកការចំណេញ ខាត

១-សមាជិកក្រុមហ៊ុន ត្រូវគណនាការចំណេញ ខាត នៅក្នុងអំឡុងពេលទៀងទាត់ ហើយក្នុងករណីដែលមានចំណេញ អាចទាមទារឱ្យបែងចែកផលចំណេញនោះបាន ។

២-ប្រសិនបើសមាជិកក្រុមហ៊ុន មិនបានកំណត់ភាគនៃការបែងចែកការចំណេញ ខាតទេ ត្រូវកំណត់ទៅតាមសមាមាត្រនៃចំនួនតម្លៃវិនិយោគទ្រព្យធនរបស់សមាជិកនីមួយៗនៃក្រុមហ៊ុននោះ ។

៣-ប្រសិនបើបានកំណត់តែភាគនៃការបែងចែកចំពោះការចំណេញ ខាតណាមួយ ត្រូវសន្មតថាភាគនោះ ដូចគ្នាទៅនឹងការខាតបង់ និង ការចំណេញ ។

(កំណត់)

ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន មិនមែនមានត្រឹមតែផលចំណេញដែលបានមកពីសកម្មភាពអាជីវកម្មរួមរបស់ក្រុមហ៊ុនប៉ុណ្ណោះទេ គឺមានទាំងការខាតបង់ផងដែរ ហើយដែលជារបស់សមាជិកក្រុមហ៊ុនទាំងអស់ ។ ក៏ប៉ុន្តែ តាមស្ថានភាពផ្ទៃក្នុងរបស់ក្រុមហ៊ុន ជាទូទៅ គេធ្វើការបែងចែក ឬ ឱ្យសមាជិកម្នាក់ៗទទួលបន្ទុករៀងៗខ្លួន ។ ដោយឈរលើមូលដ្ឋាននេះ មាត្រានេះបានចែងអំពីសិទ្ធិទាមទារឱ្យធ្វើការបែងចែកផលចំណេញ (កថាខណ្ឌទី ១) ព្រមទាំងបានចែងកំណត់អំពីភាគនៃការបែងចែកចំណេញ និង ភាគនៃការទទួលបន្ទុកនូវការខាតបង់ផងដែរ (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត ប្រសិនបើមានការព្រមព្រៀងរបស់សមាជិកទាំងអស់របស់ក្រុមហ៊ុន អំពីភាគនៃការបែងចែកចំណេញ ឬ ភាគនៃការទទួលបន្ទុកនូវការខាតបង់ ត្រូវអនុលោមតាមការព្រមព្រៀងនោះ ដោយមិនអនុវត្តមាត្រានេះ ។ លើសពីនេះ ការព្រមព្រៀងឱ្យសមាជិកណាម្នាក់មិនទទួលបន្ទុកនូវការខាតបង់សោះ មានសុពលភាព ក៏ប៉ុន្តែ ការព្រមព្រៀងដែលមិនបែងចែកចំណែកនៃផលចំណេញឱ្យសមាជិកណាម្នាក់ គួរតែត្រូវបានបកស្រាយថាជាការព្រមព្រៀងមោឃៈ ដោយសារយោងតាមគោលដៅនៃក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងដើម្បីរកផលចំណេញនោះ ក្នុងករណីនេះ តាមផ្លូវរដ្ឋប្បវេណី មិនអាចហៅថាជាក្រុមហ៊ុនប្រកបកិច្ចការដោយសហការគ្នាបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៨៧ និង មាត្រា ១២៩២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៦៧៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៤៤-១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣៣ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០៧.-** ភាគដែលត្រូវទទួលបន្ទុកនៃការខាតបង់របស់សមាជិកក្រុមហ៊ុន ចំពោះម្ចាស់បំណុល

១-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចការរបស់ក្រុមហ៊ុន ជាកាតព្វកិច្ចដោយសាមគ្គីភាព ។ ប៉ុន្តែ កាតព្វកិច្ចនោះ ត្រូវសងដោយទ្រព្យសម្បត្តិក្រុមហ៊ុនសិន ហើយប្រសិនបើមិនអាចសងកាតព្វកិច្ចទាំងអស់ ដោយទ្រព្យសម្បត្តិក្រុមហ៊ុន ទើបសងដោយទ្រព្យដោយឡែករបស់សមាជិកនីមួយៗ ។

២-បន្ទុករបស់សមាជិកនីមួយៗ ត្រូវអនុលោមតាមសមាមាត្រនៃភាគវិនិយោគ លើកលែងតែមានការសន្យាពិសេស ។

(កំណត់)

(1) កាតព្វកិច្ចដែលកើតឡើងដោយសារកិច្ចការរបស់ក្រុមហ៊ុន អាចបែងចែកឱ្យសមាជិកក្រុមហ៊ុនម្នាក់ៗទទួលបន្ទុកបានដែរ ក៏ប៉ុន្តែ ការបែងចែកនេះនឹងធ្វើឱ្យខូចផលប្រយោជន៍ដល់ម្ចាស់បំណុលរបស់ក្រុមហ៊ុន ។ ដូច្នេះហើយ វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ បានចែងថា កាតព្វកិច្ចរបស់ក្រុមហ៊ុន ជាកាតព្វកិច្ចដោយសាមគ្គីភាពរបស់សមាជិកម្នាក់ៗ ។ ក៏ប៉ុន្តែ ដើម្បីសងកាតព្វកិច្ច (យកមកធ្វើជា "ទ្រព្យសម្បត្តិទទួលខុសត្រូវ"[៩]) ជាបឋម ត្រូវប្រើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនជាមុន ហើយក្នុងករណីដែលមិនអាចសងកាតព្វកិច្ចឱ្យបានអស់ទេ ទ្រព្យសម្បត្តិដោយឡែករបស់សមាជិករៀងៗខ្លួន នឹងក្លាយទៅជាទ្រព្យសម្បត្តិទទួលខុសត្រូវ ។ ចំណុចនេះមានចែងច្បាស់លាស់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ។

(2) សមាជិកក្រុមហ៊ុនម្នាក់ៗ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុន ក៏ប៉ុន្តែ តើសមាជិកម្នាក់ៗ ត្រូវទទួលបន្ទុកប៉ុន្មានភាគនោះ គឺជាបញ្ហាផ្ទៃក្នុងមួយ ។ ប្រសិនបើមានការសន្យាពិសេស ត្រូវអនុលោមតាមការសន្យាពិសេសនោះ ។ ក៏ប៉ុន្តែ សម្រាប់ករណីដែលពុំមានការសន្យាពិសេសទេ ចាំបាច់ត្រូវមានវិធានគោលមួយ ។ មានទស្សនៈខ្លះយល់ឃើញថា គួរតែឱ្យទទួលបន្ទុកស្មើភាពគ្នា ក៏ប៉ុន្តែ បើគិតទៅតាមសមាមាត្រនៃភាគវិនិយោគវិញ គឺជាការសមរម្យ ទៅតាមឆន្ទៈរបស់សមាជិកម្នាក់ៗ ហើយមានសមភាពផង ។ កថាខណ្ឌទី ២ ចែងបញ្ជាក់អំពីចំណុចនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៥៧ និង មាត្រា ១៨៥៨ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ៣ មាត្រា ៥៤៤ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧០៨.- ការហាមឃាត់មិនឱ្យទូទាត់កាតព្វកិច្ចក្រុមហ៊ុន

[៩] ចំពោះពាក្យ "ទ្រព្យសម្បត្តិទទួលខុសត្រូវ" សូមមើលកថាភាគទី ១ ផ្នែកទី ៣ ជំពូកទី ២ នៃ "សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ : ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ" (ក្រសួងយុត្តិធម៌ ២០០៩) ។

កូនបំណុលរបស់ក្រុមហ៊ុន ពុំអាចទូទាត់កាតព្វកិច្ចនោះ ជាមួយនឹងសិទ្ធិលើបំណុលចំពោះសមាជិកនីមួយៗនៃក្រុមហ៊ុន បានឡើយ ។

(កំណត់)

ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន មិនមែនត្រូវបែងចែកទៅឱ្យសមាជិកម្នាក់ៗទេ គឺជាកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ។ បើមិនធ្វើដូចនេះទេ នឹងមានការពិបាកក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ។ ដូច្នេះ ប្រសិនបើយកគំនិតនេះ មកធ្វើជាមូលដ្ឋាន មិនត្រូវទទួលស្គាល់ឱ្យកូនបំណុលនៃក្រុមហ៊ុនយកសិទ្ធិលើបំណុលដែលខ្លួនមានចំពោះសមាជិកម្នាក់ មកធ្វើការទូទាត់កាតព្វកិច្ចរបស់ខ្លួនដែលមានចំពោះក្រុមហ៊ុននោះឡើយ (មិនត្រូវទទួលស្គាល់ឱ្យកូនបំណុលនៃក្រុមហ៊ុនយកសិទ្ធិលើបំណុលដែលខ្លួនមានចំពោះសមាជិកម្នាក់ មកធ្វើជាសិទ្ធិលើបំណុលដែលផ្ដើមការទូទាត់ឡើយ) ។ មាត្រានេះបានចែងអំពីចំណុចនេះ ។ ម្យ៉ាងទៀត មាត្រានេះមានគោលគំនិតដូចគ្នានឹងមាត្រា ៧០១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ៧១៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧០៩.-** ការដកខ្លួនដោយស្ម័គ្រចិត្ត

១-ប្រសិនបើពុំបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុននៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ ឬ បើបានកំណត់អត្ថិភាពដែលក្រុមហ៊ុនត្រូវមាន ក្នុងរយៈពេលមួយជីវិតរបស់សមាជិកណាម្នាក់ សមាជិកនីមួយៗ អាចដកខ្លួនចេញ នៅពេលណាក៏បាន ។ ប៉ុន្តែការដកខ្លួននេះ ពុំអាចធ្វើបានឡើយ បើបណ្ដាលឱ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន លើកលែងតែក្នុងករណីដែលពុំអាចជៀសវាងបាន ។

២-ទោះបីជាបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុនក៏ដោយ នៅក្នុងករណីដែលពុំអាចជៀសវាងបាន សមាជិកនីមួយៗ អាចដកខ្លួនបាន ។

៣-ការដកខ្លួនអាចធ្វើទៅបាន ដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន ។

(កំណត់)

មាត្រានេះបានចែងថា សមាជិកម្នាក់ៗអាចសុំដកខ្លួនពីក្រុមហ៊ុនបានដោយស្ម័គ្រចិត្តបាន ហើយបានចែងអំពីល័ក្ខខ័ណ្ឌ និង វិធីដកខ្លួនចេញផងដែរ ។ ការដកខ្លួនដោយស្ម័គ្រចិត្តនេះអាចធ្វើបាន ដោយការបង្ហាញឆន្ទៈរបស់ខ្លួន ចំពោះសមាជិកផ្សេងៗ (កថាខណ្ឌទី ៣) ហើយចំពោះល័ក្ខខ័ណ្ឌវិញ ក្នុងករណីដែលមានកំណត់អំពីអំឡុងពេលដែលក្រុមហ៊ុនមាន

អត្ថិភាព ក្រៅពីអំឡុងពេលមួយជីវិតរបស់សមាជិកណាម្នាក់ សមាជិកអាចដកខ្លួនបានក្នុងករណីដែលមានហេតុដែល "ពុំអាចជៀសវាងបាន" ហើយក្រៅពីករណីនេះ សមាជិកអាចដកខ្លួនបាន នៅពេលដែលការដកខ្លួននោះ "បណ្តាលឱ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន" ឬ ទោះជាចំពេលដែលធ្វើឱ្យខូចផលប្រយោជន៍ក្រុមហ៊ុនក៏ដោយ តែប្រសិនបើមានហេតុដែល "មិនអាចជៀសវាងបាន" ក៏អាចដកខ្លួនបានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២៣, មាត្រា ៧២៤ និង មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧១០.-** ការដកខ្លួនតាមច្បាប់

ក្រៅពីបញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា ៧០៩ (ការដកខ្លួនដោយស្ម័គ្រចិត្ត) ខាងលើ សមាជិកក្រុមហ៊ុន ត្រូវដកខ្លួន ដោយមូលហេតុណាមួយ ដូចខាងក្រោមនេះ :

ក-មរណភាព ។

ខ-ធនក្ស័យ ។

គ-បានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ។

ឃ-ការលុបឈ្មោះ ។

(កំណត់)

(1) មាត្រានេះចែងអំពីការដកខ្លួនរបស់សមាជិកក្រុមហ៊ុនតាមច្បាប់ ។

(2) ទោះបីជាសមាជិកក្រុមហ៊ុនបានទទួលមរណភាព ហើយសមាជិកនោះលែងមានអត្ថិភាពក៏ដោយ ក៏មាត្រានេះចែងថា មរណភាពនេះជាមូលហេតុនៃការដកខ្លួន ។ មានន័យថា សន្តតិជនរបស់សមាជិកក្រុមហ៊ុននោះមិនត្រូវទទួលបន្តដោយស្វ័យប្រវត្តិ នូវឋានៈជាសមាជិកក្រុមហ៊ុននោះទេ ។ តាមធម្មតា ទំនុកចិត្តរវាងសមាជិក និង សមាជិក មានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុន ដូច្នេះហើយ ប្រសិនបើឱ្យសន្តតិជនរបស់សមាជិកដែលទទួលមរណភាព ស្នងបន្តដោយស្វ័យប្រវត្តិនូវឋានៈជាសមាជិកទៅ នឹងអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់អត្ថិភាពនៃក្រុមហ៊ុន ។ ហេតុនេះហើយ មាត្រានេះបានចែងថា មរណភាព គឺជាមូលហេតុនៃការដកខ្លួនចេញពីក្រុមហ៊ុន ។ ម្យ៉ាងទៀត ប្រសិនបើមានកំណត់ជាមុននៅក្នុងកិច្ចសន្យាក្រុមហ៊ុនថា ឱ្យសន្តតិជនរបស់សមាជិកស្នងបន្តនូវឋានៈជាសមាជិក នោះការស្នងបន្តនោះត្រូវបានទទួលស្គាល់ ។ នេះគឺដោយសារតែការយកមរណភាពជាមូលហេតុនៃការដកខ្លួននេះ គឺដើម្បីការពារផលប្រយោជន៍របស់សមាជិកផ្សេងទៀត ហើយប្រសិនបើបានកំណត់ជាមុននូវការស្នងបន្តនេះដោយកិច្ចសន្យាក្រុមហ៊ុន មិនធ្វើឱ្យបាត់បង់នូវផលប្រយោជន៍របស់សមាជិកផ្សេងទេ ។

(3) ចំពោះធនក្ស័យវិញ ចំណែករបស់សមាជិកធនក្ស័យនោះ ចាំបាច់ត្រូវទុកសម្រាប់សងកាតព្វកិច្ច ដើម្បីការពារម្ចាស់បំណុលធនក្ស័យ (ម្ចាស់បំណុលរបស់សមាជិកធនក្ស័យ) នោះ ហេតុដូច្នេះ មិនអាចបង្កើតការសន្យាពិសេសដែលអនុញ្ញាតឱ្យជនធនក្ស័យ នៅជាសមាជិក នៅក្នុងកិច្ចសន្យាក្រុមហ៊ុនបានទេ ។

(4) មាត្រានេះចែងថា ការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ គឺជាមូលហេតុនៃការដកខ្លួនពីក្រុមហ៊ុន ដើម្បីការពារផលប្រយោជន៍របស់សមាជិកផ្សេងទៀត ។ ហេតុដូច្នេះ ប្រសិនបើមានការសន្យាពិសេសក្នុងកិច្ចសន្យាក្រុមហ៊ុន ការប្រកាសចាប់ផ្ដើមអាណាព្យាបាលនេះ អាចត្រូវបានចេញពីមូលហេតុនៃការដកខ្លួនបាន ។

(5) ចំពោះការលុបឈ្មោះវិញ សូមមើលមាត្រា ៧១១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២៣, មាត្រា ៧២៧, មាត្រា ៧២៨, មាត្រា ៧៣៦ និង មាត្រា ៧៣៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៤៥ នៃច្បាប់ស្ដីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧១១.- ការលុបឈ្មោះ

ការលុបឈ្មោះសមាជិកក្រុមហ៊ុន អាចអនុវត្តបាន ដោយមតិយល់ព្រមជាឯកច្ឆន្ទពីសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន តែក្នុងករណីដែលមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ ។ ប៉ុន្តែ បើមិនបានជូនដំណឹងពីការលុបឈ្មោះ ដល់សមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះទេ ពុំអាចយកទៅតតាំងជាមួយនឹងសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះនោះ បានឡើយ ។

(កំណត់)

(1) ការលុបឈ្មោះ ដែលជាការដកលក្ខណសម្បត្តិរបស់សមាជិកក្រុមហ៊ុនដោយបង្ខំ ដោយសមាជិកក្រុមហ៊ុនផ្សេងទៀត គឺជាវិធីមួយដែលធ្វើឱ្យខូចផលប្រយោជន៍របស់សមាជិកដែលត្រូវលុបឈ្មោះនោះ ។ ផ្ទុយទៅវិញ ចំពោះក្រុមហ៊ុនដែលយកទំនុកចិត្តរវាងសមាជិកទាំងអស់មកធ្វើជាមូលដ្ឋានវិញ ប្រសិនបើទុកឋានៈសមាជិកដែលបាត់បង់នូវទំនុកចិត្ត ឱ្យនៅដដែលនៅក្នុងក្រុមហ៊ុននោះទៅ មិនមែនជាការល្អចំពោះដំណើរការនៃកិច្ចការរួមរបស់ក្រុមហ៊ុននោះទេ ។ ដូច្នេះហើយ មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌនៃការលុបឈ្មោះ ដើម្បីសម្របសម្រួលផលប្រយោជន៍ទាំងពីរនេះ ។

(2) មាត្រានេះ បានចែងថា ក្នុងករណីដែលមាន "មូលហេតុត្រឹមត្រូវ" ការលុបឈ្មោះអាចធ្វើបាន "ដោយមតិយល់ព្រមជាឯកច្ឆន្ទ ពីសមាជិកផ្សេងទៀតទាំងអស់" ហើយអានុភាពនៃការលុបឈ្មោះនេះ មិនអាចតតាំងនឹងសមាជិកដែលត្រូវបានលុបឈ្មោះបានទេ ប្រសិនបើមិនបានជូនដំណឹងទៅឱ្យសមាជិកនោះ ។ ម្យ៉ាងទៀត ចំពោះការលុបឈ្មោះ មានមតិខ្លះថា គួរតែទាមទារឱ្យមានសាលក្រម ឬ សាលដីការបស់តុលាការ ក៏ប៉ុន្តែ ប្រសិនបើបានធ្វើការជូនដំណឹងអំពីការលុបឈ្មោះ

ក្នុងករណីដែលសមាជិកដែលត្រូវបានលុបឈ្មោះនោះមិនពេញចិត្ត សមាជិកនោះអាចដាក់ពាក្យបណ្ដឹងទៅតុលាការបាន ហើយអាចទទួលលទ្ធផលដូចគ្នាបានដែរ ហេតុដូច្នេះ នៅក្នុងមាត្រានេះ មិនបានយកសាលក្រម ឬ សាលដីការបស់តុលាការ មកធ្វើជាល័ក្ខខ័ណ្ឌនៃការលុបឈ្មោះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧១២.-** ការសងវិញ នូវចំណែករបស់សមាជិកក្រុមហ៊ុន ដែលដកខ្លួន

១-ការគណនារវាងសមាជិកក្រុមហ៊ុនដែលបានដកខ្លួន និង សមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ចាំបាច់ត្រូវអនុវត្ត ដោយផ្អែកតាមស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន នៅពេលដែលដកខ្លួននោះ ។

២-ចំណែកដែលសមាជិកក្រុមហ៊ុនដែលបានដកខ្លួននោះមាន អាចសងវិញជាប្រាក់បាន ដោយពុំគិតពីប្រភេទនៃទ្រព្យធនដែលវិនិយោគនោះឡើយ ។

៣-ចំពោះចំណុចដែលពុំទាន់បានបញ្ចប់ នៅពេលដកខ្លួន អាចគណនាបាន នៅក្រោយពេលធ្វើការបញ្ចប់នោះ ។

៤-ការសងចំណែកដែលមាន ទៅសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះ ត្រូវភ្ជាប់ការប្រាក់ តាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ចំពោះអំឡុងពេលគិតចាប់ពីពេលដែលបានជូនដំណឹងអំពីការលុបឈ្មោះ រហូតដល់ពេលដែលបានសងវិញ ។

(កំណត់)

(1) អតីតសមាជិកក្រុមហ៊ុនដែលបានបាត់បង់នូវលក្ខណសម្បត្តិជាសមាជិក ត្រូវបាត់បង់នូវសិទ្ធិ ព្រមទាំងកាតព្វកិច្ចវិនិយោគរបស់សមាជិកក្រុមហ៊ុន ។ ហេតុនេះហើយ ចាំបាច់ត្រូវគណនាទ្រព្យសម្បត្តិរវាងសមាជិកនេះ និង ក្រុមហ៊ុន ។ នេះគឺជាការសងវិញនូវចំណែករបស់សមាជិក ។

(2) មាត្រានេះចែងអំពីការសងនូវចំណែករបស់សមាជិក ។ ការសងនូវចំណែករបស់សមាជិកត្រូវធ្វើទៅតាមស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនពេលដកខ្លួនចេញនោះ ហើយអាចសងជាសាច់ប្រាក់បាន ។ ម្យ៉ាងទៀត ពេលដែលសមាជិកបានដកខ្លួនចេញ ប្រសិនបើមានការពិបាកក្នុងការគណនាដោយសារកិច្ចការរបស់ក្រុមហ៊ុនមិនទាន់បានបញ្ចប់ទេ អាចធ្វើការគណនាក្រោយពេលកិច្ចការនោះបញ្ចប់បាន ។

(3) ម្យ៉ាងទៀត ចំពោះការសងវិញនូវចំណែករបស់សមាជិកដែលត្រូវបានលុបឈ្មោះ ត្រូវបូកបន្ថែមនូវការប្រាក់ ដោយគិតពីថ្ងៃដែលបានជូនដំណឹងអំពីការលុបឈ្មោះនោះ ដល់ថ្ងៃដែលបានសងចំណែកនោះ ។ ក្នុងករណីនៃការលុបឈ្មោះ

អាចនឹងមានវិវាទច្រើនពាក់ព័ន្ធនឹងការលុបឈ្មោះនេះ ហើយត្រូវការពេលវេលាយូរដើម្បីដោះស្រាយ ដូច្នេះហើយ ដើម្បីជៀសវាងនូវការបាតបង់ផលប្រយោជន៍របស់សមាជិកដែលត្រូវគេលុបឈ្មោះចោលនោះ ទើបមានការចែងដូចកថាខណ្ឌទី ៤ នៃមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧៣៨ និង កថាខណ្ឌទី ២ មាត្រា ៧៤០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧១៣.-** ការរំលាយក្រុមហ៊ុន

១-ក្រុមហ៊ុន ត្រូវរំលាយតាមករណីណាមួយ ដូចកំណត់ខាងក្រោមនេះ :

ក-ការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុន ឬ អលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ។

ខ-បើមានការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន ។

គ-បើនៅសល់សមាជិកក្រុមហ៊ុន តែម្នាក់ ។

ឃ-បើអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវបានបញ្ចប់ ។

២-ក្នុងករណីដែលមានមូលហេតុមិនអាចជៀសវាងបាន សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចទាមទារឱ្យរំលាយក្រុមហ៊ុនបាន ។

៣-ការទាមទារនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់ របស់ក្រុមហ៊ុន ។

(កំណត់)

(1) ការរំលាយក្រុមហ៊ុន រំសាយចំណងរបស់សមាជិក បញ្ចប់ និង រំលាយទំនាក់ទំនងគតិយុត្តដែលត្រូវបានកសាងឡើង ហើយតម្រូវឱ្យត្រៀមចាប់ផ្តើមជម្រះបញ្ជី ។ មាត្រានេះចែងអំពីមូលហេតុ និង វិធីរំលាយក្រុមហ៊ុន ។

(2)ចំណុច ក នៃកថាខណ្ឌទី ១ ចែងអំពីករណីបញ្ចប់កិច្ចការដែលជាគោលបំណងនៃក្រុមហ៊ុន ឬ កិច្ចការនោះមិនអាចសម្រេចបាន ។ ពេលបានបញ្ចប់កិច្ចការ គោលបំណងរបស់ក្រុមហ៊ុននោះត្រូវបានសម្រេច ដូច្នេះហើយមិនចាំបាច់ឱ្យមានអត្ថិភាពបន្តទៀតទេ ហើយក្នុងករណីនៃអលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ក៏គ្មានអត្ថន័យអ្វីឱ្យមានអត្ថិភាពបន្តទៀតដែរ ។

(3)ចំណុច ខ នៃកថាខណ្ឌទី ១ ចែងអំពីករណីដែលមានការព្រមព្រៀងពីសមាជិកទាំងអស់ ។ ប្រសិនបើមានការព្រមព្រៀងពីសមាជិកទាំងអស់គ្នា លែងមានអត្ថន័យអ្វីនឹងទុកឱ្យមានអត្ថិភាពបន្តទៀតទេ ។ ម្យ៉ាងទៀត ការព្រមព្រៀង

នេះមិនចាំបាច់ធ្វើជាលាយល័ក្ខណ៍អក្សរទេ ។ ក្រោយពីបានរំលាយ នៅវង់ចាំតែធ្វើការជម្រះបញ្ជីដើម្បីរំលត់ខ្លួនប៉ុណ្ណោះ ដូច្នេះហើយមិនចាំបាច់ទាមទារឱ្យធ្វើជាលាយល័ក្ខណ៍អក្សរឡើយ ។

(4) ចំណុច គ នៃកថាខណ្ឌទី ១ ចែងអំពីករណីដែលសមាជិកក្រុមហ៊ុនបែរជានៅតែម្នាក់ ហើយបានបាត់បង់នូវលក្ខណៈសារធាតុជាក្រុម ។ យើងអាចទទួលស្គាល់ក្រុមហ៊ុនដែលមានសមាជិកតែម្នាក់ក៏បានដែរ ក៏ប៉ុន្តែ ពុំមានផលប្រយោជន៍ក្នុងការទទួលស្គាល់ក្រុមហ៊ុនដែលមានសមាជិកតែម្នាក់ឡើយ ។ ម្យ៉ាងទៀត ពេលដែលភាគីនៃកិច្ចសន្យាក្រុមហ៊ុនមានតែម្នាក់ កិច្ចសន្យានោះអាចចាត់ទុកថាបានរលត់ក៏បានដែរ ប៉ុន្តែ មាត្រានេះបានចាត់ទុកករណីនេះថាជាទម្រង់មួយនៃការរំលាយដែរ ។

(5) ចំណុច ឃ នៃកថាខណ្ឌទី ១ ចែងអំពីករណីដែលអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវបានបញ្ចប់ ។ ដោយសារតែបានធ្វើការកំណត់នូវអំឡុងពេលដែលមានអត្ថិភាពក្នុងកិច្ចសន្យាក្រុមហ៊ុន គ្មានបញ្ហាអ្វីដែរក្នុងការចែងថា ក្រុមហ៊ុននោះនឹងចូលដល់ដំណាក់កាលត្រៀមរំលត់ខ្លួន នៅពេលបញ្ចប់អំឡុងពេលនោះ តាមកិច្ចសន្យាក្រុមហ៊ុននោះទេ ។

(6) កថាខណ្ឌទី ២ ចែងអំពីការទាមទារឱ្យរំលាយពីសមាជិក ។ ក្នុងនេះ មានចែងថា សមាជិកអាចទាមទារឱ្យរំលាយក្រុមហ៊ុនបានដោយការបង្ហាញឆន្ទៈរបស់ខ្លួនចំពោះសមាជិកផ្សេងទៀត ដោយយកអត្ថិភាពនៃមូលហេតុមិនអាចជៀសវាងបាន មកធ្វើជាល័ក្ខខ័ណ្ឌ ។ មូលហេតុដែលមិនអាចជៀសវាងបាន មានដូចជា ករណីដែលមានការលំបាកខ្លាំងក្នុងការបន្តធ្វើកិច្ចការរបស់ក្រុមហ៊ុន ដោយសារការមិនចុះសំរុងគ្នារវាងសមាជិក ការផ្លាស់ប្តូរនៃស្ថានភាពសេដ្ឋកិច្ច ឬ ការផ្លាស់ប្តូរនៃស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨២ និង មាត្រា ៦៨៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៧១៤.- ភាពគ្មានប្រតិសកម្មនៃការរំលាយ

ការរំលាយក្រុមហ៊ុន ពុំមានអានុភាពប្រតិសកម្មឡើយ ។

(កំណត់)

ការអនុវត្តប្រតិសកម្មនូវអានុភាពនៃការរំលាយក្រុមហ៊ុន នឹងធ្វើឱ្យទំនាក់ទំនងគតិយុត្តកាន់តែស្មុគស្មាញទៅ ហេតុនេះហើយ គ្រាន់តែឱ្យមានអានុភាពឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៧១៥.- អ្នកជម្រះបញ្ជី

១-ប្រសិនបើក្រុមហ៊ុនត្រូវបានរំលាយ ការជម្រះបញ្ជីត្រូវធ្វើ ដោយសហការគ្នារវាងសមាជិកទាំងអស់របស់ក្រុមហ៊ុន ឬ ដោយអ្នកជម្រះបញ្ជី ដែលត្រូវបានជ្រើសតាំងដោយសមាជិកក្រុមហ៊ុន ។

២-ការជ្រើសតាំងអ្នកជម្រះបញ្ជីនៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលគ្មានកំណត់ពិសេសនៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកក្រុមហ៊ុននោះ ។

(កំណត់)

ដូចដែលបានពន្យល់រួចមកហើយ ការរំលាយមានន័យថា ការចាប់ផ្ដើមធ្វើសកម្មភាពដើម្បីរំលត់ក្រុមហ៊ុន ។ ដើម្បីរំលត់ក្រុមហ៊ុននាអនាគត ចាំបាច់ត្រូវជម្រះបញ្ជីទ្រព្យសម្បត្តិ ហើយដើម្បីធ្វើការងារនេះ ត្រូវតែកំណត់អ្នកជម្រះបញ្ជី ។ នេះគឺជាគោលគំនិតដូចអ្នកអនុវត្តកិច្ចការដែរ ។ ដូច្នេះហើយ សមាជិកម្នាក់ៗ ត្រូវធ្វើការងារជម្រះបញ្ជី ដោយសហការគ្នា ឬ ជ្រើសតាំងអ្នកជម្រះបញ្ជី ដើម្បីឱ្យធ្វើការងារជម្រះបញ្ជី ។ម្យ៉ាងទៀត កថាខណ្ឌទី ២ ចែងអំពីនីតិវិធីជ្រើសតាំងអ្នកជម្រះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧១៦**.- ការអនុវត្តកិច្ចការរបស់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០២ (វិធីអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលអ្នកជម្រះបញ្ជី មានចំនួនច្រើននាក់ ។

(កំណត់)

ដូចដែលបានពន្យល់ក្នុងមាត្រា ៧១៥ ដែរ អ្នកជម្រះបញ្ជីមានសិទ្ធិអំណាចត្រឹមតែធ្វើសកម្មភាពដើម្បីជម្រះបញ្ជីប៉ុណ្ណោះ ក៏ប៉ុន្តែ ឋានៈរបស់អ្នកនោះប្រហាក់ប្រហែលគ្នានឹងឋានៈរបស់អ្នកអនុវត្តកិច្ចការដែរ ។ ហេតុនេះហើយ ក្នុងករណីដែលមានអ្នកជម្រះបញ្ជីច្រើនរូប បញ្ញត្តិនៃមាត្រា ៧០២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧១៧**.- ការលាឈប់ និង ការបញ្ឈប់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០៤ (ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន បានព្រមព្រៀងជ្រើសតាំងអ្នកជម្រះបញ្ជី ពីក្នុងចំណោមសមាជិកក្រុមហ៊ុននោះ ។

(កំណត់)

ស្តីពីឋានៈរបស់អ្នកជម្រះបញ្ជី មានពន្យល់នៅក្នុងមាត្រា ៧១៥ និង មាត្រា ៧១៦ ហើយ ។ ហេតុនេះហើយ ចំពោះការលាឈប់ និង ការបញ្ឈប់អ្នកជម្រះបញ្ជី ដែលត្រូវបានជ្រើសតាំងដោយការព្រមព្រៀងរបស់សមាជិកក្រុមហ៊ុន មាត្រា ៧០៤ ស្តីពីអ្នកអនុវត្តកិច្ចការដែលត្រូវបានជ្រើសតាំងដោយកិច្ចសន្យាក្រុមហ៊ុន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧១៨**.- មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី វិធីបែងចែកទ្រព្យសម្បត្តិដែលនៅសេសសល់

១-បញ្ញត្តិនៃមាត្រា ៧១ (មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទី និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី ។

២-ទ្រព្យសម្បត្តិដែលនៅសេសសល់ ត្រូវបែងចែកដោយសមាមាត្រតាមតម្លៃនៃទ្រព្យធនដែលសមាជិកនីមួយៗរបស់ក្រុមហ៊ុន បានវិនិយោគ ។

(កំណត់)

ចំពោះមុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជីក្រុមហ៊ុន បញ្ញត្តិស្តីពីអ្នកជម្រះបញ្ជីនីតិបុគ្គល ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយសារតែការងាររបស់អ្នកទាំងពីរនេះមានលក្ខណៈដូចគ្នា ។

ម្យ៉ាងទៀត ពេលជម្រះបញ្ជីហើយ ហើយទ្រព្យសម្បត្តិនៅសល់ ត្រូវបែងចែកទៅឱ្យសមាជិកទៅតាមចំនួនទឹកប្រាក់នៃការវិនិយោគរបស់សមាជិកម្នាក់ៗ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) និង មាត្រា ៥១៣ (ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា) នៃក្រមរដ្ឋប្បវេណី សំដៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូត ។

ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

ខ-លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា ។

ក្នុងករណីនេះ កាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

គ-លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណភាព។

ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាព ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

ឃ-លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។

ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ។

**មាត្រា ៩.- អត្ថន័យនៃលិខិតយថាភូត**

"លិខិតយថាភូត" ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្ទីការ) មាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្ទីការ) និងមាត្រា៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ ។

ខ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៤៥ (ការតតាំងនៃហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ១១៧២ (បុគ្គលដែលមិនអាចក្លាយជាសាក្សីជាអាទិ៍) មាត្រា ១១៧៣ (មរតកសាសន៍ដោយលិខិតយថាភូត) និង មាត្រា ១១៨១ (បទប្បញ្ញត្តិពិសេសចំពោះមរតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី ឬ កុងស៊ុលតាមបញ្ញត្តិនៃមាត្រានីមួយៗ ខាងលើនេះ ។

## មាត្រា ១០.- ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលត្រូវទទួលបន្ទុកកិច្ចការសារការីជាបណ្ដោះអាសន្នតាមតម្រូវការចាំបាច់ នៅក្នុងអំឡុងពេលរហូតដល់មានការកំណត់ផ្សេងនៅក្នុងច្បាប់មិនលើសពី ២ នាក់ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូង ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា ឬ ឥស្សរជនជាមន្ត្រីរាជការសាធារណៈ ដែលមានបទពិសោធន៍ការងារផ្នែកវិស័យច្បាប់ និង មានសញ្ញាបត្រនីតិសាស្ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ។

២-ចៅក្រមដែលត្រូវបានកំណត់ថាជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវបានចាត់ទុកថា មានហេតុនៃការដកហូតសមត្ថកិច្ចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្តីដែលខ្លួនបានចាត់ចែងកិច្ចការសារការី ។

៣-ចំពោះសារការី និងមន្ទីរសារការីដែលបានតែងតាំងនិងបង្កើតឡើងមុនច្បាប់នេះ ត្រូវបន្តមានសមត្ថកិច្ចបំពេញកិច្ចការសារការីស្របតាមក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ជាធរមាន ។

## មាត្រា ១១.- សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការី ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី និងច្បាប់នេះ ដូចជាការផ្តល់សេចក្តីបញ្ជាក់លើលក្ខន្តិកៈ ការធ្វើលិខិតយថាភូត ជាអាទិ៍ ជាបណ្ដោះអាសន្ន ។

២-ដើម្បីធ្វើលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៩ (អត្ថន័យនៃលិខិតយថាភូត) នៃច្បាប់នេះ មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវពិនិត្យ និង បញ្ជាក់អត្តសញ្ញាណរបស់ភាគីដោយសាក្សី ឬ សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ហើយក្រៅពីនេះត្រូវធ្វើការចាត់ចែងដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ។

៣-បុគ្គលដែលប្រើប្រាស់សេវារបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបង់ពន្ធ ។ ចំណូលពន្ធនេះត្រូវបង្វែរចូលទៅថវិកាជាតិ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ ថ្ងៃទី........ខែ....................ឆ្នាំ................

## <u>កិច្ចព្រមព្រៀងសហការ</u>

**ភាគី "ក"** មន្ទីរពេទ្យ X

អាស័យដ្ឋានៈ.......................................................................

ទូរស័ព្ទលេខៈ................................

តំណាងដោយលោក........................

**ភាគី "ខ"** ក្រុមហ៊ុន Y

អាស័យដ្ឋានៈ.......................................................................

ទូរស័ព្ទលេខៈ................................

តំណាងដោយលោក........................

ក្រោយការពិភាក្សាគ្នារួច ភាគីទាំងពីរបានឯកភាព និងព្រមព្រៀងទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

**<u>ប្រការ ១ :</u>** ការសហការ

-ភាគី ក ជាម្ចាស់ទីតាំងពេទ្យX និងភាគី ខ ជាម្ចាស់ម៉ាស៊ីន CT SCAN 8 Slices ហើយភាគីទាំងពីរបានព្រមព្រៀងសហការគ្នាវិនិយោគ។

**<u>ប្រការ ២ :</u>** ការបែងចែកភាគហ៊ុន

-ភាគី ក ទទួលបាន ២៥% នៃប្រាក់ចំណូលសុទ្ធ (ក្រោយការទូទាត់ចំណាយរួចរាល់) ដែលទទួលបានជារៀងរាល់ខែនីមួយៗ។

-ភាគី ខ ទទួលបាន ៧៥% នៃប្រាក់ចំណូលសុទ្ធ (ក្រោយការទូទាត់ចំណាយរួចរាល់) ដែលទទួលបានជារៀងរាល់ខែនីមួយៗ។

**<u>ប្រការ ៣ :</u>** រយៈពេលនៃកិច្ចព្រមព្រៀង

-កិច្ចព្រមព្រៀងនេះ មានរយៈពេល១០ឆ្នាំ គិតចាប់ពីថ្ងៃទី………..ខែ…………..ឆ្នាំ២០១០ ជាថ្ងៃចុះកិច្ចសន្យា រហូតដល់ថ្ងៃទី…………ខែ……………ឆ្នាំ…….......ដោយគ្មានការប្រែប្រួលនូវលក្ខខណ្ឌនៃការបែងចែកភាគហ៊ុនឡើយ។

**<u>ប្រការ ៤ :</u>** កាតព្វកិច្ចរបស់ភាគី ក

-ផ្តល់អគ្គិសនី និងទឹកដល់ភាគី ខ ដោយមិនគិតថ្លៃ ហើយត្រូវធានាចរន្តអគ្គិសនីគ្រប់គ្រាន់ និងដំណើរការបានល្អ។ ក្នុងករណីម៉ាស៊ីន CT Scan មានបញ្ហាដោយសារចរន្តអគ្គិសនី នោះភាគី ក ជាអ្នកទទួលខុសត្រូវ ហើយភាគី ខ នឹងកាត់យកប្រាក់មួយចំនួនពីចំណូលសុទ្ធ នៃការបម្រើសេវាកម្មម៉ាស៊ីន CT Scan នៃចំណែករបស់ភាគី ក ដើម្បីធ្វើការជួសជុល។

-ផ្តល់បន្ទប់ដាក់ម៉ាស៊ីន CT Scan ដល់ភាគី ខ ដោយមិនគិតថ្លៃ។

-ផ្តល់ការសម្អាតបន្ទប់ម៉ាស៊ីន CT Scan គ្រប់ពេលក្នុងម៉ោងធ្វើការ។

-ទទួលខុសត្រូវសម្របសម្រួលជាមួយវេជ្ជបណ្ឌិត ដើម្បីការពារកុំឱ្យអ្នកជម្ងឺហូរចេញទៅមន្ទីរពេទ្យខាងក្រៅ។

-ទទួលខុសត្រូវសម្របសម្រួលគ្រប់ការងារច្បាប់ដែលទាក់ទងនឹងរាជរដ្ឋាភិបាល និងផ្នែកដែលពាក់ព័ន្ធ។

-ត្រូវធានា និងសន្យាថា មិនអនុញ្ញាតឱ្យមានឧបករណ៍ម៉ាកផ្សេងក្រៅពី GE ប្រភេទ CORE DI ដូចជា CT, MRI, Mammography, X-Ray, Angiography, និង C-Arm មកវិនិយោគក្នុងមន្ទីរពេទ្យ នៅក្នុងអំឡុងពេលនៃកិច្ចព្រមព្រៀងនេះឡើយ។ ក្នុងករណីមានឧបករណ៍ម៉ាកផ្សេងកើតឡើង នោះភាគី ក ត្រូវសងប្រាក់មកភាគី ខ វិញភ្លាម ស្មើនឹងទឹកប្រាក់០៣ដង នៃតម្លៃសរុបម៉ាស៊ីន CT Scan។

**<u>ប្រការ ៥ :</u>** កាតព្វកិច្ចរបស់ភាគី ខ

-ធ្វើការវិនិយោគម៉ាស៊ីន CT Scan 8 Slices ដែលជាម៉ាស៊ីនថ្មីរបស់ GE។

-ជួសជុល និងរៀបចំបន្ទប់ CT Scan។

-គ្រប់គ្រងហិរញ្ញវត្ថុក្នុងកំឡុងពេលវិនិយោគ។

-គ្រប់គ្រងផ្នែករដ្ឋបាលរបស់ CT Scan ក្នុងកំឡុងពេលវិនិយោគ។

-គាំត្របច្ចេកទេស និងប្រតិបត្តិការ។

-គ្រប់គ្រងបុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់ CT Scan។

-អាចធ្វើទំនើបរូបនីយកម្ម បច្ចេកទេស ឬ បន្ថែមម៉ាស៊ីនបន្ទាប់ពី០៥ឆ្នាំ នៃការវិនិយោគលើកទី១។

-ជួសជុលម៉ាស៊ីន CT Scan។

-ទទួលខុសត្រូវលើការចំណាយទាំងអស់ដែលទាក់ទងនឹងម៉ាស៊ីន CT Scan។

-ផ្តល់របាយការណ៍ចំណូលចំណាយប្រចាំខែទៅភាគី ក រៀងរាល់ខែ។

-ត្រូវបង់ទឹកប្រាក់ចំនួន ២៥% នៃប្រាក់ចំណូលសុទ្ធ បន្ទាប់ពីបិទបញ្ជីរៀងរាល់ខែឱ្យភាគី ក។

<u>**ប្រការ ៦**</u> : កាទទួលខុសត្រូវរបស់ភាគីទាំងពីរ

-បង្កើតយុទ្ធសាស្រ្តធ្វើយ៉ាងណាឱ្យការវិនិយោគនេះមានការរីកចម្រើនឡើង។

-សហការគ្នាធ្វើការផ្សាយពាណិជ្ជកម្មជាមួយរដ្ឋបាល ក៏ដូចជាវិស័យឯកជនដែរដែលបង្ហាញថា មន្ទីរពេទ្យ X មានម៉ាស៊ីន CT Scan។

-មានការប្រជុំរៀងរាល់ត្រីមាស ០១ដង ក្នុងករណីចាំបាច់អាចមានការស្នើប្រជុំប្រញាប់។

-គោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

-កំណត់តម្លៃសមរម្យ និងប្រកួតប្រជែងសម្រាប់អ្នកជម្ងឺ។

-ភាគីទាំងពីរអាចចាប់ផ្តើមពិភាក្សាការវិនិយោគថ្មី ដូចជា MRI, Angiography និងសម្ភារៈផ្សេងទៀត ក្នុងកាលៈទេសៈសមរម្យ។

-ភាគីទាំងពីរ ត្រូវរក្សាការសំងាត់ចំពោះគម្រោងថ្មី និងឱកាសក្នុងការវិនិយោគ។

<u>**ប្រការ ៧ :**</u> ការបញ្ចប់កិច្ចព្រមព្រៀង

-ភាគីទាំងពីរបានឯកភាពគ្នាថា ក្នុងករណីការវិនិយោគនេះអស់រយៈពេល ០៥ឆ្នាំ ហើយពុំមានចំណូលគ្រប់គ្រាន់អាចបន្តទៅទៀតបាន នោះភាគីទាំងពីរត្រូវពិភាក្សាដើម្បីបញ្ចប់កិច្ចព្រមព្រៀង ឬបន្តទៀត។

-ក្នុងករណីភាគី ក បញ្ចប់កិច្ចព្រមព្រៀងមុនកាលកំណត់ នោះភាគី ក ត្រូវឯកភាពទិញម៉ាស៊ីន CT Scan ពីភាគី ខ ក្នុងតម្លៃមួយបន្ទាប់ពីគិតរំលោះអស់។

-ក្រោយដល់កាលកំណត់នៃរយៈពេលត្រូវបញ្ចប់កិច្ចព្រមព្រៀងនេះ ភាគីទាំងពីរត្រូវជូនដំណឹងឱ្យបានដឹងមុនរយៈពេល ០៦ខែ ថាតើត្រូវបញ្ចប់ ឬបន្តកិច្ចព្រមព្រៀងនេះ។ ក្រោយបញ្ចប់កិច្ចព្រមព្រៀង ភាគី ក បានឯកភាពទិញម៉ាស៊ីន CT Scan ពីភាគី ខ ក្នុងតម្លៃមួយបន្ទាប់ពីគិតរំលោះអស់។

**ប្រការ ៨ :** អ្នកស្នង

-កិច្ចព្រមព្រៀងនេះ ដាក់កាតព្វកិច្ចទៅលើទាយាទ ឬអ្នកស្នងស្របច្បាប់របស់ភាគីទាំងពីរ។

**ប្រការ ៩ :** ច្បាប់អភិបាល

-កិច្ចព្រមព្រៀងនេះ ត្រូវស្ថិតនៅក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១០** : កិច្ចព្រមព្រៀងបន្ថែម

-ក្នុងករណីមានជំលោះកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយដោយសន្តិវិធីដោយការចរចារមានលក្ខណៈយោគយល់គ្នាជាមិត្តភាព ឬដោយសម្របសម្រួលផ្នែកពាណិជ្ជកម្មកម្ពុជា។

-បើការដោះស្រាយជំលោះតាមលក្ខណៈសន្តិវិធីមិនបានសម្រេច

ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ដែលមានសមត្ថកិច្ច ដើម្បីវិនិច្ឆ័យតាមច្បាប់។ ចំពោះការប្តឹងទៅតុលាការ ភាគីបង្កកំហុសជាអ្នកចេញសោហ៊ុយផ្សេងៗ រួមទាំងសោហ៊ុយសម្រាប់មេធាវីផងដែរ។

**ប្រការ ១១** : កិច្ចព្រមព្រៀង ធ្វើឡើងដោយស្ម័គ្រចិត្តរវាងភាគីទាំងពីរ ដោយឆន្ទៈពិតប្រាកដដោយសេរី ពុំមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

-គូភាគីនៃកិច្ចព្រមព្រៀង បានអាន និងបានព្រមព្រៀងទាំងស្រុងលើខ្លឹមសារដែលមានចែងខាងលើ និងប្តេជ្ញាគោរពយ៉ាងម៉ឺងម៉ាត់គ្រប់ប្រការទាំងអស់ ហើយយល់ព្រមផ្តិតស្នាមមេដៃ ឬចុះហត្ថលេខានៅចំពោះមុខសាក្សី និងមេធាវី។ កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ មានចំនួន ០៣ច្បាប់ដើម មាន០៤ ទំព័រ ជាភាសាខ្មែរ ០៣ច្បាប់ដើម ដែលច្បាប់នីមួយៗមានតម្លៃស្មើគ្នា ហើយភាគីទាំងពីរត្រូវរក្សាទុកម្នាក់០១ច្បាប់ និងតម្កល់ទុកនៅការិយាល័យមេធាវី ០១ច្បាប់។

**កិច្ចព្រមព្រៀងនេះ មានអនុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។**

**ស្នាមមេដៃស្តាំភាគី "ខ"** **សាក្សី** **ភាគី "ក"**

<u>បានឃើញ និងបញ្ជាក់ថា:</u>

ភាគីទាំងពីរពិតជាបានផ្តិតមេដៃស្តាំ និងចុះហត្ថលេខាចំពោះមុខមេធាវី ប្រាកដមែន។

ថ្ងៃទី…………ខែ…………ឆ្នាំ……………

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាសហការប្រកបអាជីវកម្ម

**កិច្ចសន្យាសហការប្រកបអាជីវកម្មនេះ (តទៅហៅថា កិច្ចសន្យា)** ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និងមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃទី……………..ខែ…………ឆ្នាំ……………. រវាង:

លោក……………………សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ………….. ចុះថ្ងៃទី…………………. មានទីលំនៅអចិន្ត្រៃយ៍ស្ថិតនៅ……………………….ទូរស័ព្ទលេខ…… ……………………..(តទៅហៅថា**ភាគី ក**)។

**និង**

លោក……………………សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ………….. ចុះថ្ងៃទី…………………. មានទីលំនៅអចិន្ត្រៃយ៍ស្ថិតនៅ……………………….ទូរស័ព្ទលេខ…… ……………………..(តទៅហៅថា**ភាគី ខ**)។

ភាគី ក និងភាគី ខ ម្ខាងៗត្រូវបានហៅថាជាភាគីនៃកិច្ចសន្យានេះ និងជារួមគ្នាហៅថាគូភាគី។

**ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក**
**គូភាគីទាំងបានព្រមព្រៀងគ្នាដូចតទៅ:**

## ប្រការ ១ : គោលបំណងនៃកិច្ចសន្យា

កិច្ចសន្យានេះ កំណត់អំពីទំនាក់ទំនង និងលក្ខខណ្ឌ នៃកិច្ចសន្យាសហការរបស់គូភាគី លើអាជីវកម្ម……………………….ព្រមទាំងសកម្មភាពដែលពាក់ព័ន្ធ ស្របតាមអាជ្ញាប័ណ្ណ ឬការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**<u>ប្រការ ២</u> : កិច្ចសហការអាជីវកម្ម**

គូភាគីព្រមព្រៀងចូលរួមវិនិយោគជាមួយគ្នា និងបែងចែកការទទួលខុសត្រូវលើកិច្ចវិនិយោគធ្វើអាជីវកម្មរួមគ្នា តាមចំណែកភាគហ៊ុនដូចខាងក្រោម៖

១. ភាគី ក ទទួលបាន ហុកសិបភាគរយ (៦០%) នៃទុនវិនិយោគ

២. ភាគី ខ ទទួលបាន សែសិបភាគរយ(៤០%) នៃទុនវិនិយោគ

ចំពោះដើមទុនក្នុងអាជីវកម្ម៖

១. ភាគី ក ត្រូវដាក់ចូលជាភាគហ៊ុនក្នុងក្រុមហ៊ុន នូវទ្រព្យសម្បត្តិ និងថវិកាដែលមានតម្លៃសរុបចំនួន…………………..ដុល្លារអាមេរិក(ស្មើនឹង៦០%) ដូចខាងក្រោម៖

- ដី និងផ្ទះដែលមានទីតាំងស្ថិតនៅ……………………………. មានផ្ទៃដីទំហំ…………………………...ម៉ែត្រក្រឡាដូចមានបញ្ជាក់ក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ…………...ចុះថ្ងៃទី…………..ចេញដោយ…………..។

អចលនវត្ថុនេះត្រូវកាត់ឈ្មោះចូលជាកម្មសិទ្ធិ របស់ក្រុមហ៊ុន។ គូភាគីព្រមព្រៀងកំណត់តម្លៃចលនវត្ថុនេះស្មើនឹង…………………………. ដុល្លារអាមេរិក។

- ទឹកប្រាក់ចំនួន…………………… ដុល្លារអាមេរិក។

២. ភាគី ខ ត្រូវបង់ថវិកាចូលក្រុមហ៊ុនចំនួន………………ដុល្លារអាមេរិក (ស្មើនឹង៤០%)។

៣. ក្នុងករណីបន្ថែមទុនវិនិយោគលើអាជីវកម្ម គូភាគីព្រមព្រៀងដាក់ទុនបន្ថែមក្នុងចំណែកសមាមាត្ររៀងៗខ្លួនស្របតាមអត្រា៦០%-៤០%ដូចខាងលើ។

**<u>ប្រការ ៣</u> : ភារកិច្ចនៃការទទួលខុសត្រូវ**

**១- ភារកិច្ច និងការទទួលខុសត្រូវរបស់ភាគី ក**

ក.(……………………………………………..)

ខ. (មានសិទ្ធិស្រាវជ្រាវទ្រព្យសម្បត្តិក្រុមហ៊ុន………………………………..)

គ. (……………………………………………..)

**២- ភារកិច្ច និងការទទួលខុសត្រូវរបស់ភាគី ខ**

ក.(……………………………………………..)

ខ.(មានសិទ្ធិស្រាវជ្រាវទ្រព្យសម្បត្តិក្រុមហ៊ុន……………………………..)

គ.(……………………………………………..)

ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោមៈ

ក.(……………………………………………..)

ខ.(……………………………………………..)

គ.(……………………………………………..)

ចំពោះបញ្ហាខាងក្រោមត្រូវសម្រេចជាឯកច្ឆន្ទ ដោយម្ចាស់ហ៊ុនទាំងអស់ ដែលជាគូភាគីនៃកិច្ចសន្យាៈ

ក.(……………………………………………..)

ខ.(……………………………………………..)

គ.(……………………………………………..)

<u>ប្រការ ៤</u> **: គណនីធនាគារ និងការចំណាយ**

- ក្រុមហ៊ុនត្រូវបើកគណនីមួយនៅធនាគារ…………………..សម្រាប់ចំណូលចំណាយដែលពាក់ព័ន្ធ ទៅនឹងកិច្ចសន្យានេះ។
- ចំពោះការចំណាយចាប់ពីចំនួន១០០ដុល្លារ ឡើងទៅត្រូវចេញជាមូលប្បទានប័ត្រដាក់ឈ្មោះអ្នកទទួលដាក់លាក់ និងត្រូវមានហត្ថលេខាពីគូភាគីដែលទទួលនោះ។
- ចំពោះការចំណាយតិចជាងចំនួន១០០ដុល្លារ ភាគី កមានសិទ្ធិសម្រេចជាបណ្ដោះអាសន្ន ប៉ុន្តែត្រូវដាក់ជូនភាគី ខ ពិនិត្យនិងផ្ដល់ការឯកភាពនៅរៀងរាល់សប្ដាហ៍នីមួយៗ។

<u>ប្រការ ៥</u> **: ការបែងចែកភាគលាភ**

គូភាគី បានព្រមព្រៀងថា ប្រាក់ចំណេញដែលបានមកពីកិច្ចសហការអាជីវកម្ម បន្ទាប់ពីបង់ពន្ធដារនានា និងចាត់ចែងលើការចំណាយក្នុងប្រតិបត្តិការអាជីវកម្មរួចហើយ ត្រូវបែងចែកតាមចំណែក និងសមាមាត្រ ដូចខាងក្រោម៖

១. ភាគី ក ៦០%(ហុកសិបភាគរយ) នៃប្រាក់ចំណេញសុទ្ធ និង

២. ភាគី ខ ៥០%(សែសិបភាគរយ) នៃប្រាក់ចំណេញសុទ្ធ

លើកលែងតែគូភាគីព្រមព្រៀងគ្នាផ្សេងពីនេះ ការបែងចែកប្រាក់ចំណេញ ត្រូវធ្វើឡើងនៅរៀងរាល់បីខែម្តង។

**ប្រការ ៦ : អំឡុងពេល ការបំពានកាតព្វកិច្ច និងការបញ្ចប់កិច្ចសន្យា**

-កិច្ចសន្យានេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទដូចមានចែងខាងដើម និងបន្តរហូតដល់ពេលបញ្ចប់ ដោយភាគីណាមួយ ឬដោយភាគីទាំងពីរស្រប តាមប្រការនេះ។

-កិច្ចសន្យានេះត្រូវបញ្ចប់ក្នុងករណីណាមួយដូចខាងក្រោម:

១-មានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់គូភាគី។

២-ផុតថ្ងៃទី.........បន្ទាប់ពីមានការជូនដំណឹងពីភាគីណាមួយ ថាភាគីម្ខាងទៀត បានខកខានក្នុងការបំពេញកាតព្វកិច្ចសំខាន់ណាមួយតាមកិច្ចសន្យានេះ ហើយ ភាគីដែលទទួលការជូនដំណឹង មិនបានកែតម្រូវក្នុងរយៈពេល.......ថ្ងៃនោះ។ ភាគីដែលបំពាន ត្រូវទទួលខុសត្រូវសងសំណង ការខូចខាត និងការខាតបង់ ទាំងអស់របស់ភាគីរងគ្រោះត្រូវទទួលរង ឬត្រូវចំណាយ។

៣-ភាគីណាមួយជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យា រយៈពេល.........ថ្ងៃជាមុន។ នៅពេលបញ្ចប់កិច្ចសន្យា កាតព្វកិច្ចរបស់គូភាគី ត្រូវគិតមកទល់កាលបរិច្ឆេទ បញ្ចប់កិច្ចសន្យា ហើយត្រូវជម្រះបញ្ជី និងបិទក្រុមហ៊ុន ព្រមទាំងជម្រះបំណុល និងកាតព្វកិច្ចផ្សេងៗទាំងអស់។

**ប្រការ ៧ : ការរក្សាការសម្ងាត់**

លើកលែងតែតម្រូវដោយច្បាប់ ឬដីការតុលាការ ឬមានការព្រមព្រៀងរវាងគូភាគី ភាគីនីមួយៗមិនត្រូវទម្លាយឱ្យជនដទៃដឹងអំពីព័ត៌មានទាក់ទងនឹងកិច្ចសន្យានេះ ឬអំពីព័ត៌មានសម្ងាត់របស់ភាគីម្ខាងទៀតឡើយ។

<u>ប្រការ ៨</u> : **ការជូនដំណឹង**

រាល់ការជូនដំណឹងរវាងគូភាគី ពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យានេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងបញ្ជូនតាមលិខិតអនុសិដ្ឋផ្លូវការរបស់រដ្ឋ ឬដោយផ្ទាល់ដៃទៅអាស័យដ្ឋានដូចមានចែងខាងដើម ហើយត្រូវចាត់ទុកថា ភាគីដែលត្រូវទទួលបានទទួលរួចរាល់ក្នុងករណីណាមួយដូចខាងក្រោះ

១-ប្រសិនបើប្រគល់ជូនផ្ទាល់ដៃ ការប្រគល់ និងការទទួលសេចក្តីជូនដំណឹងនោះកើតឡើងនៅពេលប្រគល់តែម្តង។ ភស្តុតាងនៃការប្រគល់ជូន អាចជាហត្ថលេខារបស់ភាគីដែលត្រូវទទួលបញ្ជាក់ថា បានទទួល ឬអាចជាហត្ថលេខារបស់សាក្សីពីររូបដែលបញ្ជាក់ពីការបានប្រគល់។

២-ប្រសិនជាផ្ញើរតាមលិខិតអនុសិដ្ឋផ្លូវការរបស់រដ្ឋ ការប្រគល់ជូនកើតឡើងនៅមួយថ្ងៃបន្ទាប់ពីថ្ងៃដែលការិយាល័យប្រៃសណីយ៍បញ្ជាក់ថា បានទទួលកញ្ចប់បញ្ញើនោះ។

<u>ប្រការ ៩</u> : **ច្បាប់គ្រប់គ្រង និងដំណើរស្រាយវិវាទ**

-កិច្ចសន្យានេះ ត្រូវបានគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

-គូភាគី ព្រមព្រៀងដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យានេះ តាមរយៈការចរចារជាមិត្តភាព។ ក្នុងករណីដែលការចរចារជាលក្ខណៈមិត្តភាពត្រូវបរាជ័យ ការដោះស្រាយវិវាទត្រូវធ្វើឡើងដោយមជ្ឈត្តការ នៅព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមានប្រសិទ្ធភាពជាធរមាននៅពេលជូនដំណឹងអំពីមជ្ឈត្តការ។ តាមរយៈការចែងយោងនេះ វិធានមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវចាត់ទុកថាបានចែងបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

-គូភាគីព្រមព្រៀងគ្នាលើការចំណាយនៃដំណើរការមជ្ឈត្តកម្ម និងចំនួនអត្តសញ្ញាណមជ្ឈត្តករ។ បើពុំមានការព្រមព្រៀងគ្នាក្នុងរយៈពេលមួយសប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងអំពីមជ្ឈត្តការទេ វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករមួយរូប ដែលជ្រើសរើសដោយប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហើយមជ្ឈត្តករ ត្រូវសម្រេចអំពីការចំណាយ និងការបែងចែកបន្ទុកចំណាយរបស់គូភាគី។

-ភាគីនីមួយៗ ព្រមព្រៀងដោយស្ម័គ្រចិត្ត និងជាក់លាក់លើការបោះបង់សិទ្ធិក្នុងការស្នើសុំអន្តរាគមន៍ពីតុលាការ លើកលែងតែកិច្ចអន្តរាគមន៍នោះ ត្រូវធ្វើឡើងដើម្បីអនុវត្តប្រការនេះ ដើម្បីប្រតិបត្តិមជ្ឈត្តវិនិច្ឆ័យ ឬដើម្បីអនុវត្តវិធានការបណ្តោះអាសន្នដទៃទៀត ដែលសម្រេចដោយវេទិកាមជ្ឈត្តកម្ម។

**<u>ប្រការ ១០</u> : បទប្បញ្ញត្តិទូទៅ**

កិច្ចសន្យានេះ ចំណុះទៅនឹងបញ្ញត្តិ និងលក្ខខណ្ឌបន្ថែមដូចខាងក្រោមៈ

១-ភាគីនីមួយៗ មិនអាចផ្ទេរសិទ្ធិ ឬកាតព្វកិច្ចក្នុងកិច្ចសន្យានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីភាគីម្ខាងទៀតបានឡើយ។

២- ប្រសិនបើមានបញ្ញត្តិណាមួយនៃកិច្ចសន្យា មិនអាចអនុវត្តបាន ឬអសុពលភាព ឬមិនស្របច្បាប់ នោះភាគីត្រូវបន្តអនុវត្ត និងគោរពតាមរាល់បញ្ញត្តិ និងលក្ខខណ្ឌផ្សេងៗដទៃទៀតទាំងអស់។

៣-កិច្ចសន្យានេះ បង្កើតជាកិច្ចព្រមព្រៀងទាំងស្រុងរបស់គូភាគី ហើយជំនួសរាល់ការព្រមព្រៀង ឬការសន្យានានាទាំងអស់ ដែលមានពីមុនមកទាក់ទងនឹងកម្មវត្ថុនៃកិច្ចសន្យានេះ។

៤-ការកែប្រែ វិសោធនកម្ម ឬការថែងបន្ថែមណាមួយលើកិច្ចសន្យានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយគូភាគី ទើបមានប្រសិទ្ធភាពអនុវត្តលើគូភាគី។

៥-កិច្ចសន្យានេះ ចងកាតព្វកិច្ចលើទាយាទ អ្នកទទួលសិទ្ធិ ឬអច្ច័យលាភីរបស់ភាគីនីមួយៗ។

ដើម្បីជាសក្ខីភាពនៃការព្រមព្រៀង គូភាគី បានចុះកិច្ចសន្យានៅកាលបរិច្ឆេទដូចមានចែងខាងដើម។

ភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ.............

**ស្នាមមេដៃស្តាំ**
**ភាគី "ក"**

ឈ្មោះ......................

**ស្នាមមេដៃស្តាំ**
**សាក្សី**

ឈ្មោះ......................

**ស្នាមមេដៃស្តាំ**
**ភាគី "ខ"**

ឈ្មោះ......................

**ស្នាមមេដៃស្តាំ**
**សាក្សី**

ឈ្មោះ......................